ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-
ព្រឹទ្ធសភា និងអធិការកិច្ច

# របាយការណ៍បូកសរុប
# ការងារ ឆ្នាំ២០២១
# និងទិសដៅ ឆ្នាំ២០២២



2022

# មាតិកា

**អារម្ភកថា**..........1
**ផ្នែកទី ១-សមិទ្ធផលការងារឆ្នាំ ២០២១**..........3
**១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ**..........4
១-១-ការងាររដ្ឋបាល..........4
១.២.ការងារបុគ្គលិក និងធនធានមនុស្ស..........5
១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់..........8
១.៤.ការងារផែនការ និងស្ថិតិ..........8
១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ..........10
**២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**..........11
២.១.ការងារនីតិកម្ម..........11
២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់..........11
២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល..........13
២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា..........13
២.៥.ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ..........13
**៣.សកម្មភាពការងារអធិការកិច្ច**..........14
៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច..........14
៣.២.ការងារអធិការកិច្ចលើវិស័យរដ្ឋបាលទូទៅ..........14
៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច..........15
៣.៤.ការងារតាមដានការអនុវត្តច្បាប់..........15
៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ..........22
**៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង**..........30
**៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច**..........31
**៦.សកម្មភាពការងារផ្សេងៗ**..........32
៦.១.សកម្មភាពការងារយេនឌ័រ..........32
៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព..........33
៦.៣. សមាគមសង្គហមិត្តភាព..........33
៦.៤.សកម្មភាពក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និង លិខិត បទដ្ឋានគតិយុត្ត..........34
៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង..........34
៦.៦.សកម្មភាពការងារក្រុមការងារ សម្រង់ព័ត៌មាន និងខ្លឹមសារ អនុសាសន៍របស់សម្តេចតេជោ នាយរដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់..........34
៦.៧.សកម្មភាពការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App..........34

៦.៨.ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ..... 35
**ផ្នែកទី ២-បញ្ហាប្រឈម** ..... 37
**១. ការប្រឈមផ្នែករដ្ឋបាល** ..... 38
**២. ការប្រឈមផ្នែកទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ..... 38
**៣. ការប្រឈមផ្នែកអធិការកិច្ច** ..... 38
**៤. ការប្រឈមផ្នែកនីតិកម្ម** ..... 39
**៥. ការប្រឈមផ្សេងទៀត** ..... 39
**ផ្នែកទី ៣. ទិសដៅការងារឆ្នាំ ២០២២** ..... 41
**១. រដ្ឋបាលកិច្ចការទូទៅ** ..... 42
១-១-ការងាររដ្ឋបាល ..... 42
១-២-ការងារបុគ្គលិក និងធនធានមនុស្ស ..... 42
១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ..... 42
១-៤-ការងារផែនការ និងស្ថិតិ ..... 43
**២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ..... 44
**៣.ការងារអធិការកិច្ច** ..... 44
**៤.ការងារសវនកម្មផ្ទៃក្នុង** ..... 45
**៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច** ..... 45
៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ..... 45
៥.២. ការងារផែនការ និងស្រាវជ្រាវ ..... 46
៥.៣. ការងារបណ្តុះបណ្តាល ..... 46
៥.៤. ការងារទំនាក់ទំនងសាធារណៈ ..... 47
**៦.ការងារផ្សេងៗ** ..... 47
៦.១.ការងារយេនឌ័រ ..... 47
៦.២.ការងារចងសម្ព័ន្ធមេត្រីភាព ..... 47
៦.៣.ការងារសមាគមសង្គហមិត្តភាព ..... 48
៦.៤.ការងារក្រុមការងារ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ..... 48
៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ..... 48
៦.៦.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App ..... 48
៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ..... 48
**ផ្នែកទី៤. សេចក្តីសន្និដ្ឋាន** ..... 51
**ផ្នែកទី ៥. ឧបសម្ព័ន្ធ** ..... 55
**ឧបសម្ព័ន្ធ ទី១. កម្មវិធីសន្និបាត** ..... 56

ឧបសម្ព័ន្ធ ទី២. របាយការណ៍សង្ខេប ..... 58
ឧបសម្ព័ន្ធ ទី៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត ..... 80
ឧបសម្ព័ន្ធ ទី៤. សុន្ទរកថាបើកសន្និបាត ..... 84
ឧបសម្ព័ន្ធ ទី៥. សុន្ទរកថាបិទសន្និបាត ..... 89
ឧបសម្ព័ន្ធ ទី៦. កម្រងរូបថតអនុស្សាវរីយ៍ ..... 95

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឧត្តុង្គឧត្តម និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**បានទទួលសេចក្តីសុខ សន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយជាលំដាប់ នៅពេលដែលកម្រិតជីវភាពប្រជាពលរដ្ឋទូទាំងប្រទេសកាន់តែធូរធារ។ កម្ពុជាដែលធ្លាប់ជាសមរភូមិ នៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច និងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ជាវាលពិឃាតនៃរបបប្រល័យពូជសាសន៍ បានប្រែក្លាយទៅជាទីផ្សារ វិនិយោគដ៏ទាក់ទាញជាម្មណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងជាប្រទេសមួយមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសដទៃលើពិភពលោក។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ របបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហ ដោយធ្វើការកែទម្រង់ស៊ីជម្រៅ និងដាក់ចេញយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការងារចំបងគឺទំនាក់ទំនង សម្របសម្រួលរវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យសំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

ទោះជានៅឆ្នាំ ២០២១ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសនានា ក្នុងពិភពលោក ត្រូវបានញាំញីដោយវិបត្តិនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ដែលបានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។ ដោយឡែកក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចជួបប្រទះការប្រឈមខ្លះ ដោយការរឹតត្បិត ការជួបប្រជុំ និងការកាត់បន្ថយការចំណាយលើខ្ទង់មួយចំនួនដែលបណ្តាលឲ្យប៉ះពាល់ដល់លទ្ធផលការងារ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងខិតខំបំពេញការងារ ប្រកបដោយការទទួលខុសត្រូវ និងសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។

យើងពិតជាមានមោទនភាព និងអំណរសាទរចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្ដេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំដ៏ត្រឹមត្រូវ ដោយមានផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ រួមនឹងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាព នានា។

របាយការណ៍លទ្ធកលការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២នេះបានមកពីលទ្ធផលសន្និបាតប្រចាំឆ្នាំរបស់ក្រសួង ដែលបានប្រារព្ធធ្វើកាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០២២ នៅសណ្ឋាគារសុខាភ្នំពេញ។

ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២២

កិត្តិសង្គហបណ្ឌិត ម៉ែន_សំអន

# ផ្នែកទី ១-សមិទ្ធផលការងារឆ្នាំ ២០២១



## ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បានទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន១,០៥២ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន ៦៧៨ ច្បាប់។

-បានថតចម្លងរាល់លិខិតចេញ-ចូលក្នុងក្រសួងតម្កល់ទុកជាឯកសារ។

-បានរៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-បានរៀបចំតាំងបដាពាក្យស្លោក ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ នៅទីស្តីការក្រសួង។

-បានរៀបចំ និងបញ្ជូនសារលិខិតថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងផ្ញើសារលិខិតជូនពរថ្នាក់ដឹកនាំ កំពូលរបស់ជាតិ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ និងពិធីខួបកំណើត។

-បានរៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងផែនការ និងរបាយការណ៍អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ។

-បានរៀបចំបូកសរុបរបាយការណ៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី។

-បានរៀបចំលិខិតបង្គាប់ការចាត់មន្ត្រីរាជការចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-បានចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ សន្និបាតបូកសរុបលទ្ធផលការងារ ប្រកាសតែងតាំងចូលកាន់មុខតំណែង សម្ពោធសមិទ្ធផលនានា ជាអនុរក្ស-អប្បមាទ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-បានត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-បានចូលរួមប្រជុំគណៈកម្មការសន្និបាត និងអនុគណៈកម្មការឯកសារ ដើម្បីត្រៀមលក្ខណៈរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅទីស្តីការក្រសួងចំនួន៥លើក។

-បានចូលរួមប្រជុំអនុគណៈកម្មការអនុរក្ស និងអនុគណៈកម្មការអប្បមាទស្តីពីការត្រៀមប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត មន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នចំនួន ៨ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួន១លើក។

-បានចូលរួមប្រជុំស្តីពីការត្រៀមលក្ខណៈរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ ដើម្បីសម្ពោធវិមានកីឡាដ្ឋាននៃពហុកីឡាដ្ឋានជាតិមរតកតេជោ និងការត្រៀមលក្ខណៈទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិចំនួន៥លើក។

## ១.២.ការងារបុគ្គលិក និងធនធានមនុស្ស

-បានធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការតាំងស៊ប់បំពេញសិទ្ធិនៅក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រាប់ឆ្នាំ២០២១។

-បានធ្វើសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងាររាជរដ្ឋាភិបាល ឌីជីថលបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យចូលបម្រើការងារ នៅទីស្តីការក្រសួង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២១ និងសម្រាប់ឆ្នាំ២០២២។

-បានធ្វើប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការចំនួន៤រូប ជាអនុប្រធាននាយកដ្ឋានចំនួន១រូប ជាជំនួយការលោកជំទាវរដ្ឋលេខាធិការ ចំនួន១រូប ជាប្រធានការិយាល័យចំនួន១រូប និងជាអនុប្រធានការិយាល័យចំនួន១រូប។

-បានធ្វើប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចំនួន៤រូប ពីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចឱ្យទៅបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១រូប ក្រសួងយុត្តិធម៌ចំនួន១រូប ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១រូប និងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃចំនួន១រូប។

-បានធ្វើប្រកាសស្តីពីការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការចំនួន៥រូប ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១រូប ពីក្រសួងពាណិជ្ជកម្មចំនួន១រូប ពីក្រសួងព័ត៌មានចំនួន១រូប ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន១រូប និងពីក្រសួងអប់រំ យុវជន និងកីឡាចំនួន១រូប ឱ្យមកបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច។

-បានធ្វើប្រកាសស្តីពីការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការថ្មីចំនួន៦រូប ឱ្យមកបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន១រូប ចូលបម្រើការងារឡើងវិញ។

-បានធ្វើលិខិតស្តីពីសំណើសុំពិនិត្យ និងផ្តល់នីត្យានុកូលភាពដល់មន្ត្រីរាជការចំនួន៧រូប។

-បានធ្វើលិខិតស្តីពីសំណើសុំគោលការណ៍តាំងស៊ប់បំពេញសិទ្ធិជូនមន្ត្រីរាជការចំនួន៦រូប ក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើលិខិតស្ដីពីការបែងចែកផែនការក្របខ័ណ្ឌមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ឆ្នាំ២០២១។

-បានធ្វើលិខិតស្ដីពីសំណើសុំផ្ដល់បញ្ជីឈ្មោះមន្ត្រីរាជការ ដែលត្រូវដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ និងដំឡើងថ្នាក់តាមវេនអតីតភាព សម្រាប់ឆ្នាំ២០២១។

-បានធ្វើលិខិតស្ដីពីសំណើសុំលុបឈ្មោះមន្ត្រីរាជការចំនួន១រូប ក្រុមប្រឹក្សាជំនួយការក្រសួង ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ជូនទៅក្រសួងមុខងារសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ។

-បានធ្វើលិខិតស្ដីពីសំណើចាត់បញ្ជូនតំណាងក្រសួងចំនួន២រូប ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC)លើកទី១៩។

-បានធ្វើលិខិតស្ដីពីការចាត់បញ្ជូនថ្នាក់ដឹកនាំ១រូប ជារដ្ឋលេខាធិការ ដើម្បីចូលជាសមាជិកគណៈកម្មាធិការពិសេសតាមដានអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជន និងអភិវឌ្ឍន៍។

-បានធ្វើ និងបញ្ជូនរបាយការណ៍ស្ដីពីបច្ចុប្បន្នភាពមន្ត្រីរាជការ ដែលបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ សម្រាប់ឆ្នាំ២០២១ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធ។

-បានធ្វើរបាយការណ៍ស្ដីពីការបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភចូលឆ្នាំថ្មីប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា សម្រាប់ខែមេសា និងខែកញ្ញា ឆ្នាំ២០២១ ជូនធនាគារអេស៊ីលីដា និងនាយកដ្ឋានពាក់ព័ន្ធ។

-បានធ្វើរបាយការណ៍ស្ដីពីសំណើសុំពិនិត្យ និងផ្ដល់ទិដ្ឋាការ លើសំណុំឯកសារផ្លាស់ប្ដូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់ឆ្នាំ២០២១ ជូនក្រសួងមុខងារសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ។

-បានបញ្ជូនតារាងទូទាត់ប្រាក់បៀវត្ស និងអាណត្តិបើកប្រាក់បៀវត្សសម្រាប់ឆ្នាំ២០២១ ដែលមានហត្ថលេខាឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជូននាយកដ្ឋានពាក់ព័ន្ធ។

-បានធ្វើ និងបញ្ជូនលិខិតលេខ២៤៨/២១ ទរពអ.រប ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១ ស្ដីពីវិញ្ញាបនប័ត្រផ្ដាច់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីរាជការដែលផ្ទេរចេញចំនួន១រូប ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។

-បានធ្វើកំណត់បង្ហាញស្ដីពីសេចក្ដីសម្រេច ស្ដីពីការទទួលស្គាល់សិក្ខាកាម ជាន់ខ្ពស់នៃវគ្គបណ្ដុះបណ្ដាល «ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍»ឆ្នាំ២០២១។

-បានធ្វើលិខិតលេខ៣១៧/២១ ទរពអ. រប ស្ដីពីការចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ដើម្បីចូលរួមក្នុងទិវាប្រជាជនពិភពលោក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធZoom។

-បានធ្វើលិខិតលេខ៣១៥/២១ ទរពអ.រប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការចាត់មន្ត្រីរាជការចំនួន៣រូប ចូលរួមសិក្ខាសាលាស្ដីពីយុទ្ធសាស្ត្រសន្តិសុខសាយប័រ (Workshop on Cybersecurity Strategy) តាមប្រព័ន្ធZoom។

-បានធ្វើលិខិតស្តីពីការចាត់តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២រូប ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំពីការរៀបចំធាតុចូល សម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ តាមប្រព័ន្ធZoom។

-បានធ្វើលិខិតស្តីពីការចាត់តាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល ២០២២-២០២៤ តាមប្រព័ន្ធ Zoom។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំចំនួន៣រូប ដើម្បីចូលរួមសិក្ខាសាលាពីចម្ងាយស្តីពីបទពិសោធន៍ សឹង្ហបុរីក្នុងការជំរុញលទ្ធផលនៃការអនុវត្តថវិកា តាមប្រព័ន្ធZoom។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំចំនួន១រូប និងមន្ត្រីជំនាញចំនួន១រូប ដើម្បីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ តាមប្រព័ន្ធ Zoom។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ចំនួន១រូប ដើម្បីចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍អំពីស្ថានភាពប្រជាសាស្ត្រ និងសង្គមកិច្ច-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជាតាមប្រព័ន្ធZoom។

-បានធ្វើលិខិត ស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួងចំនួន១រូប ដើម្បីចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ តាមប្រព័ន្ធZoom។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួងជំនាញចំនួន២រូប ធ្វើបទឧទ្ទេសនាមក្នុងសិក្ខាសាលាស្តីពីគោលការណ៍ និងនីតិវិធីនៃការធ្វើអធិការកិច្ច និងសវនកម្ម តាមប្រព័ន្ធZoom។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូប ដែលជាថ្នាក់ដឹកនាំនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ តាមប្រព័ន្ធZoom។

***ការងារបណ្តុះបណ្តាល**

-បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចបឋមជំនាន់៣ វគ្គ១ ជូនមន្ត្រីរាជការចំនួន៤៥រូប នៅទីស្តីការក្រសួង។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៨រូបជាកម្មសិក្សាការីនៃវគ្គវិក្រឹត្យការជាន់ខ្ពស់ វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល វគ្គវិក្រឹត្យការមធ្យម និងវគ្គវិក្រឹត្យការក្រមការនៃវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០២១ នៅសាលាភូមិន្ទរដ្ឋបាល។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល(ក.វ.ស) នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន ១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងឯកសារពិន្ទុវិស័យ សម្រាប់ធ្វើជាឧបករណ៍វិភាគបញ្ហាតម្រូវការ និងដំណោះស្រាយ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ នៅមន្ទីរផែនការខេត្តកែប។

-បានចាត់បញ្ជូនមន្ត្រីចំនួន ១៤ រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅសណ្ឋាគារ៧មករាខេត្តកំពង់ចាម។

-បានចាត់បញ្ជូនមន្ត្រីរាជការ ចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាច់ប្រាក់ (online web-based application) នៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនថ្នាក់ដឹកនាំចំនួន ៤រូប ចូលរួមបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ភាពជាថ្នាក់ដឹកនាំដើម្បីកែទម្រង់ នៅសាលាភូមិន្ទរដ្ឋបាល តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ចូលរួមវគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)បទពិសោធន៍ប្រទេសចិន តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមបណ្តុះបណ្តាលស្តីពីជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគណនេយ្យសាធារណៈ និងនីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៥រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ជំនាន់ទី២ និងLaunching Workshop on Leadership and Innovation Program តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការដែលជាប្រធាន ឬអនុប្រធាននាយកដ្ឋានចំនួន ២រូបទទួលបន្ទុកការងារចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជនបទពិសោធន៍របស់ប្រទេសចិន និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បទពិសោធន៍របស់ប្រទេសចិន តាមប្រព័ន្ធZoom។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាសមិទ្ធកម្ម តាមប្រព័ន្ធZoom។

### ១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-បានទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស លទ្ធកម្ម។ល។

### ១.៤.ការងារផែនការ និងស្ថិតិ

-បានរៀបចំគម្រោងវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០២២-២០២៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជូនក្រសួងផែនការ។

-បានរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានរៀបចំគម្រោងថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ (ចំណាយទូទៅ របស់រដ្ឋលម្អិតតាមមាតិកាថវិកា និងមាតិកាកម្មវិធី) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២២-២០២៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានរៀបចំចងក្រងជាសៀវភៅថវិកា សម្រាប់គ្រប់គ្រងឆ្នាំ២០២២ និងសៀវភៅផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២២-២០២៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបណ្តាអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

-បានរៀបចំ និងចងក្រងទិន្នន័យស្ថិតិផ្លូវការ ដែលបានចាត់តាំងទៅតាមវិស័យ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់ឆ្នាំ២០២១ ជូនទីស្តីការគណរដ្ឋមន្ត្រី ក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិ។

-បានរៀបចំ និងចងក្រងទិន្នន័យស្ថិតិទូទៅ ប្រចាំឆ្នាំ២០២១ អំពីបម្រែបម្រួលចំនួនមន្ត្រីតាមបណ្តាអង្គភាព និងតាមមន្ទីររាជធានី-ខេត្ត ចំណុះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

-បានរៀបចំចងក្រងសៀវភៅស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់ឆ្នាំ២០២១។

-បានរៀបចំកែសម្រួលទម្រង់របាយការណ៍លទ្ធផលនៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០២១។

-បានរៀបចំ និងចងក្រងឯកសារពាក់ព័ន្ធការងារតាមដាន និងវាយតម្លៃរបស់នាយកដ្ឋាន ព្រមទាំងលិខិតបទដ្ឋាននានា របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានបូកសរុបរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាកម្មវិធីប្រចាំឆមាសទី១ និងប្រចាំឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានទាំងបី និងបណ្តាមន្ទីររាជធានី-ខេត្ត របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម រៀបចំឡើងដោយក្រសួងផែនការ។

-បានចូលរួមវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្មតាមប្រព័ន្ធអនឡាញ ក្រោមការសម្របសម្រួលរបស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសតាមប្រព័ន្ធអនឡាញលើគម្រោងផែនការចំណូល-ចំណាយថវិកា ឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួងតាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ឆ្នាំ២០២២-២០២៤។

-បានចូលរួមកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ លើសេចក្តីព្រាង ស្តីពីស្ថានភាពភាគលាភប្រជាសាស្ត្រ និងយេនឌ័រនៅកម្ពុជា រៀបចំដោយក្រសួងផែនការ និងស្ថិតិ។

-បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពីការពិនិត្យផ្តល់សុពលភាព លើរបាយការណ៍វាយតម្លៃស្ថិតិយេនឌ័រនៅកម្ពុជា រៀបចំដោយក្រសួងផែនការ និងស្ថិតិ។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងកែសម្រួលចំណុចដៅសូចនាករ ព្រមទាំងតម្លៃនៃចំណុចដៅសូចនាករនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គអចក) នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ស្ថិតក្រោមការចាត់ចែងរបស់ក្រសួងផែនការ និងស្ថិតិ។

-បានចូលរួមកិច្ចប្រជុំស្តីពីការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅទីស្តីការក្រសួង។

## ១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ

-បានសម្របសម្រួលជាមួយស្ថានទូតអូស្រ្តាលី និងបកប្រែលិខិតស្តីពីការជួបសម្តែងការគួរសមរវាងឯកឧត្តមអនុប្រធានបេសកកម្ម Andreas Zurbrugg និងឯកឧត្តម Nguyen Huy Tang ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជាមួយថ្នាក់ដឹកនាំក្រសួង។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួងនៃគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា វៀតណាម (JC) លើកទី១៨ ឆ្នាំ២០២០ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស រយៈពេល៣ថ្ងៃ ក្រោមអធិបតីភាពឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម PHAN BINH ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមប្រព័ន្ធវីដេអូ Conference កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០។

-បានទទួលកំណត់ហេតុពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីកិច្ចប្រជុំអន្តរក្រសួងនៃគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា-វៀតណាម (JC) លើកទី១៨ ឆ្នាំ២០២០ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ តាមប្រព័ន្ធវីដេអូ Conference។

-បានចូលរួមកិច្ចប្រជុំស្តីពីការបញ្ចូលធាតុចូល(JC) លើកទី១៩ ក្រោមការដឹកនាំរបស់លោកជំទាវ សុភ័គ្គ ថាវី រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅទីស្តីការក្រសួង។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីត្រៀមរៀបចំកិច្ចប្រជុំនៃគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា-វៀតណាម (JC) លើកទី១៩ ឆ្នាំ២០២១ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ Conference។

-បានចូលរួមកិច្ចប្រជុំជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ(JC) លើកទី១៩ និងសេចក្តីព្រាងសេចក្តីប្រកាសរួមក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ កាលពីថ្ងៃទី១៣-១៤ ខែធ្នូ ឆ្នាំ២០២១ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បានចូលរួមកិច្ចប្រជុំពេញអង្គដើម្បីពិភាក្សាលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ(JC) លើកទី១៩ និងសេចក្តីព្រាងសេចក្តីប្រកាសរួមក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២១ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមបណ្តុះបណ្តាលស្តីពីជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ តាមប្រព័ន្ធវីដេអូConference ដែលមានរយៈពេល៣សប្តាហ៍។

-បានបកប្រែលិខិតចំនួន១១ច្បាប់។

## ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក តាមប្រព័ន្ធ Zoom។

-បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក នៅទីស្តីការក្រសួង។

-បានរៀបចំកិច្ចប្រជុំ និងចូលរួមកិច្ចប្រជុំនៅទីស្តីការក្រសួង និងក្រសួងស្ថាប័នផ្សេងពាក់ព័ន្ធនឹងការងារផ្សេងៗ ចំនួន១២លើក ក្នុងនោះតាមប្រព័ន្ធអនឡាញចំនួន៤លើក។

-បានចូលរួមសិក្ខាសាលាស្តីពីយុទ្ធសាស្ត្រសន្តិសុខសាយប័រ (Workshop on Cybersecurity Strategy) ដឹកនាំដោយ ឯកឧត្តម នាង ម៉ៅ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមប្រព័ន្ធZoom ។

-បានចូលរួមសិក្ខាសាលាស្តីពីការវាយប្រហាររបស់មេរោគចាប់ចំរិត និងវិធីសាស្ត្រឆ្លើយតប ដឹកនាំដោយនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមប្រព័ន្ធZoom។

-បានចូលរួមសិក្ខាសាលាស្តីពីAdvanced CSIRT Technical Training សម្របសម្រួលដោយនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមប្រព័ន្ធZoom។

-បានចូលរួមសិក្ខាសាលាស្តីពីការពិគ្រោះយោបល់លើកចុងក្រោយ ស្តីពីការរៀបចំយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមប្រព័ន្ធZoom។

-បានបញ្ចូលអត្ថបទច្បាប់ចំនួន៨០ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

-បានចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ចំនួន៨លើក គឺច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន៤លើក(ខេត្តមណ្ឌលគិរីចំនួន១លើក រតនគិរីចំនួន១លើក កំពង់ចាមចំនួន១លើក និងខេត្តពោធិ៍សាត់ចំនួន១លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៣លើក(ខេត្តកំពតចំនួន៣លើក) និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១លើក (ខេត្តកំពង់ធំចំនួន១លើក) ដោយមានអ្នកចូលរួមចំនួន១,៣៣២នាក់ (ស្ត្រីចំនួន៥៥៧នាក់)។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-បានចុះផ្សព្វផ្សាយច្បាប់ចំនួន៧៣លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៥លើក និងមន្ទីររាជធានី-ខេត្តចំនួន៦៨លើក) គឺច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១៥លើក(ខេត្តកំពង់ចាមចំនួន៤លើក ឧត្តរមានជ័យចំនួន៤លើក ក្រចេះចំនួន៣លើក ព្រះសីហនុ ចំនួន

១លើក សៀមរាបចំនួន១លើក តាកែវចំនួន១លើក និងខេត្តកំពតចំនួន១លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១២លើក(ខេត្តព្រះសីហនុចំនួន៤លើក កំពង់ចាមចំនួន២លើក កែបចំនួន២លើក កំពង់ធំចំនួន២លើក ក្រចេះចំនួន១លើក និងខេត្តកំពតចំនួន១លើក) ច្បាប់ភូមិបាលចំនួន១លើក (ខេត្តសៀមរាបចំនួន១លើក) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចំនួន១លើក (ខេត្តសៀមរាបចំនួន១លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៣លើក (ខេត្តព្រៃវែងចំនួន៣លើក) ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាចំនួន ១២លើក (ខេត្តកំពង់ធំចំនួន៥លើក ពោធិ៍សាត់ចំនួន៤លើក កែបចំនួន១លើក មណ្ឌលគិរីចំនួន១លើក និងខេត្តរតនគិរីចំនួន១លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន១៤លើក (ខេត្តស្វាយរៀងចំនួន១៤លើក) និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន១៥លើក (ខេត្តត្បូងឃ្មុំចំនួន៩លើក និងខេត្តកែបចំនួន៦លើក) ដោយមានអ្នកចូលរួមចំនួន៦,៧៩៧នាក់ (ស្ត្រីចំនួន២,៨៥៩នាក់) និងបានទទួលសំណួរចំនួន៥២៥សំណួរ។

-បានចុះចែកឯកសារច្បាប់ចំនួន១៧លើក គឺច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១៦លើក និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាចំនួន១លើក ជូនក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងខេត្តក្រចេះ ចំនួន២,០១៥ច្បាប់។

-បានរៀបចំកម្មវិធីថតវីឌីអូផ្សព្វផ្សាយច្បាប់ សម្រាប់ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងតាមបណ្តាញសង្គម ដោយសហការជាមួយស្ថានីយទូរទស្សន៍អប្សារាប៉ុស្តិ៍លេខ១១រួមមានៈ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីសញ្ជាតិ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពី

ការត្រួតពិនិត្យគ្រឿងញៀន អនុក្រឹត្យស្តីពីការគ្រប់គ្រងជីវជ្ជ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ភូមិបាល (ប្រធានបទះសម្បទានដីសង្គមកិច្ច និងកម្មសិទ្ធិឯកជន) ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីអស្សាមិករណ៍។

-បានរៀបចំផ្សព្វផ្សាយសេចក្តីជូនដំណឹង សារាចរណែនាំ និងវិធានការ តាមរយៈវិទ្យុជាតិភ្នំប្រុសភ្នំស្រី និងផេកមន្ទីរព័ត៌មានខេត្តកំពង់ចាមរួមមាន៖ អំពីការអប់រំអនុវត្តវិធានការ ៣ការពារ ៣កុំចំនួន១៨០លើក អំពីការជំរុញឱ្យកុមារ និងយុវវ័យមានអាយុពី១២ឆ្នាំដល់ក្រោម១៨ឆ្នាំ ទៅទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួន១២០លើក អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន សេចក្តីជូនដំណឹងស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០២១ និងស្តីពីការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២១ សេចក្តីជូនដំណឹងស្តីពីការចូលរួមរបស់អាជ្ញាធរក្នុងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារចំនួន ២៤០លើក និងសេចក្តីជូនដំណឹងស្តីពីការពិន័យអន្តរកាលចំពោះអ្នកបើកបរយានយន្តធុនស្រាល និងធុនធ្ងន់ដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន២១០លើក។

## ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

-បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន២លើក សេចក្តីព្រាងច្បាប់ចំនួន ១១លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៣១លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន២លើក។

## ២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភាលើសេចក្តីព្រាងច្បាប់ចំនួន១៨លើក ព្រះរាជសារចំនួន១លើក របាយការណ៍របស់រដ្ឋសភាចំនួន១លើក ការបោះឆ្នោតជ្រើសតាំងចំនួន៥លើក ការសម្រេចអំពីសុពលភាពចំនួន២លើក និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន២លើក។

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញ របស់ព្រឹទ្ធសភាលើសេចក្តីព្រាងច្បាប់ចំនួន១៨លើក របាយការណ៍របស់ព្រឹទ្ធសភាចំនួន១លើក ការប្រកាសទទួលស្គាល់ចំនួន១លើក និងការបោះឆ្នោតជ្រើសរើសចំនួន១លើក។

## ២.៥.ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

-បានរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ ដោយអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល គឺពាក់ម៉ាស លាងដៃនឹងអាកុល និងរក្សាគម្លាតសុវត្ថិភាពក្នុងពេលបំពេញការងារចំនួន៤លើក (ខេត្តស្វាយរៀងចំនួន១លើក តាកែវចំនួន១លើក កំពតចំនួន១លើក និងខេត្តកែបចំនួន១លើក) ដោយមានអ្នកចូលរួមចំនួន៦១០នាក់(ស្ត្រីចំនួន១៩៥នាក់)។

## ៣.សកម្មភាពការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ នៅក្រសួងសាធារណការ និងដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ក្នុងការងារស្តារ សាងសង់ ជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រ និងការប្រើប្រាស់ប្រេងអន្តរាគមន៍ នៅក្រសួងធនធានទឹក និងឧតុនិយម មន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ ២០១៨។

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ក្នុងការងារស្តារ សាងសង់ ជួសជុល ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ផ្លូវលំជនបទ នៅក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

### ៣.២.ការងារអធិការកិច្ចលើវិស័យរដ្ឋបាលទូទៅ

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំ ហេដ្ឋារចនាសម្ព័ន្ធ នៅតាមបណ្តាសាលាខេត្ត សាលាក្រុង ស្រុក មន្ទីរ អង្គភាពពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅខេត្តកណ្តាល បាត់ដំបង និងខេត្តកំពង់ចាម។

-របាយការណ៍ទទួលពីបណ្តាក្រសួងចំនួន៤ គឺក្រសួងការពារជាតិចំនួន១០លើក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន៦លើក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១លើក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១លើក។

-របាយការណ៍ជូនជ្រាបតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៧ គឺមន្ទីរទរពអខេត្តកែបចំនួន១៦លើក មន្ទីរទរពអខេត្តពោធិ៍សាត់ចំនួន១៥លើក មន្ទីរទរពអខេត្តកោះកុងចំនួន១៥លើក មន្ទីរទរពអខេត្តបាត់ដំបងចំនួន១៤លើក មន្ទីរទរពអខេត្តស្វាយរៀងចំនួន១៤លើក មន្ទីរទរពអខេត្តក្រចេះចំនួន១៣លើក មន្ទីរទរពអខេត្តកំពតចំនួន១៣លើក មន្ទីរទរពអខេត្តកំពង់ស្ពឺចំនួន១២លើក មន្ទីរទរពអរាជធានីភ្នំពេញចំនួន១២លើក មន្ទីរទរពអខេត្តត្បូងឃ្មុំចំនួន១១លើក មន្ទីរទរពអខេត្តកណ្តាលចំនួន១១លើក មន្ទីរទរពអខេត្តកំពង់ចាមចំនួន១០លើក មន្ទីរទរពអខេត្តរតនគិរីចំនួន១០លើក មន្ទីរទរពអខេត្តតាកែវចំនួន៩លើក មន្ទីរទរពអខេត្តកំពង់ធំចំនួន៨លើក មន្ទីរទរពអខេត្តកំពង់ឆ្នាំងចំនួន៤លើក និងមន្ទីរទរពអខេត្តព្រះសីហនុចំនួន៣លើក។

### ៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ នៅក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន និងមន្ទីររាជធានី-ខេត្តក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

### ៣.៤.ការងារតាមដានការអនុវត្តច្បាប់

-បានចុះតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍៖

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ស្ពឺ។

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តក្រចេះ។

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ឆ្នាំង។

+អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការពិនិត្យស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការកាប់ទន្រ្ទានឈូសឆាយដីព្រៃលិចទឹក នៅតំបន់បឹងទន្លេសាប ស្ថិតក្នុងខេត្តកណ្តាល កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ និងខេត្តបន្ទាយមានជ័យ។

-បានចុះតាមដានការអនុវត្តច្បាប់(មន្ទីររាជធានី-ខេត្ត)៖

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ភូមិបាល អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដាឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅខេត្តឧត្តរមានជ័យ។

+ការគ្រប់គ្រងផ្សារ និងការប្រមូលចំណូលភាស៊ី នៅផ្សាររដ្ឋចំនួន៣ គឺផ្សារអូឡាំពិក ផ្សារទួលទំពូង និងផ្សារធំថ្មី នៅរាជធានីភ្នំពេញ។

+ការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅការិយាល័យអប់រំ យុវជន និងកីឡា និងបណ្តាវិទ្យាល័យនានា ក្នុងស្រុកអង្គរបូរី និងស្រុកកោះអណ្តែត ក្នុងខេត្តតាកែវ។

+ច្បាប់ស្តីពីវិធានសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកប ដោយគ្រោះថ្នាក់ផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅតាមអង្គភាពមានសមត្ថកិច្ច ដែលឈរជើងនៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង និងការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹកតំបន់២ និងតំបន់៣ នៃដែនបឹងទន្លេសាប នៅខេត្តបាត់ដំបង។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងចូលរួមជាមួយក្រុមការងាររបស់ក្រសួង និងរដ្ឋបាលខេត្តកំពង់ធំចុះពិនិត្យ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹកនៅតំបន់៣ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ កិច្ចសន្យាភាស៊ី ចំណតរថយន្ត ចំណតទូក និងឡសត្តឃាត និងសិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី និងទឹកបរិសុទ្ធ នៅខេត្តស្វាយរៀង។

+អនុក្រឹត្យ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

+អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់អាងទន្លេរបស់រាជរដ្ឋាភិបាល នៅស្រុកដំណាក់ចង្អើរ ខេត្តកែប។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ ការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិ ចូលរួមវាស់វែង និងកាត់ឆ្វៀលដីជូនប្រជាពលរដ្ឋ ចូលរួមចុះបង្ក្រាបបទល្មើសការកាប់រានដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យមើលការឈូសឆាយ និងកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស៊ីវហ្គេច អ៊ិនវេសមេន ចូលរួមចុះបង្ក្រាបបទល្មើសឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ និងគ្រឿងចក្រ ខុសច្បាប់ ចូលរួមចុះពិនិត្យទីតាំងឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមជាមួយក្រុមការងារថ្នាក់ខេត្តចុះវាស់វែងដីសង្គមកិច្ច និងស្រង់ស្ថិតិប្រជាពលរដ្ឋ ដែលរស់នៅអាស្រ័យផលលើដីបម្រុងខេត្ត ចូលរួមចុះពិនិត្យ និងវាស់វែងដីសំណង់ជូនក្រុមហ៊ុនហីវ៉ាយសិន អាហ្គ្រីឧលឈ័រចំនួន៥,៦០២ហិកតា នៅស្រុកសេសាន-ស្រុកសៀមប៉ាង និងបានចូលរួមជាមួយក្រុមការងារចម្រុះថ្នាក់ខេត្តចុះត្រួតពិនិត្យ និងបង្ក្រាបសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ នៅខេត្តស្ទឹងត្រែង។

តាមរយៈការចុះតាមដានការអនុវត្តច្បាប់ទទួលបានលទ្ធផលដូចខាងក្រោម៖

-បានចុះតាមដានការអនុវត្តច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តឧត្តរមានជ័យ៖

+ក្រុងសំរោង នៅចំណុចភូមិដងទង ភូមិជ្រឹង ភូមិរំដួលជើងភ្នំ ភូមិស្រះព្រិច ភូមិក្រូចសាខន សង្កាត់កូនក្រៀល ក្រុងសំរោង នៅមានបទល្មើសអារឈើក្រញូងមានចំនួន៤ទៅ៥គ្រឿង ការពារដោយកំលាំងយោធា នៅតំបន់ភូមិសាស្ត្រនោះ។

+ស្រុកអន្លង់វែង សកម្មភាពប្រើប្រាស់រណារយន្តអារឈើខុសច្បាប់នៅតែមាន៦ ទៅ៧គ្រឿង កំពុងធ្វើសកម្មភាពត្រង់ចំណុចដែនព្រៃសហគមន៍ខាងត្បូងភូមិរំចេក ឃុំអន្លង់វែង រួចដឹកដោយរទេះគោទៅស្រុកវ៉ារិន និងស្រុកស្រីស្នំ ខេត្តសៀមរាប មានចំនួន៧ទៅ៨រទេះគោ ជារៀងរាល់ខែពេលយប់។

+ស្រុកបន្ទាយអំពិល សកម្មភាពប្រើប្រាស់រណារយន្តអារឈើខុសច្បាប់នៅតែមានចំនួន ៣ ទៅ៤គ្រឿងកំពុងធ្វើសកម្មភាពត្រង់ចំណុចដែនព្រៃសហគមន៍ខាងត្បូងភូមិរំចេក ឃុំបេង រួចដឹកដោយរទេះគោទៅស្រុកវ៉ារិន និងស្រុកស្រីស្នំ ខេត្តសៀមរាប មានចំនួន៤ទៅ៥រទេះគោ ជារៀងរាល់ខែពេលយប់។

+ស្រុកត្រពាំងប្រាសាទ សកម្មភាពប្រើប្រាស់រណារយន្តអារឈើខុសច្បាប់នៅតែមានចំនួន ៥ ទៅ៦គ្រឿង កំពុងធ្វើសកម្មភាពត្រង់ចំណុចដែនព្រៃសហគមន៍ខាងត្បូងភូមិរំចេក ឃុំព្រះប្រឡាយ រួចដឹកដោយរទេះគោទៅ ស្រុកវ៉ារិន និងស្រុកស្រីស្នំ ខេត្តសៀមរាប មានចំនួន៦ទៅ៨រទេះគោ ជារៀងរាល់ខែពេលយប់។

+ស្រុកចុងកាល់ សកម្មភាពប្រើប្រាស់រណារយន្តអារឈើខុសច្បាប់នៅតែមានចំនួន ៤ ទៅ ៥ គ្រឿង កំពុងធ្វើ សកម្មភាពត្រង់ចំណុចដែនព្រៃសហគមន៍ខាងត្បូងភូមិរំចេក ឃុំចុងកាល់ រួចដឹកដោយរទេះគោទៅស្រុកស្រីស្នំ ខេត្តសៀមរាប មានចំនួន៦ទៅ៧រទេះគោ ជារៀងរាល់ខែពេលយប់។

+សកម្មភាពដឹកជញ្ជូនផល-អនុផលព្រៃឈើ នៅក្នុងខែមេសា នៅតែមានដឹកយ៉ាងផុសផុល មានឡាន ម៉ាកយីឌុបមានចំនួន៣ទៅ៤គ្រឿង ឆ្ពោះទៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ជារៀងរាល់ខែពេលយប់។

+ក្រុងសំរោង ប្រជាពលរដ្ឋមានការប្រើប្រាស់គ្រឿងញៀនមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះមានសង្កាត់សំរោង សង្កាត់បន្សាយរាក់ សង្កាត់អូរស្មាច់ សង្កាត់បុស្សស្បូវ និងសង្កាត់កូនក្រៀល។ ចំនួនអ្នកចែកចាយ និងប្រើប្រាស់គ្រឿងញៀនកើនឡើង ភាគច្រើនក្រុមយុវជន និងអ្នករកស៊ីកាប់ឈើ និងជាពលករមកពីប្រទេសថៃ ចាប់ពីអាយុ១៥ឆ្នាំឡើង មានច្រើនគួរឱ្យព្រួយបារម្ភ។

+ស្រុកអន្លង់វែង ប្រជាពលរដ្ឋមានការប្រើប្រាស់គ្រឿងញៀនមានការកើនឡើង គួរឱ្យកត់សម្គាល់ ក្នុងនោះមានឃុំត្រពាំងប្រិយ៍ ឃុំអន្លង់វែង ឃុំថ្លាត ឃុំលំទង និងឃុំត្រពាំងតាវ។ ចំនួនអ្នកចែកចាយ និងប្រើប្រាស់គ្រឿងញៀនកើនឡើង ភាគច្រើនក្រុមយុវជន និងអ្នករកស៊ីកាប់ឈើ និងជាពលករមកពីប្រទេសថៃ ចាប់ពីអាយុ ១៥ឆ្នាំឡើង មានច្រើនគួរឱ្យព្រួយបារម្ភ។

+ស្រុកបន្ទាយអំពិល ប្រជាពលរដ្ឋមានការប្រើប្រាស់គ្រឿងញៀនមានការកើនឡើង គួរឱ្យកត់សម្គាល់ ក្នុងនោះមានឃុំគោកមន ឃុំគោកខ្ពស់ ឃុំបេង និងឃុំអំពិល។ ចំនួនអ្នកចែកចាយ និងប្រើប្រាស់គ្រឿងញៀនកើនឡើង ភាគច្រើនក្រុមយុវជន និងអ្នករកស៊ីកាប់ឈើ និងជាពលករមកពីប្រទេសថៃ ចាប់ពីអាយុ១៥ឆ្នាំឡើង មានច្រើនគួរឱ្យព្រួយបារម្ភ។

+ស្រុកត្រពាំងប្រាសាទ ប្រជាពលរដ្ឋមានការប្រើប្រាស់គ្រឿងញៀនមានការកើនឡើង គួរឱ្យកត់សម្គាល់ ក្នុងនោះមានឃុំបាក់អន្លង់ ឃុំអូរស្វាយ ឃុំផ្អាវ ឃុំព្រះប្រឡាយ ឃុំត្រពាំងប្រាសាទ និងឃុំទំនប់ដាច់។ ចំនួនអ្នកចែកចាយ និងប្រើប្រាស់គ្រឿងញៀនកើនឡើង ភាគច្រើនក្រុមយុវជន និងអ្នករកស៊ីកាប់ឈើ និងជាពលករមកពីប្រទេសថៃ ចាប់ពីអាយុ១៥ឆ្នាំឡើង មានច្រើនគួរឱ្យព្រួយបារម្ភ។

+ស្រុកចុងកាល់ ប្រជាពលរដ្ឋមានការប្រើប្រាស់គ្រឿងញៀនមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះមានឃុំជើងទៀន ឃុំចុងកាល់ ឃុំក្រសាំង និងឃុំពង្រ។ ចំនួនអ្នកចែកចាយ និងប្រើប្រាស់គ្រឿងញៀនកើនឡើងភាគច្រើនក្រុមយុវជន និងអ្នករកស៊ីកាប់ឈើ និងជាពលករមកពីប្រទេសថៃ ចាប់ពីអាយុ១៥ឆ្នាំឡើង មានច្រើនគួរឱ្យព្រួយបារម្ភណ៍។

-បានចុះតាមដានការអនុវត្តច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងចូលរួមជាមួយក្រុមការងាររបស់ក្រសួង និងរដ្ឋបាលខេត្តកំពង់ធំចុះពិនិត្យ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹក នៅតំបន់៣ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ធំ៖

+ចូលរួមកិច្ចសហការល្អជាមួយរដ្ឋបាលស្រុក និងសង្កាត់រដ្ឋបាលជលផល។

+ជំនាញរដ្ឋបាលជលផលបានធ្វើការអប់រំផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធជូនដល់បងប្អូនប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋាន។

+មានការបង្ក្រាបបទល្មើសជលផល ដោយបានដុតបំផ្លាញវត្ថុតាងមួយចំនួន។

+មានកិច្ចសហការល្អពីរដ្ឋបាលស្រុក ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។

+មានការបង្ក្រាបបទល្មើសព្រៃឈើ ដោយបានឃាត់ខ្លួន និងបានបញ្ជូនវត្ថុតាងទៅតុលាការ។

+ម្ចាស់រោងសន្និធិមានលិខិតអនុញ្ញាតធ្វើអាជីវកម្មបានត្រឹមត្រូវតាមច្បាប់កំណត់។

+ជំនាញរដ្ឋបាលព្រៃឈើបានធ្វើការអប់រំផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធជូនដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

+ជំនាញរដ្ឋបាលព្រៃឈើ បានចុះអប់រំណែនាំដល់ម្ចាស់រោងសន្និធិ ទិញ លក់ ចែកចាយផល-អនុផលព្រៃឈើ មិនឱ្យទិញឈើណាដែលមិនស្របច្បាប់ក្រៅពីក្រុមហ៊ុនឡើយ។

+ជំនាញរដ្ឋបាលព្រៃឈើតែងតែចុះមកកាត់ស្តុក នៅតាមបណ្តារោងសន្និធិ ទិញ លក់ ចែកចាយផល-អនុផលព្រៃឈើ ជាប្រចាំ។

+បានចុះទៅវាស់វែង និងពិនិត្យការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹកនៅតំបន់៣ ស្ថិតនៅក្នុងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ដឹកនាំដោយឯកឧត្តម សុក ហៃ អភិបាលរងខេត្តកំពង់ធំ និងជាប្រធានក្រុមការងាររដ្ឋបាលខេត្តកំពង់ធំ។

+បានចុះទៅពិនិត្យការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹកនៅអាង២,០០០ ក្នុងតំបន់៣ ស្ថិតក្នុងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន និងឃុំកំពង់គោ ស្រុកកំពង់ស្វាយ ដឹកនាំដោយ ឯកឧត្តម សុក ហៃ អភិបាលរងខេត្តកំពង់ធំ។

+បានចូលរួមលើកប៉ាណូហាមចូលកាប់ព្រៃ និងទន្ទ្រានដីព្រៃលិចទឹក ក្នុងតំបន់៣ ក្នុងទឹកដីក្រុងស្ទឹងសែន ដឹកនាំដោយឯកឧត្តម ឡៅ ទិព្វសីហា រដ្ឋលេខាធិការ និងប្រធានក្រុមការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តកំពង់ធំ។

+បានចូលរួមលើកប៉ាណូហាមចូលកាប់ព្រៃ និងទន្ទ្រានដីព្រៃលិចទឹកក្នុងតំបន់៣ និងពិនិត្យទីតាំងក្នុងតំបន់៣ ដែលត្រូវបានទន្ទ្រានយក ក្នុងភូមិខ្សាច់ជីរស់ និងតំបន់បត់ត្រង់ នៅឃុំកំពង់គោ ស្រុកកំពង់ស្វាយ ដឹកនាំដោយ ឯកឧត្តម សុក ហៃ អភិបាលរងខេត្តកំពង់ធំ។

+បានចូលរួមលើកប៉ាណូហាមចូលកាប់ព្រៃ និងទន្ទ្រានដីព្រៃលិចទឹកក្នុងតំបន់៣ និងពិនិត្យទីតាំងតំបន់ដៃអាជ្រូក និងប្រឡាយព្រះស្នែង ស្ថិតក្នុងតំបន់៣ ក្នុងស្រុកកំពង់ស្វាយ ដែលត្រូវបានទន្ទ្រានយក ដឹកនាំដោយឯកឧត្តម ឡៅ ទិព្វសីហា រដ្ឋលេខាធិការ និងប្រធានក្រុមការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះខេត្តកំពង់ធំ និងឯកឧត្តម សុក ហៃ អភិបាលរងខេត្តកំពង់ធំ។

+បានចូលរួមដាំកូនឈើនៅតាមបន្ទាត់ព្រៃលិចទឹក តំបន់៣ ស្ថិតក្នុងភូមិសាស្ត្រសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ដឹកនាំដោយឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ។

+បានចូលរួមប្រជុំ ពិនិត្យនិងផ្ទៀងផ្ទាត់ដីតំបន់២ ស្នើសុំកាត់មកតំបន់១ ស្ថិតក្នុងឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

-បានចុះតាមដានការកាប់ទន្ទ្រានឈូសឆាយដីព្រៃលិចទឹកតំបន់២ និងតំបន់៣ នៃដែនបឹងទន្លេសាប នៅស្រុកចំនួន៤ គឺស្រុកមោងឫស្សី ស្រុកសង្កែ ស្រុកឯកភ្នំ និងស្រុកថ្មគោល ក្នុងខេត្តបាត់ដំបង៖

+ស្រុកមោងឫស្សី ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ក្រុមការងារមន្ទីរបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះទៅធ្វើការដកហូតបានរណាយន្តមួយគ្រឿង ដោយជនល្មើសមានគ្នាចំនួន៥នាក់ បើកគោយន្តកន្ត្រៃចំនួន៣គ្រឿង ទៅកាប់ និងអារឈើក្នុងតំបន់៣ នៅចំណុចអូរតាចាន់។

+ស្រុកថ្មគោលកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារមន្ទីរបានសហការជាមួយអាជ្ញាធរចម្រុះ ធ្វើការដកហូតបានអេសស្កាវ៉ាទ័រចំនួនមួយគ្រឿង ត្រាក់ទ័រមួយគ្រឿង និងប្រេងម៉ាស៊ូតចំនួន២៦កាន។

+ស្រុកឯកភ្នំក្នុងភូមិព្រៃចាស់ ក្រុមការងារមន្ទីរបានចុះអង្កេតស្រាវជ្រាវជនល្មើសដែលជាមេក្លោងចំនួន៣នាក់ ដែលបានបោះទីតាំងក្នុងការកាប់ឈូសឆាយយកដីព្រៃលិចទឹក ដើម្បីធ្វើកម្មសិទ្ធិ។

+បានចុះក្តាប់សភាពការណ៍ដីព្រៃលិចទឹកដែនបឹងទន្លេសាបតំបន់២ តំបន់៣ ក្នុងឃុំតាលាស់ ស្រុកមោងឫស្សី នៅថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០២១ បានឃើញថាមានការទន្ទ្រានដីព្រៃ ដើម្បីធ្វើស្រែកាន់តែកើនឡើងជាងមុន និងនៅតែបន្តទន្ទ្រានថែមទៀត។

+បានចុះក្តាប់សភាពការណ៍នៅឃុំកំពង់ព្រៀង ពេលក្រុមការងារចុះទៅដល់ ក៏ប្រទះឃើញត្រាទ័រជាច្រើនគ្រឿង កំពុងឈូសឆាយដីព្រៃនៅចំណុចនិយាមការលេខX៣៣០០៩២.៤ Y១៤៣៥៩១៥.១ ក្នុងតំបន់៣ ជនល្មើសឈ្មោះ ម៉ក់ ប៊ុនថុល ក្រុមការងារក៏បានធ្វើការរាយការណ៍ទៅសមត្ថកិច្ច និងកម្លាំងជំនាញមូលដ្ឋានភ្លាម តែមិនមានកម្លាំងសមត្ថកិច្ចណាចុះមកទេ ហើយត្រូវជនល្មើសរត់គេចខ្លួនបាត់អស់។

+ក្រុមការងារមន្ទីរបានចុះទៅក្តាប់សភាពការណ៍ដីព្រៃលិចទឹក ដែនបឹងទន្លេសាប តំបន់២ តំបន់៣ ក្នុងឃុំតាលាស់ ហើយក្រុមការងារក៏បានប្រទះឃើញត្រាទ័រចំនួនមួយគ្រឿង មកភ្ជួរដីស្រែក្នុងដីតំបន់៣ហើយខូច ក្រុមការងារបានចាត់ឱ្យកងកម្លាំង និងក្រុមល្បាតរបស់សហគមន៍នេសាទតាលាស់ធ្វើការដកហូតត្រាក់ទ័រនោះយកមកទុកនៅសាលាឃុំតាលាស់។

+បានចុះក្តាប់សភាពការណ៍នៅឃុំកំពង់ព្រៀង ពេលក្រុមការងារចុះទៅដល់បានពិនិត្យឃើញថា មានការកាប់ទន្ទ្រានថ្មីៗបន្ថែមទៀត និងបានប្រទះឃើញប្រជាពលរដ្ឋកំពុងវាស់ដីព្រៃ ក្នុងតំបន់៣ ចែកគ្នាម្នាក់២ហិកតា ក្រុមការងារបានសាកសួរ ហើយអប់រំឱ្យបញ្ឈប់ការទន្ទ្រានទៀត។

-បានចុះតាមដានអនុក្រឹត្យ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ មន្ទីរបានសហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងវាយតម្លៃការចូលកាន់កាប់ដី ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង(ទន្លេសាប) ក្នុងភូមិសាស្ត្រស្រុកបរិបូណ៌លើផ្ទៃដីទំហំ២,៦៤៥.៨៨ហិកតា ករណីនេះបានរកឃើញថា មានដីអាស្រ័យផល

និងដីលំនៅដ្ឋានចាស់ ដែលប្រជាពលរដ្ឋកំពុងរស់នៅទំហំប្រមាណជាង៤០០ហិកតា ក្នុងនោះមានកន្លែងខ្លះប្រជាពលរដ្ឋមួយចំនួនតូចបានកាប់រុករាន និងអាស្រ័យផល ព្រមទាំងធ្វើរបងហ៊ុំព័ទ្ធ នៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង(ទន្លេសាប) ដែលទើបនឹងកាប់រុករានថ្មីៗ និងកន្លែងខ្លះទៀតប្រជាពលរដ្ឋធ្លាប់អាស្រ័យយូរយារណាស់មកហើយ។

-បានចុះតាមដានការអនុវត្តច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ ការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិ ចូលរួមវាស់វែង និងកាត់ឆ្វៀលដីជូនប្រជាពលរដ្ឋ ចូលរួមចុះបង្ក្រាបបទល្មើសការកាប់រានដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យមើលការឈូសឆាយ និងកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស៊ីវហ្គេច អ៊ិនវេសមេន ចូលរួមចុះបង្ក្រាបបទល្មើសឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ និងគ្រឿងចក្រខុសច្បាប់ ចូលរួមចុះពិនិត្យទីតាំងឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមជាមួយក្រុមការងារថ្នាក់ខេត្តចុះវាស់វែងដីសង្គមកិច្ច និងស្រង់ស្ថិតិប្រជាពលរដ្ឋ ដែលរស់នៅអាស្រ័យផលលើដីបម្រុងខេត្ត ចូលរួមចុះពិនិត្យ និងវាស់វែងដីសំណង់ជូនក្រុមហ៊ុនហ៊ីវ៉ាយសិន អាហ្គ្រីខលឈ័រចំនួន ៥,៦០២ហិកតា នៅស្រុកសេសាន ស្រុកសៀមប៉ាង និងបានចូលរួមជាមួយក្រុមការងារចម្រុះថ្នាក់ខេត្តចុះត្រួតពិនិត្យ និងបង្ក្រាបសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ នៅខេត្តស្ទឹងត្រែង៖

+ក្រុមការងារបានពិនិត្យឃើញថា មានការកាប់រានដីព្រៃខុសច្បាប់ជាច្រើនហិកតា និងកាប់ឈើអាស្រ័យផល នៅឃុំកោះស្នែង ឃុំស្រះឫស្សី ឃុំចំការលើ ឃុំអន្លង់ភេ ឃុំសំអាង និងឃុំអូររ៉េ ស្រុកថាឡាបរិវ៉ាត់។

+ម្ចាស់អាជីវកម្មជីកយកអាចម៍ដីចល័តឈ្មោះ ឆោម ភារី បានអនុវត្តអាជីវកម្មរបស់ខ្លួនទាំងមិនទាន់មានអាជ្ញាប័ណ្ណត្រឹមត្រូវ(អាជ្ញាប័ណ្ណកំពុងស្នើសុំនៅឡើយ) នៅភូមិអន្លង់ជ្រៃ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់។

+បានចុះស្រង់ និងបំពេញសាលាកប័ត្រព័ត៌មានដីធ្លី ជូនប្រជាពលរដ្ឋត្រង់ចំណុចអូរសេរចំនួន ៧៣គ្រួសារ ស្មើនឹង១៤៦ក្បាលដី (ដីលំនៅដ្ឋាន៧៣ក្បាលដី ដីកសិកម្ម៧៣ក្បាលដី) នៅភូមិភ្លុក ឃុំភ្លុក ស្រុកសេសាន។

+បានចុះស្រង់ និងបំពេញសាលាកប័ត្រព័ត៌មានដីធ្លី ជូនប្រជាពលរដ្ឋត្រង់ចំណុចអូរសេរចំនួន ៤៥៩គ្រួសារ ស្មើនឹង៦៨៣ក្បាលដី(ដីលំនៅដ្ឋានចំនួន៧៣ក្បាលដី ដីកសិកម្មចំនួន៦១០ ក្បាលដី) នៅភូមិភ្លុក ឃុំភ្លុក ស្រុកសេសាន។

+បានឃាត់ខ្លួនមនុស្សចំនួន២នាក់ ដែលជាអ្នកស៊ីឈ្នួលកាប់ព្រៃអោយឈ្មោះ ឈឿន គង់ នៅភូមិក្រឡាពុះ ឃុំតាឡាត ស្រុកសេសាន និងបានបញ្ជូនខ្លួនទៅមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង។

+ក្រុមការងារបានពិនិត្យឃើញថា ប្រជាពលរដ្ឋបានកាប់ទន្ទ្រានដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស៊ីវហ្គេច អិនវេសមេន យកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនពិតប្រាកដមែន នៅឃុំក្បាលរមាស ស្រុកសេសាន។

+ក្រុមការងារបានពិនិត្យឃើញថា មានសកម្មភាពកំពុង កាប់រាន ឈូស ឆាយ ដី ព្រៃ ស្រោង ក្នុងដែនការពាររបស់រដ្ឋបាលព្រៃឈើទំហំប្រមាណ១៨ហិកតា ដែលកាប់រាន និងអាស្រ័យផល និង

បានធ្វើកំណត់ហេតុជាមួយម្ចាស់ដីឈ្មោះ ធឹម ឌីណា និងម្ចាស់គ្រឿងចក្រ នៅចំណុចអូជ័រទឹក ឃុំចំការលើ ស្រុកថាឡាបរីវ៉ាត់។

⁺ក្រុមការងារបានពិនិត្យឃើញថា មានសកម្មភាពកំពុងកាប់រានឈូសឆាយដីព្រៃស្រោងក្នុងដែនការពាររបស់រដ្ឋបាលព្រៃឈើទំហំប្រមាណ១០០ហិកតា ដែលកាប់រាន និងអាស្រ័យផល នៅភូមិរំដេង ឃុំចំការលើ ស្រុកថាឡាបរីវ៉ាត់។

⁺ក្រុមការងារបានពិនិត្យឃើញថា ក្រុមហ៊ុនThink Biotech បានកាប់ទន្ទ្រានដីយកមកធ្វើជាកម្មសិទ្ធិយ៉ាងអនាធិបតេយ្យ នៅភូមិអូរឡង់ ឃុំសៀមបូក។

⁺ក្រុមការងារបានពិនិត្យឃើញថា មានសកម្មភាពកំពុងកាប់រានឈូសឆាយដីព្រៃខុសច្បាប់ដោយប្រើប្រាស់គ្រឿងចក្រយកមកធ្វើជាកម្មសិទ្ធិ និងអាស្រ័យផល នៅចំណុចភូមិក្រឡាពុះ ឃុំតាឡាត ស្រុកសេសាន។

⁺ក្រុមការងារបានឃាត់ និងដកហូតត្រាក់ទ័រម៉ាកគូប៉ូតា ពណ៌ក្រហម កំលាំងសេះ(៨៥៤០) ចំនួន១គ្រឿង ដែលបានឈូសឆាយដីព្រៃខុសច្បាប់ នៅត្រង់ចំណុចUTM595228-1499404 ភូមិអន្លង់ស្វាយ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរីវ៉ាត់។

⁺ក្រុមការងារបានបង្ក្រាបសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ រួមមានសម្ភារៈដូចជាតាបឈូសចំនួន ១គ្រឿង តាបជៀកចំនួន១គ្រឿង ម៉ាស៊ីនភ្លើងចំនួន១គ្រឿង គ្រោងទ្វារចំនួន៤១វង់ និងឈើអារប្រភេទលេខ១ចំនួន ៩០៥សន្លឹកស្មើនឹងចំនួន២០ម៉ែត្រគូប១៧២ នៅឃុំស្រែគរ ស្រុកសេសាន។

⁺ក្រុមការងារបានបំពេញសម្រង់អត្តសញ្ញាណម្ចាស់ដីបានចំនួន៥៦សម្រង់ និងបានចុះពិនិត្យផ្ទៀងផ្ទាត់ និងវាស់វែងបានចំនួន៥៦ក្បាលដី នៅចំណុចផ្លូវចូលស្ពោ ភូមិគីឡូ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង។

-បានចុះតាមដានការអនុវត្តច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ កិច្ចសន្យាភាស៊ី ចំណតរថយន្ត ចំណតទូក និងឡសត្តឃាត និងសិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី និងទឹកបរិសុទ្ធ នៅខេត្តស្វាយរៀង៖

⁺ក្រុមការងារបានធ្វើកំណត់ហេតុត្រួតពិនិត្យពីម្ចាស់-តំណាងភាស៊ី និងឡសត្តឃាតក្នុងមូលដ្ឋានទាំង៦ស្រុក-ក្រុងក្នុងខេត្តរួមមាន៖ ជួបផ្ទាល់ជាមួយម្ចាស់-តំណាងភាស៊ីផ្សារចំនួន២នាក់ ស្រីចំនួន១នាក់ (ស្រុករមាសហែកចំនួន១នាក់ និងស្រុកស្វាយទាបចំនួន១នាក់) និងម្ចាស់-តំណាងឡសត្តឃាតចំនួន៤នាក់ ស្រីអត់មាន(ស្រុកស្វាយជ្រំចំនួន១នាក់ ស្រុកស្វាយទាបចំនួន១នាក់ ក្រុងបាវិត ចំនួន១នាក់ និងក្រុងស្វាយរៀងចំនួន១នាក់)។

⁺ក្រុមការងារបានធ្វើកំណត់ហេតុត្រួតពិនិត្យពីម្ចាស់អាជីវករប្រកបអាជីវកម្មបង្កើតរោងសន្និធិលក់ចែកចាយផល-អនុផលព្រៃឈើ ក្នុងមូលដ្ឋានទាំង៥ស្រុក សរុបបាន១២កន្លែង សុំបន្តសុពលភាពថ្មី១២កន្លែងរួមមាន៖ ស្រុកស្វាយជ្រំចំនួន៤កន្លែង ស្រុករំដួលចំនួន២កន្លែង ស្រុកស្វាយទាបចំនួន១កន្លែង ស្រុកកំពង់រោទិ៍ ចំនួន១កន្លែង និងស្រុករមាសហែកចំនួន៤កន្លែង។

⁺ឈើអារប្រភេទលេខ២ដឹកជញ្ជូនមកកាន់ដេប៉ូលក់ឈើក្នុងខេត្តស្វាយរៀង សុទ្ធតែមានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយនាយផ្នែកខណ្ឌរដ្ឋបាលព្រៃឈើ រមាសហែក កោះញែក សណ្តាន់ ឆែប ។ល។

+ចំពោះបរិមាណឈើអារដឹកចូលមកដេប៉ូម្តងៗ ពីចំនួន១០ម៉ែត្រគូប-១៧ម៉ែត្រគូបប៉ុណ្ណោះ តាមប្រភេទ ឡានតូច ឬធំរបស់ក្រុមហ៊ុន ឬសាខាព្រៃសម្បទាន។

+សៀវភៅតាមដានកត់ត្រាឈើចេញ- ចូលរបស់ដេប៉ូលក់ឈើស្ទើរគ្រប់ដេប៉ូពុំបានកត់ត្រាត្រឹមត្រូវតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានរុក្ខាប្រមាញ់នៅឡើយទេ។

+ក្រុមការងារបានជួបជាមួយម្ចាស់អាជីវករសរុប១២នាក់ ប្រុស៩នាក់ ស្រី៣នាក់មានលិខិតអនុញ្ញាតច្បាប់ទាំងអស់ មានរោងចក្រទឹកកកចំនួន៦នាក់ អេតចាយចំនួន៥នាក់ និងក្រុមហ៊ុនប្រមូលសម្រាមចំនួន១នាក់ ក្នុងនោះក្រុងស្វាយរៀងចំនួន៤នាក់ ក្រុងបាវិតចំនួន៤នាក់ ស្រុករំដួលចំនួន ២នាក់ ស្រុកស្វាយជ្រំចំនួន១នាក់ និងស្រុករមាសហែក ចំនួន១នាក់។

+សិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី ទឹកបរិសុទ្ធ នៅស្រុករមាសហែកបានជួបម្ចាស់អាជីវកម្មចំនួន ៥កន្លែងក្នុងនោះពុំទាន់មានលិខិតអនុញ្ញាតចំនួន២កន្លែង មានលិខិតអនុញ្ញាតចំនួន២កន្លែង និងសុំផ្អាកចំនួន១កន្លែង។

+បានចុះត្រួតពិនិត្យទីតាំងដែលជីកកកាយយកអាចម៍ដីចំនួន៤កន្លែង ករណីនេះបានពិនិត្យឃើញថា៖ក្រុមហ៊ុនទាំងនោះបានគោរពតាមច្បាប់កំណត់ការជីកកកាយយកអាចម៍ដីមិនមានលើស ពីជម្រៅនៃច្បាប់ ដែលបានកំណត់ឱ្យជីកជម្រៅ៥ម៉ែត្រ។

## ៣.៥.ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន១១៨ បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៩បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៨៩ បណ្តឹង) ៖

-ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន ៧បណ្តឹង (ឆ្នាំ២០២១ ចំនួន ៧ បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី-ខេត្ត ចំនួន ៨០បណ្តឹង (ឆ្នាំ២០២១ ចំនួន ៨០ បណ្តឹង)។

-ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន ១៨ បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៣បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៥បណ្តឹង ក្នុងនោះឆ្នាំ២០២១ ចំនួន ១៨ បណ្តឹង)។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការ ចំនួន ១បណ្តឹង (ឆ្នាំ២០២១ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំដកវិញចំនួន ៣បណ្តឹង (មន្ទីររាជធានី-ខេត្តចំនួន៣បណ្តឹង គឺឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងបានបោះបង់ចោលចំនួន ២បណ្តឹង (មន្ទីររាជធានី-ខេត្ត ចំនួន ២ បណ្តឹង គឺឆ្នាំ២០២១ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលបានធ្វើរបាយការណ៍ គោរពជូនឯកឧត្តមអភិបាល នៃគណៈអភិបាល ខេត្តកំពង់ស្ពឺពិនិត្យសម្រេច ចំនួន ៤បណ្តឹង (មន្ទីររាជធានី-ខេត្តចំនួន៤បណ្តឹង គឺឆ្នាំ២០២១ ចំនួន ៤ បណ្តឹង)។

-ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួងចំនួន៤បណ្តឹង (ឆ្នាំ២០២០ ចំនួន ៣បណ្តឹង ឆ្នាំ២០២១ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន៤បណ្តឹង (ឆ្នាំ២០២០ ចំនួន ១បណ្តឹង ឆ្នាំ ២០២១ ចំនួន៣បណ្តឹង)។

-ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន ២៤ បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន ១២ បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១២បណ្តឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៨បណ្តឹង ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន១៤បណ្តឹង)។

-ពាក្យបណ្តឹងបានទទួលការឆ្លើយតបចំនួន២បណ្តឹង(ឆ្នាំ២០២០ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយចំនួន៤បណ្តឹង (ឆ្នាំ២០១៦ ចំនួន ១បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង)។

-ពាក្យបណ្តឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន៥បណ្តឹង (ឆ្នាំ២០១៦ ចំនួន ១បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹងបានបញ្ចប់ ការដោះស្រាយចំនួន៦៣បណ្តឹង (អគ្គនាយកដ្ឋាន អធិការកិច្ច ចំនួន ២០បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៤៣បណ្តឹង ក្នុងនោះឆ្នាំ២០១៤ ចំនួន២បណ្តឹង ឆ្នាំ ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៧ ចំនួន២បណ្តឹង ឆ្នាំ២០១៨ ចំនួន៣បណ្តឹង ឆ្នាំ២០១៩ ចំនួន៨ បណ្តឹង ឆ្នាំ២០២០ ចំនួន១៦បណ្តឹង ឆ្នាំ២០២១ ចំនួន៣១បណ្តឹង) រួមមាន៖

១.ឈ្មោះ មុំ ឡាង នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី ប្តឹងឈ្មោះ ទូច វុត្ថា និងប្រពន្ធឈ្មោះ សៀង រ៉ាវី បានរំលោភយកដីរបស់គាត់ចំនួន២កន្លែង ស្ថិតនៅភូមិ អូរស្ពាន ឃុំស្ពាន មានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី។

២.ឈ្មោះ ទូច វុត្ថា និងប្រពន្ធឈ្មោះ សៀង រ៉ាវី ប្តឹងពីឈ្មោះ ដៀប សាម៉ន និងឈ្មោះ មុំ ឡាង បានសូកប៉ាន់មន្ត្រី ដើម្បីបំភាន់ការពិតធ្វើអោយប៉ះពាល់ដល់កិត្តិយសមន្ត្រីរាជការកងកំលាំងប្រដាប់អាវុធ ព្រមទាំងគ្រួសាររបស់ពួកគាត់ ពាក់ព័ន្ធករណីទំនាស់ដី នៅភូមិអូរស្ពាន ឃុំស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

៣.ពាក្យស្នើសុំអន្តរាគមន៍ឈ្មោះ JIN XIAOZHONG ប្រធានគ្រប់គ្រងគម្រោងក្រុមហ៊ុន CCCC Third Harbor Engineering Co...Ldt តំណាងក្រុមហ៊ុន CCCC Third Harbor Engineering Co...Ldt (អ្នកទទួលម៉ៅការសំណង់ សាងសង់អគារផ្សារសិនជូវឆ្លៅហ្សា) ករណីក្រុមហ៊ុន BRANCH OF FUJIANLONG ENGINEERING CONSULTING Co.LTD (អ្នកដាក់ឱ្យម៉ៅការសំណង់)មិនព្រមទូទាត់ថ្លៃសាងសង់អគារ និងការខូចខាត។

៤.ឈ្មោះ ព្រាប សុវត្ថិ និងភរិយាឈ្មោះ ឡុង ស្រីមុំ ស្នើសុំជួយអន្តរាគមន៍ករណីឈ្មោះ យឹម លុច្ស ជាសមាជិកក្រុមប្រឹក្សាខេត្តមណ្ឌលគិរី ប្រើអំណាចរំលោភបំពានយកដីកម្មសិទ្ធិរបស់គាត់ ទំហំ ១៥ ហិកតា ៦៣អា៤សង់ទីអា ស្ថិតនៅភូមិពូទ្រូលើ ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

៥.ឈ្មោះ សុខ អឿន ស្នើសុំអន្តរាគមន៍ដើម្បីបានគ្រប់គ្រងដីទំហំ ១,៥៣២ម៉ែត្រការ៉េ នៅភូមិ ពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៦.ពាក្យសុំអន្តរាគមន៍ឈ្មោះ សុខ សាន្ត ស្នើសុំមកក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជួយអង្កេតស្រាវជ្រាវឱ្យបានឆាប់រហ័សករណីបណ្តឹងរបស់ឈ្មោះ សុខ អឿន ទាមទារ កាន់ កាប់ដីទំហំ១,៥៣២ម៉ែត្រការ៉េ ស្ថិតនៅភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរមិនអាចឱ្យគាត់ ធ្វើប័ណ្ណកម្មសិទ្ធិស្របច្បាប់បាន។

៧.ពាក្យសុំអន្តរាគមន៍របស់លោក ប៊ុត កែវកុលរ័ត្ន មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ សុខ សាន្ត និងឈ្មោះ សម វង ស្នើសុំមកក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជួយពន្លឿននីតិវិធីដោះស្រាយ បណ្តឹង របស់លោក សុខ អឿន។

៨.ឈ្មោះ ឱញ សីនហា ឈ្មោះ ង្វៀន អាញ់យុង ឈ្មោះ ង្វៀន អាញ់តួន សញ្ជាតិវៀតណាម ជាអ្នកវិនិយោគ ដំណាំកៅស៊ូ នៅចំណុចគីឡូម៉ែត្រ១១៧ ផ្លូវជាតិលេខ៧៨ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ ស្នើសុំជួយរកយុត្តិធម៌ ករណីឈ្មោះ សូ ណារ៉េន និងឈ្មោះ ឆាយ ទីណា ប្តឹងពួកគាត់ខាងលើថា បានបោកប្រាស់ ប្រើប្រាស់អាវុធជាតិផ្ទុះ និងគ្រាប់បែកដៃខុសច្បាប់។

៩.ពាក្យសុំអន្តរាគមន៍ឈ្មោះ មាន នី ឈ្មោះ តែ ពិសី ឈ្មោះ ហេង គង់ ឈ្មោះ សួង សារ៉ា និងឈ្មោះ អ៊ុំ ណាំ ប្តឹងឈ្មោះ ស សឹង ជាយោធាសឹករងខេត្តព្រះសីហនុ និងឈ្មោះ ហេង សុខា ត្រូវជាប្រពន្ធឧកញ៉ា អ៊ឹង ប៊ុនហ៊ូវ ដែលបានប្រើកម្លាំងចម្រុះប្រដាប់អាវុធ និងយកគ្រឿងចក្រមកឈូសឆាយបំផ្លាញផលដំណាំ លំនៅដ្ឋានរបស់ពួកគាត់ និងរំលោភយកដីទំហំ៨៣ហិកតា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

១០.ឈ្មោះ តាក សឿន ឈ្មោះ ផ្លុង តុង ឈ្មោះ សាន សុង និងឈ្មោះ អ៊ុក ទុយ តំណាងប្រជាពលរដ្ឋ ចំនួន១៣២គ្រួសារ នៅភូមិចំបក់ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្តឹងឈ្មោះ ស៊ឹម កន ជំទប់ទី១ឃុំត្រពាំងធំ និងបក្ខពួក បានឃុបឃិតគ្នារំលោភយកដីរបស់ពួកគាត់ទំហំ២០០ហិកតា ស្ថិតនៅភូមិថ្លាត ឃុំខ្វាស់ ស្រុកសូទ្រនិគម និងភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

១១.លោក ម៉ៅ ឡុង ជាស្នងការរងភស្តុភារ និងហិរញ្ញវត្ថុនៃបញ្ជាការដ្ឋានអង្គរក្សប្រចាំសមរភូមិទិសទី១ ប្រាសាទព្រះវិហារ ប្តឹងឈ្មោះ ជា ហៃ (មេធាវី) និងបក្ខពួក បានរំលោភយកដីរបស់គាត់ទំហំ ៥ ហិកតា ស្ថិតនៅភូមិ៥ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

១២. ឈ្មោះ អួន ឆេងលី និងភរិយា ឈ្មោះ អ៊ូ សាវ៉ន្តី នៅភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ប្តឹងទាមទារកម្មសិទ្ធិស្របច្បាប់លើដីទំហំ៨៤២.៨៥ម៉ែត្រការ៉េ ទៅតាមផែនទីក្បាលដីដែលមានលេខកូដ០៤០៣០៣០២ ដែលមានកំណត់ក្នុងឧបសម្ព័ន្ធ៣.៤ ខ្នាត១/៣៩៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

១៣.ឈ្មោះ យ៉ែម ជា និងប្រពន្ធឈ្មោះ ជាវ សេដ្ឋា នៅភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ប្តឹងទាមទារកម្មសិទ្ធិស្របច្បាប់លើដីទំហំ៤,៥៨៦.៤៣ម៉ែត្រការ៉េ ទៅតាមផែនទីក្បាលដីដែលមានលេខកូដ០៤០៣០៣០២ ដែលមានកំណត់ក្នុងឧបសម្ព័ន្ធ៣.៤ ខ្នាត១/៥០០ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

១៤.ឈ្មោះ ហែម ធិន ឈ្មោះ ហែម ឡេង ឈ្មោះ គឹម ភឿន និងឈ្មោះ គង់ ឡុញ តំណាងប្រជាពលរដ្ឋ ចំនួន២១គ្រួសារ ស្នើសុំជួយអន្តរាគមន៍ទៅអាជ្ញាធរខេត្តក្រចេះ ដែលកំពុងរឹបអូសយកដី

របស់ពួកគាត់ទំហំ១១៦ហិកតា ដោយបំផ្លាញផ្ទះសម្បែង ដំណាំ ស្វាយចន្ទី ម្រេច ខ្នុរ នៅចំណុច D5 D6 ឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

១៥.ឈ្មោះ ពុធ គឹមសេង និងឈ្មោះ ពុធ ចាន់ជី តំណាងប្រជាពលរដ្ឋចំនួន៣៤គ្រួសារ ដែលមានដី នៅចំណុច D5 D6 ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ស្នើសុំជួយអន្តរាគមន៍ ទៅអាជ្ញាធរខេត្តក្រចេះ ដែលកំពុងរឹបអូសបំផ្លាញផ្ទះសម្បែង និងបណ្តេញពួកគាត់ចេញពីលំនៅដ្ឋាន និងបម្រុងកាប់បំផ្លាញដំណាំស្វាយចន្ទី ម្រេច ខ្នុរ និងរំលោភយកដីទំហំ២១៩.៨៩ហិកតា ស្ថិតនៅចំណុច D5 D6 ឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

១៦.ឈ្មោះ ហ៊ាន គឹមហេន ឈ្មោះ យ៉ាន់ សុភាព និងឈ្មោះ ឈួន បូរ៉ា ស្នើសុំជួយអន្តរាគមន៍ករណីអភិបាលរង ខេត្តក្រចេះ បានដឹកនាំកម្លាំងឈុតខ្មៅកាប់បំផ្លាញផលដំណាំស្វាយចន្ទីរបស់ពួកគាត់ទំហំ ៦ហិកតា ៨៤អា នៅភូមិជើងឃ្លេ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

១៧.ឈ្មោះ ជូ ពុន នៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្តឹងឈ្មោះ ពិន នង និងបក្ខពួកបានរំលោភយកដីរបស់គាត់ទំហំ៤៥,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

១៨.ឈ្មោះ ខៀវ វិសេស និងប្រពន្ធឈ្មោះ វង្ស កែវលីនណា តំណាងម្ចាស់ដីចំនួន៨គ្រួសារ ប្តឹងឈ្មោះ លុយ ស៊ីលីញ នៅផ្ទះលេខ១៩៣ ផ្លូវ២១៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឈ្មោះ យឺន សុខន និងបក្ខពួក បានរំលោភដីរបស់ពួកគាត់ទំហំ៣២ហិកតា៧អា ស្ថិតនៅចំណុចវាលស្មៅចិញ្ចៀន ក្នុងភូមិលើ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

១៩.បណ្តឹងប្រជាពលរដ្ឋចំនួន១៦គ្រួសារ នៅភូមិតាដោ និងភូមិក្តីកណ្តាល ស្រុកល្វាឯម ខេត្តកណ្តាល ស្នើសុំលោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច លើកចោលបណ្តឹងរបស់ឈ្មោះ ខៀវ វិសេស ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១៦។

២០.ពាក្យសុំអន្តរាគមន៍ឈ្មោះ លឹម មុន្នីរិទ្ធ នៅសង្កាត់អូរឬស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ ដើម្បីទាមទារកាន់កាប់ដីទំហំ៤៤,៦៤៤ម៉ែត្រការ៉េ នៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

២១.ឈ្មោះ ទេព ផាត ឈ្មោះ ទិត្យ លី និងឈ្មោះ កង សាឡៅ នៅរាជធានីភ្នំពេញ ប្តឹងឈ្មោះ ជេត អេន ជាមេភូមិរោងគោ ឃុំសំរោងទង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចធ្វើប័ណ្ណកម្មសិទ្ធិលើដីរបស់ពួកគាត់ ទំហំ៥៥.២៣អា ដែលបានកាន់កាប់គ្រប់គ្រងអាស្រ័យផល តាំងពីឆ្នាំ១៩៨៧ ជាមួយម្តាយ (ស្លាប់) ដែលបានចែកឱ្យពួកគាត់ ស្ថិតនៅភូមិរោងគោ ឃុំសំរោងទង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

២២.ឈ្មោះ ម៉ម ថាវី នៅផ្ទះលេខ១០៩ ផ្លូវបេតុង ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្តឹងឈ្មោះ ហេង នៅរាជធានីភ្នំពេញ បានធ្វើរបងរំលោភយកដីផ្លូវ ដែលធ្វើឱ្យខូចប្រយោជន៍សាធារណៈ ស្ថិតនៅភូមិស្រែអណ្តូង ឃុំទ័ពមាន ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

២៣.ឈ្មោះ ស៊ឹម វណ្ណនី និងកូនឈ្មោះ សួស ដារិទ្ធ នៅផ្ទះលេខ៣៦៤ ផ្លូវ៣៧១ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្តឹងឈ្មោះ ភី ភា និងឈ្មោះ ខេ រ៉ានី (ប្តីប្រពន្ធ) នៅ

ផ្ទះលេខ៤៩ ផ្លូវលេខ៤៦៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន និងឈ្មោះ សេង សុខា ឈ្មោះ ហង្ស រី (ប្តីប្រពន្ធ) នៅរាជធានីភ្នំពេញ បានលួចធ្វើប័ណ្ណកម្មសិទ្ធិរំលោភយកដីរបស់គាត់ទំហំ១៥,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរសំរ៉ែ ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

២៤.ឈ្មោះ ញឹម រ៉ាន់ និងឈ្មោះ ទូច ប៊ុន នៅភូមិត្រពាំងវែង និងឈ្មោះ ញឹម ហ៊្មត នៅភូមិថ្មស ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ផៃ គឹម និងប្តីឈ្មោះ អ៊ុំ ធូយ នៅភូមិស្នួល ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានលួចវាស់រំលោភយកដីទួលម៉ុងបញ្ចុះខ្មោចដូនតារបស់ពួកគាត់ លេខក្បាលដី១១៤ ទំហំ២០ម៉ែត្រx២០ម៉ែត្រ ស្ថិតនៅភូមិស្នួល ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ធ្វើជាកម្មសិទ្ធិ។

២៥.ឈ្មោះ ញ៉ី តក់ នៅភូមិត្រពាំងថ្ម ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ កែវ មុន្នី អតីតមេភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលបានលួចវាស់យកដីស្រែរបស់គាត់ ស្ថិតនៅភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទំហំប្រហែល៥០អា លេខក្បាលដី ៣៨៦ ធ្វើជាកម្មសិទ្ធិអវិភាគភូមិដែលឪពុកឈ្មោះ ប៉ិច ស្លឹក និងម្តាយឈ្មោះ ម៉ី អឿន(ស្លាប់) បានចែកមកឱ្យគាត់។

២៦.ឈ្មោះ នូ សម្បត្តិ នៅភូមិត្រពាំងថ្ម ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ កែវ មុន្នី អតីតមេភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចវាស់យកដីស្រែរបស់គាត់ ស្ថិតនៅភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទំហំប្រហែល៥០អា លេខក្បាលដី៣៨៦ ធ្វើជាកម្មសិទ្ធិអវិភាគភូមិដែលលោកមេភូមិឈ្មោះ ប៉ិច ស្លឹក(ស្លាប់) បានចែកមកឱ្យគាត់។

២៧.ឈ្មោះ សំ ម៉ៅ នៅភូមិត្រពាំងថ្ម ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ កែវ មុន្នី អតីតមេភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចវាស់យកដីស្រែរបស់គាត់ ស្ថិតនៅភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទំហំប្រហែល៤០អា លេខក្បាលដី៣៨៦ ធ្វើជាកម្មសិទ្ធិអវិភាគភូមិ ដែលលោកមេភូមិឈ្មោះ ប៉ិច ស្លឹក(ស្លាប់) បានចែកមកឱ្យគាត់ និងប្តីឈ្មោះ ម៉ី សុង(ស្លាប់)។

២៨.ឈ្មោះ សំ ល័ក្ខ នៅភូមិបន្លាស្អិត ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ កែវ មុន្នី អតីតមេភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចវាស់យកដីស្រែរបស់គាត់ ស្ថិតនៅភូមិវាល ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទំហំប្រហែល៥៥អា លេខក្បាលដី៣៨៦ ធ្វើជាកម្មសិទ្ធិអវិភាគភូមិ ដែលឪពុកឈ្មោះ ចុប ប៉ូ(ស្លាប់) និងម្តាយឈ្មោះ ដួន សៀង បានចែកមកអោយគាត់។

២៩.ឈ្មោះ ម៉ែ ចាន់រី នៅភូមិព្រៃត្បែង ឃុំពោធិ៍ម្រាល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ណុប សីហា (ជាកូន) នៅភូមិចំបក់ ឃុំជ្រៃសីម៉ា ស្រុកសំពៅលូន ខេត្តបាត់ដំបង បានលួចធ្វើលិខិតកាន់កាប់ដីស្រែចំនួន៤កន្លែង ដើម្បីរំលោភយកស្រែមានទំហំប្រហែល៧០អា ដែលជាកម្មសិទ្ធិរបស់គាត់ត្រូវជាម្តាយបង្កើត ស្ថិតនៅភូមិព្រៃត្បែង ឃុំពោធិ៍ម្រាល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

៣០.ឈ្មោះ ឡូញ ឡា ហៅ(ឡៅ ថា) នៅភូមិរោងដំរី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ហ៊ុន មាន នៅភូមិត្រាចកោង ឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានរំលោភយកដីស្រែ

(ដីទួល)របស់គាត់ដោយចេតនា ទំហំប្រហែល៤០ម៉ែត្រ×៨៥ម៉ែត្រ ដែលម្ដាយបង្កើតរបស់គាត់បានចែកមកឱ្យគាត់ក្នុងឆ្នាំ២០០០ ស្ថិតនៅភូមិត្រាចកោង ឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣១.ឈ្មោះ ស៊ិន កន នៅភូមិបន្ទាស្អិត ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ឃឹម ម៉ើន ជាមេភូមិមហាលាភ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចវាស់រំលោភយកដីស្រែដោយចេតនា ដែលឪពុករបស់គាត់ឈ្មោះ អ៊ុំ សៀង និងម្ដាយឈ្មោះ តេង ស៊ីន បានចែកមកឱ្យគាត់មានទំហំប្រហែល៥០អា ធ្វើជាកម្មសិទ្ធិអវិភាគភូមិមហាលាភ លេខក្បាលដី៤០២ ស្ថិតនៅភូមិមហាលាភ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៣២.ឈ្មោះ ស៊ិន សំអុល នៅភូមិមហាលាភ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ឃឹម ម៉ើន ជាមេភូមិមហាលាភ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានលួចវាស់រំលោភយកដីស្រែដោយចេតនា ដែលឪពុករបស់គាត់ឈ្មោះ អ៊ុំ សៀង និងម្ដាយឈ្មោះ តេង ស៊ីន បានចែកមកឱ្យគាត់មានទំហំប្រហែល៥០អា ធ្វើជាកម្មសិទ្ធិអវិភាគភូមិមហាលាភ លេខក្បាលដី៤០២ ស្ថិតនៅភូមិមហាលាភ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៣៣.ឈ្មោះ ឆាយ សោភ័ណ្ឌ និងប្ដីឈ្មោះ ជា ណារិទ្ធ នៅភូមិវល្លិ៍ស ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ឃួន សុផាន្នី ឈ្មោះ ហ៊ី សុខហេង ឈ្មោះ យុន សុផាណា និងឈ្មោះ យុន ប៊ុនលីន នៅភូមិព្រៃកន្ទាច សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដោយពួកគាត់ទាំងបួននាក់មានចេតនាមិនព្រមសងប្រាក់នៃថ្លៃបញ្ចាំដីលំនៅដ្ឋាន លេខក្បាលដី៥៣ ទំហំ៤៦៤ម៉ែត្រការ៉េ ដែលបានដាក់បញ្ចាំឱ្យពួកគាត់ តាមកាលបរិច្ឆេទកំណត់ ស្ថិតនៅភូមិព្រៃកន្ទាច សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

៣៤.ឈ្មោះ ប៉ាត ផាត់ នៅភូមិរំលោង សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ស្រួយ គឹមស្រ៊ុន និងឈ្មោះ ស្រួយ គឹមឡៃ នៅភូមិត្រពាំងខ្យង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានបំណងរំលោភយកដីរបស់គាត់ និងគេចវេសមិនព្រមប្រគល់ប្រាក់បង្គ្រប់ថ្លៃទិញ-លក់ដីតាមកិច្ចសន្យា ដែលមានលេខក្បាលដី១២១ ទំហំ១៦៧ម៉ែត្រការ៉េ ស្ថិតនៅភូមិរំលោង សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

៣៥.ឈ្មោះ ហេង ជៀម នៅភូមិតានី ឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ឆេង ស៊ា និងប្រពន្ធឈ្មោះ គង់ សូគីម នៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានរំលោភយកដីស្រែទំហំ៥,៦០០ម៉ែត្រការ៉េរបស់គាត់ ដែលបានដាក់បញ្ចាំ ស្ថិតនៅភូមិតានី ឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣៦.ឈ្មោះ សឿង សៀម នៅភូមិចំប៉ី ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងកូនឈ្មោះ ពូល មាស នៅភូមិពាមរស់ ឃុំស្នើសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ស៊ុន រុន នៅភូមិក្រាំង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានលួចឈូសឆាយចាក់ដីរំលោភយកដីស្រែរបស់ពួកគាត់ធ្វើផ្លូវទំហំក្បាល៦ម៉ែត្រ×២១៣ម៉ែត្រ ដែលមានលេខក្បាលដី២១៣ និងសូមផ្ទៀងផ្ទាត់ជើងម៉ែត្ររកព្រំដី ស្ថិតនៅភូមិក្រាំង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

៣៧.ឈ្មោះ ញ៉េម ឆាំ និងប្រពន្ធឈ្មោះ អ៊ុំ កង នៅភូមិវត្តភ្នំ ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ជា សុផល ជាមេឃុំភ្នំតូច និងឈ្មោះ ជួន ចន្ថន នៅភូមិក្របីព្រៃ ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្ត

កំពង់ស្ពឺ បានឃុបឃិតគ្នាមិនព្រមចុះហត្ថលេខាលើលិខិតផ្ទេរកម្មសិទ្ធិអចលនទ្រព្យ(ដី) ស្ថិតនៅភូមិវត្តភ្នំ ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣៨.ឈ្មោះ ម៉ា យ៉ាគៀត នៅភូមិដាំស្ពៃ សង្កាត់ស្លាកែត ក្រុងបាត់ដំបង ខេត្តបាត់ដំបង តំណាងឱ្យឈ្មោះ សូ សំណាង នៅបុរីអង្គទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្តឹងស្នើសុំជួយពិនិត្យ និងដោះស្រាយករណីប្រជាពលរដ្ឋចំនួន២៧គ្រួសារ នៅភូមិដំណាក់អំពិល ឃុំក្តុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានមកអះអាង និងទាមទារលើដីកម្មសិទ្ធិរបស់គាត់ចំនួន១២ ប័ណ្ណ ស្ថិតនៅភូមិដំណាក់អំពិល ឃុំក្តុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៣៩.ឈ្មោះ ហួច រ៉ាំ នៅភូមិទឹកចេញ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ខូវ គាត បានបំពានដីធ្លីក្នុងប្លង់៩៥១ និងឯកសារលក់-ទិញប្លង់ដី៩៦១ មិនប្រក្រតី ស្ថិតក្នុងភូមិខ្វិតទួលឃ្លាំង ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤០.ឈ្មោះ ពុំ សុភាព នៅភូមិស្វាយជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ជួន ធៀប និងប្រពន្ធឈ្មោះ ចាន់ វណ្ណា បានរំលោភបំពានដីទំហំ៩ហិកតា៣អា៤០សង់ទីអា និងលួចដីកដីធ្វើប្រឡាយធ្វើជាព្រំលើកម្មសិទ្ធិរបស់គាត់ ស្ថិតនៅភូមិទួលសំពោង ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤១.ឈ្មោះ កុល ភូមិន្ទ នៅភូមិស្វាយជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ជួន ធៀប និងប្រពន្ធឈ្មោះ ចាន់ វណ្ណា ដែលបានរំលោភបំពានដីទំហំ៤ហិកតា២៩អា និងលួចដីកដីធ្វើប្រឡាយធ្វើជាព្រំលើកម្មសិទ្ធិរបស់គាត់ ស្ថិតនៅភូមិទួលសំពោង ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤២.ឈ្មោះ យឹម ស្រីទូច នៅភូមិថ្នារប ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ជួន ធៀប និងប្រពន្ធឈ្មោះ ចាន់ វណ្ណា បានរំលោភបំពានដី និងលួចដីកដីធ្វើប្រឡាយធ្វើជាព្រំលើកម្មសិទ្ធិរបស់ពួកគាត់ ស្ថិតនៅភូមិចាន់ត្រក ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤៣.ឈ្មោះ ស្រី យ៉ា នៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ជួន ធៀប និងប្រពន្ធឈ្មោះ ចាន់ វណ្ណា បានរំលោភបំពានដីរបស់គាត់ទំហំ១ហិកតា៨៩អា ស្ថិតនៅភូមិចាន់ត្រក ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤៤.ប្រជាពលរដ្ឋចំនួន៧០គ្រួសារ នៅភូមិក្រាំងស្គារ ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ស្នើសុំជួយដោះស្រាយករណីទំនាស់ដីធ្លីមួយកន្លែង ដែលមានទំនាស់ជាមួយលោក ព្រហ្ម ហួយ ស្ថិតនៅភូមិក្រាំងស្គារ ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

៤៥.ឈ្មោះ ពន អូន នៅភូមិក្រាំងសាម៉ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ស្នើសុំជួយ ដោះស្រាយជម្លោះដីធ្លីជាមួយលោក ឌុល ជា មេភូមិក្រាំងសាម៉ លោកស្រី ប៉ែន សោភា មេឃុំស្វាយជុក និងលោក អ៊ុំ ប៊ុណ្ណា នាយកវិទ្យាល័យហ៊ុនសែនក្រាំងសាម៉។

៤៦.អាជ្ញាធរឃុំទឹកហូត ប្តឹងទាមទារដកតំណែងព្រះតេជគុណ ជុត ចន្ថា ចៅអធិការវត្តទឹកហូត បានស្តីប្រមាថ ចំពោះគណៈកម្មការវត្ត នៅភូមិទឹកហូត ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

៤៧.ឈ្មោះ អៀង ហួន និងប្រពន្ធឈ្មោះ ឃុន សុខហេង នៅភូមិឡទឹកត្រី សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ នង ភក្តី និងប្រពន្ធ បានសាងសង់លំនៅដ្ឋាន និងបង្គន់ ព្រមទាំង

បោះបង្គោលរំលោភយកដីកម្មសិទ្ធិស្របច្បាប់របស់គាត់ ស្ថិតនៅភូមិស្រះកែវ ឃុំមេលំ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

៤៨.ឈ្មោះ ឆាយ លាភា នៅផ្ទះ២អ៊ី០ ផ្លូវ១៧៨ ភូមិ៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្តឹងប្រជាពលរដ្ឋមួយក្រុម បានបោះបង្គោលហ៊ុំព័ទ្ធយកដីរបស់គាត់ ព្រមទាំងហាមឃាត់ និងគំរាមមិនឱ្យគាត់ចូលកាន់កាប់លើដីកម្មសិទ្ធិរបស់គាត់ផង ស្ថិតនៅភូមិដំបូកកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលគាត់បានកាន់កាប់តាំងពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន។

៤៩.ប្រជាពលរដ្ឋរស់នៅឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ប្តឹងជនអនាមិកពាក់ព័ន្ធនឹងឈ្មោះ អៀង វណ្ណី មេទាហ៊ានស្រុកជលគីរី ខេត្តកំពង់ឆ្នាំង បានគំរាមកំហែង និងទារប្រាក់ពីប្រជាពលរដ្ឋ។

៥០.មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំងស្នើសុំក្រុមការងារខេត្តកំពង់ឆ្នាំង និងអាជ្ញាធរពាក់ព័ន្ធ ជួយពិនិត្យដោះស្រាយផលប៉ះពាល់ផ្លូវខេត្តលេខ1KCH18 (ចេញពីរង្វង់មូលទូកមាសហូតដល់វត្តថ្នល់) ដែលប្រជាពលរដ្ឋបានប្រើប្រាស់អាស្រ័យផល និងសាងសង់របងលើដីចំណីផ្លូវ ស្ថិតនៅភូមិដំបូកកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

៥១.ប្រជាពលរដ្ឋចំនួន៨គ្រួសារ នៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងលោក ហ៊ុន លី និងប្រពន្ធឈ្មោះ ឡៃ្សន សុភា នៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានធ្វើរបងបិទផ្លូវសាធារណៈ ធ្វើឱ្យប្រជាពលរដ្ឋពុំអាចចេញ-ចូលបាននៅខ្សែទី៧ កាត់ទទឹងផ្លូវចន្លោះចេញពីផ្លូវបំបែកជា៤ ប្រកដំរីស ឆ្ពោះទៅសាខាវិទ្យាស្ថានបូលីណូ ស្ថិតនៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

៥២.ឈ្មោះ អេង គឹមសួរ និងប្រពន្ធឈ្មោះ ឆយ រុន នៅភូមិកំពង់ត្រឡាចលើ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ទេព ប៊ុនឈឿន បានរំលោភបំពានយកដីលំនៅដ្ឋានរបស់គាត់ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលមានក្បាលដីទំហំ១៤ម៉ែត្រ និងបណ្តោយទំហំ២៥ម៉ែត្រ ស្ថិតនៅភូមិ-ឃុំខាងលើ។

៥៣.ឈ្មោះ ម៉ាត់ ម៉ែសំ នៅភូមិសំរិទ្ធិជ័យ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ទុំ ពេស បានសាងសង់របងថ្មរំលោភយកដីគាត់ ស្ថិតនៅភូមិសំរិទ្ធិជ័យ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង។

៥៤.ឈ្មោះ សូ ធី នៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ សំ សុខខេម នៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បានបិទផ្លូវ ស្ថិតនៅភូមិ អ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

៥៥.ឈ្មោះ អ៊ុន សុវឿន មានទំនាស់ជាមួយឈ្មោះ ម៉ៅ ស្រស់ បានដណ្តើមដីកេរ្តិ៍ ស្ថិតនៅភូមិព្រៃកគន្លង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

៥៦.ឈ្មោះ ម៉ែន សាវឿន នៅភូមិព្រេច សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ស្នើសុំអន្តរាគមន៍ជួយកំណត់ព្រំដីរវាងក្បាលដីលេខ២២៣ និងក្បាលដីលេខ២២៧ ស្ថិតនៅភូមិព្រេច សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។

៥៧.ឈ្មោះ ព្រាប ដាក់ា និងប្រពន្ធឈ្មោះ សួង ស្រីណាត នៅភូមិក្រាំងចំរើន ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ស្នើសុំជួយអន្តរាគមន៍ករណីរារាំងការចាក់ដីធ្វើរបង ពីសំណាក់ឈ្មោះ សាន កក្តដា និងប្រពន្ធឈ្មោះ សួង ស្រីណែត នៅភូមិក្រាំងចំរើន ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

៥៨.ឈ្មោះ សួន ហៀង ឈ្មោះ ណុប ហឿន និងឈ្មោះ សួន ហុន នៅភូមិតាឌុ សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ប្តឹងឈ្មោះ សួន នៀក ជាបងប្អូនបង្កើតនឹងគ្នា បានលក់ដីកេរ្តិ៍ឪពុក ដោយមិនបានបែងចែកចំណែកពីការលក់ដីជូនបងប្អូនដទៃទៀត។

៥៩.ឈ្មោះ ស៊ឹម សំណាង នៅផ្ទះលេខ៣៣៣ ក្រុម១៦ ភូមិអញ្ចាញ សង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបងដោយស្នើសុំជួយដោះស្រាយការចុះបញ្ជីធ្វើប្លង់កម្មសិទ្ធិដីតាមប្រព័ន្ធនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងបាត់ដំបង ដោយអនុវត្តតាមសាលដីការស្ថាពរ លេខ៤៩(ឈ)១៧-០៨-២០០៩ របស់សាលាឧទ្ធរណ៍ លើសំណុំរឿងព្រហ្មទណ្ឌ លេខ០២/០៥-០១-២០០៩។

៦០.ឈ្មោះ លី មករា និងប្រពន្ធឈ្មោះ សុះ ទ៉ីភ័ស្ត នៅភូមិអូរឃ្មុំ ឃុំស្នើសង្ហា ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ប្តឹងឈ្មោះ វ៉ាន់ លី និងកូនឈ្មោះ ពុធ បានដកបង្គោលរំកិលព្រំដី ស្ថិតនៅភូមិអូរឃ្មុំ ឃុំស្នើសង្ហា ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។

៦១.ឈ្មោះ រ៉ូ សារ៉ាក់ នៅភូមិបាក់អំរែក ឃុំព្រៃកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ប្តឹងឈ្មោះ ពក សៃ បានរំលោភព្រំដីទំហំ១ម៉ែត្រ ចំនួន២ជ្រុង នៅចំហៀងខាងមុខ និងចំហៀងខាងក្រោយ។

៦២.ឈ្មោះ ដួង ស្រេង និងប្រពន្ធឈ្មោះ សេង ញ៉ាញ់ នៅភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ករណីទំនាស់ដីធ្លី ស្ថិតនៅភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជាមួយឈ្មោះ ប៊ុនថាន់ លក្ខិណា នៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

៦៣.ឈ្មោះ ហុក គឹមច្រើន និងប្រពន្ធឈ្មោះ អឿន មករា នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ស្នើសុំអន្តរាគមន៍ប្រើប្រាស់ និងអាស្រ័យផលស្របច្បាប់លើដីមួយកន្លែង ស្ថិតនៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

## ៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-ក្នុងរយៈពេល១២ខែឆ្នាំ២០២១នេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានទទួលលិខិតបញ្ជាបេសកកម្មពីសំណាក់ថ្នាក់ដឹកនាំក្រសួង ដើម្បីចុះធ្វើសវនកម្មក្នុងការិយបរិច្ឆេទ២០២០ នៅតាមទីសវនដ្ឋានចំនួន ៤មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបង ប៉ៃលិន កំពង់ធំ និងខេត្តកែប តែដោយសារវិបត្តិនៃជំងឺកូវីដ-១៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមិនទាន់បានចុះធ្វើសវនកម្មនៅឡើយ។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ១៦៨ អនក្រ. បក ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធZoom។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយឯកសារស្រាវជ្រាវទស្សនាទាន ស្តីពីនីតិវិធីសុខដុមនីយកម្ម សវនកម្ម និងអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធZoom។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ ដែលរៀបចំឡើងដោយអាជ្ញាធរសវនកម្មជាតិ តាមប្រព័ន្ធZoom។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បានពង្រឹងការគ្រប់គ្រងរដ្ឋបាល និងចរន្តការងារទូទៅ របស់វិទ្យាស្ថាន។

-បានប្រជុំតាមដានវឌ្ឍនភាពការងារប្រចាំខែមករាដល់ខែធ្នូ ឆ្នាំ២០២១ ប្រជុំបូកសរុបការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២។

-បានបង្កើតក្រុមស្រាវជ្រាវ ចងក្រងអនុសាសន៍ របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី។

-បានស្រាវជ្រាវ ចងក្រងអនុសាសន៍របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីសរុបចំនួន៨៧ច្បាប់ និងប្រមូលផ្តុំឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាសរុបចំនួន ១,៣៩៩ច្បាប់ រួមទាំងធ្វើសៀវភៅចំនួន៥៥ក្បាល។

-បានរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២២ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-បានរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់ឆ្នាំ២០២២។

-បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-បានបើកវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចជំនាន់ ៣ វគ្គ១ ដែលមានរយៈពេល២សប្តាហ៍ ដល់សិក្ខាកាមចំនួន៤៥នាក់ (ស្ត្រីចំនួន១១នាក់) ។

-បានរៀបចំរបាយការណ៍សមិទ្ធកម្មឆមាសទី១ និងប្រចាំឆ្នាំ២០២១ របស់វិទ្យាស្ថាន។

-បានបូកសរុបរបាយការណ៍លទ្ធផល ការងារពាក់កណ្តាលអាណត្តិពីខែមករា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២១ របស់វិទ្យាស្ថាន។

-បានបូកសរុបរបាយការណ៍ប្រចាំខែមករាដល់ខែធ្នូ ឆ្នាំ២០២១ (ខែ ត្រីមាសទី១ ឆមាសទី១ រយៈពេល៩ខែ និងប្រចាំឆ្នាំ២០២១) របស់វិទ្យាស្ថាន។

-បានបញ្ជូនមន្ត្រីរាជការចំនួន៣រូបរបស់វិទ្យាស្ថានទៅសិក្សានៅសាលាភូមិន្ទរដ្ឋបាល។

-បានបញ្ចប់សេចក្តីព្រាងស្តីពីការជ្រើសរើសសាស្ត្រាចារ្យ គ្រូឧទ្ទេស មន្ត្រីរាជការ និងនិស្សិត។

-បានបញ្ចប់សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន។

-បានបញ្ចប់សេចក្តីព្រាងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់វិទ្យាស្ថាន។

-បានផ្តល់ព័ត៌មាន ណែនាំ និងក្រើនរំលឹកមន្ត្រីរាជការនៃវិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីទប់ស្កាត់ និងការពារការឆ្លងជំងឺកូវីដ-១៩។

-បានសម្របសម្រួលមន្ត្រីរាជការវិទ្យាស្ថានជាតិអធិការកិច្ច បានចាក់វ៉ាក់សាំងកូវីដ-១៩ លើកទី១ លើកទី២ និងដូសជំរុញទាំងអស់គ្នា។

-បានផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួង និងវិទ្យាស្ថាន នៅក្នុងផេករបស់វិទ្យាស្ថានជាប្រចាំ។

-បានចូលរួមផ្សព្វផ្សាយបន្តក្នុងផេករបស់វិទ្យាស្ថាននូវសេចក្តីណែនាំ វិធានការ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងការការពារ និងបង្ការការចម្លងជំងឺកូវីដ-១៩ ព្រមទាំងវិធានការ ៣ការពារ និង៣កុំ របស់រាជរដ្ឋាភិបាល។

## ៦.សកម្មភាពការងារផ្សេងៗ

### ៦.១.សកម្មភាពការងារយេនឌ័រ

ក្រុមការងារបច្ចេកទេសយេនឌ័រប្រចាំក្រសួងបានអនុវត្តទៅតាមតួនាទីភារកិច្ច និងផែនការប្រចាំឆ្នាំ ឆ្នាំ២០២១ របស់ខ្លួន ដើម្បីបញ្ជ្រាបយេនឌ័រគ្រប់វិស័យរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចគ្រប់ផ្នែក សំដៅលើកកំពស់សមភាពយេនឌ័រ សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារ ឱ្យបានល្អប្រសើរ។ ក្នុងរយៈពេល១ឆ្នាំនេះ បិតក្នុងបរិការណ៍កូវីដ១៩ ក្រុមការងារទទួលលទ្ធផលបានដូចខាងក្រោម៖

-ស្ថានភាពស្ត្រីក្នុងមុខតំណែង នៅក្រសួងសម្រាប់ឆ្នាំ២០២១ មានភាពប្រែប្រួលដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រីចំនួន១រូបត្រូវបានតែងតាំង ជារដ្ឋលេខាធិការ ចំនួន១៨រូបជាទីប្រឹក្សា ចំនួន១រូបជាប្រធានការិយាល័យ និងចំនួន៣រូបជាអនុប្រធានការិយាល័យ។ ទន្ទឹមនេះដែរ ថ្នាក់មន្ទីររាជធានី-ខេត្ត មន្ត្រីរាជការជាស្ត្រីត្រូវបានតែងតាំងជាអនុប្រធានមន្ទីរចំនួន១រូប ប្រធានការិយាល័យចំនួន៩រូប និងអនុប្រធានការិយាល័យចំនួន ១៤ រូប។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រីដែលមានមុខតំណែងថ្នាក់ក្រសួងមានប្រមាណ២៩% និងថ្នាក់មន្ទីររាជធានី-ខេត្តមានប្រមាណ២៧%។

-លោកជំទាវប្រធានក្រុមការងារបានចុះសួរសុខទុក្ខ និងបានចាត់តាំងប្រតិភូចុះសួរសុខទុក្ខស្ត្រីជាមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាសម្រាលមាតុភាព ចំនួន៧នាក់ និងប្រគល់ជូនថវិកាឧបត្ថម្ភរបស់ លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី ក្នុងម្នាក់ចំនួន៥០ម៉ឺនរៀល និងថវិការបស់ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងម្នាក់២០ម៉ឺនរៀល បន្ថែមលើប្រាក់ឧបត្ថម្ភរបស់ក្រសួង។

-ដើម្បីចូលរួមចំណែកគាំទ្រដល់សកម្មភាពបង្ការ ការពារនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឯកឧត្តម លីវ សុភក្ត្រា អនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមការងារបច្ចេកទេសយេនឌ័របានឧបត្ថម្ភម៉ាស់ពេទ្យ និងជែលលាងដៃ ជូនដល់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៥ រួមមានខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កណ្តាល រាជធានីភ្នំពេញ ខេត្តកំពង់ចាម ត្បូងឃ្មុំ ស្វាយរៀង ខេត្តពោធិ៍សាត់ កំពង់ធំ បាត់ដំបង ព្រៃវែង សៀមរាប កោះកុង និងកែប ដោយមន្ទីរនីមួយៗទទួលបានម៉ាស់ពេទ្យចំនួន១០,០០០ម៉ាស់ និងជែលលាងដៃចំណុះ ២៥០មីលីលីត្រ សរុបចំនួន ៩៦ដប។

-កាលពីថ្ងៃទី១២ ខែមីនាឆ្នាំ២០២១ ក្រុមការងារបច្ចេកទេសយេនឌ័រត្រូវបានកែសម្រួលសមាសភាពមួយចំនួន និងបន្ថែមក្រុមការងារលេខាធិការដ្ឋាន ។

-ក្រុមការងារបច្ចេកទេសយេនឌ័របានផ្អាកធ្វើពិធីផ្លូវការអបអរខួប លើកទី១១០ ទិវា អន្តរជាតិនារី ៨មីនា ឆ្នាំ២០២១ ប្រធានបទ «ស្ត្រី និងការអភិវឌ្ឍក្នុងបរិការណ៍កូវីដ១៩»។ ទោះជាមានការផ្អាកធ្វើពិធីក៏ដោយ ក៏ថ្នាក់ដឹកនាំក្រសួង ក៏ដូចជាក្រុមការងារ បច្ចេកទេសយេនឌ័របានយកចិត្តទុកដាក់ រៀបចំផ្តល់ជូនថវិកា និងវត្ថុអនុស្សាវរីយ៍ ដល់ថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង មន្ត្រីរាជការ និងមន្ត្រីជាប់ កិច្ចសន្យាជាស្ត្រី ដោយលោកជំទាវកិត្តិសង្គហបណ្ឌិតបានឧបត្ថម្ភថវិកា ឯកឧត្តម លីវ សុភក្ត្រា បាន ឧបត្ថម្ភម៉ាស

ពេទ្យ ដែលលាងដៃ និងសប្បុរសជនបានផ្តល់ក្រណាត់ប៉ាក់ ដោយម្នាក់ៗទទួល បាន ថវិកា ៥ ម៉ឺនរៀល ម៉ាសសុវត្ថិភាព១ប្រអប់ ដែលលាងដៃ១ដប និងក្រណាត់ប៉ាក់១អាវ។

ដោយឡែកមន្ត្រីជាប់កិច្ចសន្យាជាបុរសលោកជំទាវកិត្តិសង្គហបណ្ឌិតបានឧបត្ថម្ភថវិកាម្នាក់៥ម៉ឺនរៀល។

-បានដោះស្រាយជូនមន្ត្រីជាអ្នកជំងឺចំនួន២រូបចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយមន្ទីរពេទ្យព្រះកេតុមាលា។

-បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រសួងកិច្ចការនារីចំនួន២លើក និងជាមួយក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីចំនួន២លើក និងចូលរួមប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រអន្តរក្រសួងប្រចាំឆ្នាំ ២០២១ ចំនួន១លើក នៅសណ្ឋាគារភ្នំពេញ។

## ៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយកងកម្លាំងជួរមុខវរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣។ ក្នុងឱកាសនោះ ក៏មានការឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ដែលបានមកពីសប្បុរសជន គិតជាទឹកប្រាក់សរុបចំនួន ៨០,២៨០,០០០រៀល និងប្រាក់ដុល្លារសហរដ្ឋអាមេរិកចំនួន ១១,០០០ដុល្លារ។

## ៦.៣. សមាគមសង្គហមិត្តភាព

-ចាប់ពីខែឧសភា ឆ្នាំ២០១៨ ដល់ខែធ្នូ ឆ្នាំ២០២១ សមាជិក សមាជិកា សមាគមសង្គហមិត្តភាព មានចំនួន៥៨៩នាក់ ថ្នាក់កណ្តាលមានចំនួន១៤នាយកដ្ឋាន វិទ្យាស្ថានជាតិអធិការកិច្ច សមាជិកផ្សេងៗ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២៥រាជធានី-ខេត្ត។

-ក្នុងឆ្នាំ២០១៨ សមាជិក សមាជិកា មានចំនួន៥៨៩នាក់ ឆ្នាំ២០១៩ សមាជិក សមាជិកា មានចំនួន ៥២៣នាក់ ឆ្នាំ២០២០ សមាជិក សមាជិកា មានចំនួន ៤៣៧នាក់ និងឆ្នាំ២០២១ សមាជិក សមាជិកា មានចំនួន ២៤៤នាក់។ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ ចំនួនសមាជិក សមាជិកា ដែលមិនទាន់បានបង់វិភាគទានជូនសមាគមសង្គហមិត្តភាពរួមមាន៖

១.ថ្នាក់កណ្តាលមានចំនួន៩នាយកដ្ឋានពុំទាន់បានបង់វិភាគទាន ជូនសមាគមសង្គហមិត្តភាព គឺ នាយកដ្ឋាន បុគ្គលិក និងធនធានមនុស្ស នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអធិការកិច្ចទី១ នាយកដ្ឋានអធិការកិច្ចទី២ នាយកដ្ឋានអធិការកិច្ចទី៣ នាយកដ្ឋានទំនាក់ទំនងរាជរដ្ឋាភិបាល និងនាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់។

២.មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៦មន្ទីរពុំទាន់បានបង់វិភាគទានជូនសមាគមសង្គហមិត្តភាព គឺមន្ទីរទរពអខេត្តកំពង់ចាម ស្វាយរៀង ប៉ៃលិន កំពង់ធំ កោះកុង ស្ទឹងត្រែង មណ្ឌលគីរី កំពង់ឆ្នាំង កំពង់ស្ពឺ ព្រះសីហនុ បន្ទាយមានជ័យ ឧត្តរមានជ័យ ក្រចេះ បាត់ដំបង ពោធិ៍សាត់ និងមន្ទីរទរពអខេត្តព្រះវិហារ។

-សមាគមសង្គហមិត្តភាពក៏បានឧបត្ថម្ភប្រាក់ជូនដល់មន្ត្រីរាជការ និងក្រុមគ្រួសារមន្ត្រីរាជការ ដែលទទួលមរណភាពចំនួន៧លើករួមមានៈ ថ្នាក់កណ្តាល និងមន្ទីរទេពអខេត្តស្វាយរៀង ព្រះសីហនុ កែប កំពង់ឆ្នាំង តាកែវ។

សមាគមសង្គហមិត្តភាព បានអនុវត្តការងាររបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ដើម្បីសម្រេចឱ្យបាន លទ្ធផលគួរជាទីមោទនៈ ទោះបីមានការលំបាកខ្លះៗយ៉ាងណាក្តី ក៏សមាគមសង្គហមិត្តភាពនៅតែពុះ ពាររាល់ឧបសគ្គ ដើម្បីជំរុញការងារឱ្យសម្រេចបានលទ្ធផលល្អប្រសើរ ទៅតាមលក្ខន្តិកៈរបស់សមាគម សង្គហមិត្តភាព នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

## ៦.៤.សកម្មភាពក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក។

-បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក។

## ៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បានស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញ ភារកិច្ចជូនក្រសួងចំនួន១៥៥នាក់។

## ៦.៦.សកម្មភាពការងារក្រុមការងារ សរុបព័ត៌មាន និងខ្លឹមសារ អនុសាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់

សម្តេចតេជោ នាយករដ្ឋមន្ត្រី បានដាក់ចេញនូវអនុសាសន៍ជាបន្តបន្ទាប់សរុបចំនួន ៩៩ អនុសាសន៍ និងឥស្សរជនជាន់ខ្ពស់ផ្សេងទៀត បានដាក់ចេញនូវអនុសាសន៍ជាបន្តបន្ទាប់សរុបចំនួន៤ គឺ ខែមករាបានដាក់ចេញនូវចំនួន៧អនុសាសន៍ ខែកុម្ភៈបានដាក់ចេញនូវចំនួន៨អនុសាសន៍ ខែមីនាបាន ដាក់ចេញចំនួន១៤អនុសាសន៍ ខែមេសាបានដាក់ចេញចំនួន២៦អនុសាសន៍ ខែឧសភាបានដាក់ចេញ នូវចំនួន ១អនុសាសន៍ ខែមិថុនាបានដាក់ចេញនូវចំនួន ៨អនុសាសន៍ ខែកក្កដាបានដាក់ចេញ ចំនួន១ អនុសាសន៍ ខែសីហាបានដាក់ចេញនូវចំនួន៦អនុសាសន៍ ខែកញ្ញាបានដាក់ចេញនូវចំនួន៣អនុសាសន៍ ខែតុលាបានដាក់ចេញនូវចំនួន៥អនុសាសន៍ ខែវិច្ឆិកាបានដាក់ចេញនូវចំនួន១២អនុសាសន៍ និងខែធ្នូ បានដាក់ចេញនូវចំនួន៨អនុសាសន៍ និងលិខិតបទដ្ឋានគតិយុត្តសរុបចំនួន៥៩ គឺខែមករាចំនួន១២ លិខិត ខែកុម្ភៈចំនួន៣លិខិត ខែមីនាចំនួន៥លិខិត ខែមេសាចំនួន៧លិខិត ខែឧសភាចំនួន ៧ លិខិត ខែមិថុនាចំនួន៣លិខិត ខែកក្កដាចំនួន៥លិខិត ខែសីហាចំនួន៨លិខិត ខែកញ្ញាចំនួន ២ លិខិត ខែតុលាចំនួន៥លិខិត ខែធ្នូចំនួន២លិខិត។

## ៦.៧.សកម្មភាពការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App

-បានធ្វើការចុះផ្សាយព័ត៌មាន និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងស្ថាប័នក្រោមចំណុះ ក្រសួង ចូលក្នុងគេហទំព័រជាប់ជាប្រចាំ។

-បានធ្វើការទាញរក្សាទុកទិន្នន័យនៅក្នុងគេហទំព័រជាប្រចាំ ដើម្បីរក្សាទុកទិន្នន័យទាំងអស់ដែល មាននៅក្នុងគេហទំព័រកន្លងមក។

-បានធ្វើបច្ចុប្បន្នភាព (update) ប្រព័ន្ធការពារមេរោគរបស់គេហទំព័រ ដើម្បីធានាបាននូវសុវត្ថិភាព។

-បានធ្វើការផ្សព្វផ្សាយព័ត៌មានពីគេហទំព័រទៅកាន់បណ្តាញសង្គមដូចជា Facebook និង Telegram។

### ៦.៨.ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS

ក្រសួងបានអនុវត្តតាមផែនការសកម្មភាពដំណាក់កាលទី៣ បូក២ ឆ្នាំ២០២១ ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធFMIS ដោយសម្រេចបានទទួលផលដូចខាងក្រោម៖

១.អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបានរៀបចំរបាយការណ៍ប្រៀបធៀបផែនការចំណាយតាមកម្មវិធី ប្រចាំត្រីមាស និងការអនុវត្តជាក់ស្តែងដោយឆ្លុះបញ្ចាំងនូវគោលដៅចំណាយក្នុងត្រីមាសនីមួយៗ

២.ក្រសួងបានផ្សព្វផ្សាយតាមរយៈសារព័ត៌មាននូវសេចក្តីជូនដំណឹងស្តីពីការចូលរួមដេញថ្លៃរបស់អង្គភាពលទ្ធកម្ម។

៣.ក្រសួងបានទូទាត់ថវិការជូនទេយ្យបុរេប្រទានប្រចាំត្រីមាសនីមួយៗ (ជុំទី១,២,៣,៤) បានទាន់ពេលវេលា។

៤.ក្រសួងបានពិនិត្យលទ្ធភាពបញ្ចូលប្រាក់បេសកកម្ម ចូលទៅក្នុងប្រព័ន្ធ ATM កំរិតថ្នាក់ដឹកនាំ (រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ) តែនៅមានបញ្ហាមួយចំនួនដែលនៅសេសសល់ និងមិនទាន់បានអនុវត្ត។

៥.បានចូលរួមបណ្តុះបណ្តាល (Online Meeting)ទាំងមន្ត្រីចាស់ មន្ត្រីថ្មីលើការអនុវត្តប្រព័ន្ធ FMIS ជាមួយក្រុមការងារ FMIS នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាច្រើនលើក។

៦.បានចូលរួមប្រជុំជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ចំនួន២១លើក។

៧.អង្គភាពលទ្ធកម្មបានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើន ថយប្រចាំឆ្នាំ២០២០ និងបានរៀបចំរបាយការណ៍ចំនួនមន្ទីរដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ។

៨.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ត្រូវបានអនុវត្តតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៩.បានពិនិត្យ និងវាយតម្លៃលក្ខណៈសម្បត្តិ របស់អង្គភាពថវិកាចំនួន៣ ដែលមិនទាន់ជាអង្គភាពអណាប័កផ្ទេរសិទ្ធិ និងត្រៀមការកសាងសមត្ថភាពមន្ត្រីជំនាញដើម្បីឈានទៅអនុវត្តបន្ត។

១០.គម្លាតនៃផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដែលអនុម័ត ត្រូវបានកាត់បន្ថយ។

១១.បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធី ប្រចាំត្រីមាសទី១,២,៣ និងទី៤ ហើយបានផ្ញើ ជូនអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាន់ពេលវេលា។

១២.បានរៀបចំកិច្ចប្រជុំវាយតម្លៃការអនុវត្តការងារពាក់កណ្តាលឆ្នាំតាមរយៈ Zoom។

១៣.ផែនការយុទ្ធសាស្ត្រអធិការកិច្ច ៣ឆ្នាំរំកិល ផែនការអធិការកិច្ចប្រចាំឆ្នាំ២០២២ ត្រូវបានបញ្ចប់និងអនុម័ត។

១៤.ផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំរំកិល និងផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២២ ត្រូវបានបញ្ចប់និងអនុម័ត។

១៥.មានតារាងសូចនាករសមិទ្ធកម្មគន្លឹះ(KPI) និងតារាងតម្រូវការថវិកា សម្រាប់ការអនុវត្តឆ្នាំ២០២២ និងបានផ្ញើជូន អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈពិនិត្យ។

១៦.បានរៀបចំកិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពលម្អិតដំណាក់កាលទី៣ បូក២ តាមប្រព័ន្ធ (Zoom Meeting)។

១៧.បានរៀបចំសេចក្តីសម្រេចការកែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្ញើជូនអគ្គលេខាធិការគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិនិត្យ និងវាយតម្លៃ។

១៨.បានអនុម័តជាប្រចាំនូវឯកសារមួយចំនួនតាមប្រព័ន្ធ FMIS ដូចជាប្រាក់បៀវត្សរ៍មន្ត្រីរាជការ ការងារលទ្ធកម្ម វេជ្ជទេយ្យ ទឹក ភ្លើង ទូរស័ព្ទ និងធានាចំណាយផ្សេងៗទៀត។

១៩.បានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ២០២១ ផ្ញើជូនទៅអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិនិត្យ។

# ផ្នែកទី ២-បញ្ហាប្រឈម



## ១. ការប្រឈមផ្នែករដ្ឋបាល

-ថវិកាបុរេប្រទានមានកំរិតទាប នាំឲ្យមានការលំបាកក្នុងការដោះស្រាយថវិកាមុនបេសកកម្ម ពោលគឺធ្វើបេសកកម្មមុន ទើបដោះស្រាយតាមក្រោយ។

-កង្វះមធ្យោបាយធ្វើដំណើររបស់ក្រសួង (រថយន្តផ្លាកលេខរដ្ឋ០៨) និងកង្វះសម្ភារបច្ចេកវិទ្យា (កំព្យូទ័រយួរដៃ) សម្រាប់ចុះបំពេញបេសកកម្ម។

-ដំណើរការរដ្ឋបាល លិខិតចេញ និងលិខិតចូលនៅមានភាពយឺតយ៉ាវ ដោយសារបញ្ហាមួយចំនួន ជាពិសេសក្នុងករណីឯកសារដែលមកដល់ក្រសួងយឺត ឬមានភាពបន្ទាន់។

## ២. ការប្រឈមផ្នែកទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-បុគ្គលិកមកធ្វើការមិនទៀង ឬអវត្តមានច្រើន ដោយសារមូលហេតុទី១ បណ្តាលមកពីកត្តានៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងទី២ បណ្តាលមកពីនាយកដ្ឋានពុំមានការងារធ្វើច្រើន ក្នុងវិស័យទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា។

-ការផ្សព្វផ្សាយច្បាប់ត្រូវបានកាត់បន្ថយ ដោយសារបញ្ហានៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ នាំឲ្យលទ្ធផលការងារត្រូវធ្លាក់ចុះ។

## ៣. ការប្រឈមផ្នែកអធិការកិច្ច

-ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បណ្តាលឱ្យការងាររបស់អគ្គនាយកដ្ឋានអធិការកិច្ចត្រូវបានផ្អាកសកម្មភាពស្ទើរតែពេញ១ឆ្នាំ នាំឱ្យផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានអធិការកិច្ចមិនបានអនុវត្ត ជាហេតុធ្វើឱ្យការងារអធិការកិច្ច និងការងារតាមដានការអនុវត្តច្បាប់មិនសម្រេចបានលទ្ធផលល្អ។

-កិច្ចសហការរបស់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួនលើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវបណ្តឹងនៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខា និងយល់ព្រមលើលទ្ធផលអធិការកិច្ច ដែលនាំឲ្យមានការយឺតយ៉ាវ និងតម្រូវឲ្យមានការពិភាក្សា និងកែតម្រូវ។

## ៤. ការប្រឈមផ្នែកនីតិកម្ម

-សេចក្ដីព្រាងច្បាប់អធិការកិច្ចត្រូវបានត្រៀម និងប្រជុំពិភាក្សាផ្ទៃក្នុង និងក្នុងកិច្ចប្រជុំអន្តរក្រសួងជាច្រើនលើក តែនៅរាំងស្ទះ និងពន្យារពេលជាច្រើនខែឆ្នាំ។ លើសពីនេះទៀត ក្រសួងនៅខ្វះលិខិតបទដ្ឋានគតិយុត្តសម្រាប់ណែនាំ និងតម្រង់ទិសការងារ ដែលជាវិធានផ្ទៃក្នុងមួយចំនួនទៀត នៅពេលដែលរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០២០ ស្ដីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច។ ដោយហេតុនេះ តួនាទី និងភារកិច្ចរបស់ក្រសួងនៅមានភាពមិនច្បាស់លាស់ និងភ័ន្តច្រឡំ ជាពិសេសការងារចុះធ្វើអធិការកិច្ចតាមក្រសួងស្ថាប័ននានា។

-កង្វះធនធានមនុស្សផ្នែកនីតិកម្មដើម្បីផ្ដួចផ្ដើមគំនិតធ្វើសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

## ៥. ការប្រឈមផ្សេងទៀត

-ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ ជាពិសេសជំនាញការផ្នែកច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

-ពុំទាន់មានក្របខ័ណ្ឌមន្ត្រីរាជការគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងប្រសិទ្ធភាពការងាររបស់វិទ្យាស្ថាន និងសមត្ថភាពមន្ត្រីនៅមានកម្រិត។

-ពុំទាន់មានគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល។

-ថវិកានៅមានកម្រិត ដែលជាឧបសគ្គដល់ការរៀបចំការបណ្ដុះបណ្ដាលឱ្យមានលក្ខណៈជាប្រព័ន្ធ និងរយៈពេលវែង ក៏ដូចជាឧបសគ្គដល់ការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍវិស័យអធិការកិច្ច។

-កិច្ចសហការរវាងអង្គភាពផ្ដល់ការបណ្ដុះបណ្ដាល (វិទ្យាស្ថានជាតិអធិការកិច្ច) និងអង្គភាពទទួលការបណ្ដុះបណ្ដាលនៅមានកម្រិតនៅឡើយ ជាពិសេសទាក់ទងនឹងការចាត់បញ្ជូនមន្ត្រីមកចូលរៀន។

-ការបណ្ដុះបណ្ដាល និងការងារទំនាក់ទំនងត្រូវបានផ្អាកជាបណ្ដោះអាសន្នដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។

-ចរន្តការងារទំនាក់ទំនង របស់ក្រសួងមកវិទ្យាស្ថានជាតិអធិការកិច្ចនៅមានការយឺតយ៉ាវ និងពេលខ្លះត្រូវបំភ្លេចមិនបានទទួលព័ត៌មានតែម្ដង ។

# ផ្នែកទី ៣. ទិសដៅការងារឆ្នាំ ២០២២



ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យស្របតាមតួនាទី ភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

### ១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ត្រៀមទូទាត់លើការប្រើប្រាស់អគ្គិសនី ទឹក ទូរស័ព្ទ តាមវិក័យបត្រជាក់ស្តែងជូនថ្នាក់ដឹកនាំ។

-បន្តពិនិត្យ និងចូលរួមយោបល់ទាក់ទងតម្រូវការចំណាយផ្សេងៗក្នុងក្រសួង។

-ត្រៀមរៀបចំទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែ ឆ្នាំ ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំជានាចំណាយប្រេងឥន្ធនៈប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសម្ភារថែទាំអគារ និងថែទាំសម្ភារឧបករណ៍ប្រចាំ ឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ ជានាចំណាយសង្ហារិម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំនាយសម្ភារ និងឧបករណ៍ដឹកជញ្ជូនប្រចាំ ឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយការងារ ជួសជុលលាបថ្នាំបន្ទប់អគារទីស្តីការក្រសួង (ABC) និងជួសជុលស្តាបនាអគារឱ្យសន្តិសុខស្នាក់នៅប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយការងារជួសជុល និងមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២២។

-ត្រៀមបែងចែកប្រេងឥន្ធនៈ ដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-ត្រៀមរៀបចំបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ ដឹកនាំគ្រប់នាយកដ្ឋាន។

-ត្រៀមបែងចែកសម្ភារអនាម័យតាមបណ្តានាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ត្រៀមរៀបចំបែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមនាយកដ្ឋាន។

-ត្រៀមរៀបចំការងារជួសជុលសម្ភារការិយាល័យ ជួសជុលអគារការិយាល័យគ្រឿងយន្ត និងបរិក្ខាបច្ចេកទេស ក្នុងទីស្តីការក្រសួង។

**១-៤-ការងារផែនការ និងស្ថិតិ**

-បន្តរៀបចំស្ថិតិផ្លូវការដែលមានការចាត់តាំង តាមវិស័យរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តកែសម្រួលនូវទម្រង់របាយការណ៍លទ្ធផលនៃការអនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្ត របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យកាន់តែប្រសើរឡើង ដើម្បីឈានទៅអនុវត្តថវិកាសមិទ្ធកម្មនាពេលឆាប់ៗ។

-ត្រៀមរៀបចំគម្រោងផ្សេងៗដែលជាប្រតិបត្តិការ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យមានសុក្រិត្យភាព និងតម្លាភាព។

-ត្រៀមលក្ខណៈបំពេញការងារស្នូលរបស់នាយកដ្ឋានសម្រាប់ឆ្នាំ២០២២។

-ត្រៀមសហការរាល់ការងារដែលពាក់ព័ន្ធអង្គភាព និងស្ថាប័នផ្សេងៗ។

-គ្រោងចងក្រងជាសៀវភៅនូវរាល់ឯកសារ និងគម្រោងផ្សេងៗរៀបចំដោយនាយកដ្ឋានផែនការ និងស្ថិតិ។

-បន្តសិក្សាស្រាវជ្រាវអំពីទម្រង់ និងបែបបទនៃការរៀបចំថវិកាសមិទ្ធកម្ម នាឆ្នាំខាងមុខ។

**១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ**

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-រៀបចំកិច្ចប្រជុំបន្តពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-ចុះស្ទង់មតិប្រជាពលរដ្ឋនៅតាមខេត្តគោលដៅ។

-បន្តសិក្សាស្រាវជ្រាវអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បញ្ចូលក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចុះផ្សព្វផ្សាយច្បាប់តាមខេត្តគោលដៅ។

-ផលិតវីដេអូផ្សព្វផ្សាយច្បាប់ សម្រាប់ផ្សព្វផ្សាយតាមទូរទស្សន៍ និងបណ្តាញសង្គម។

-ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃមុន និងក្រោយការផ្សព្វផ្សាយច្បាប់។

-ចុះរៀបំវេទិកាសាធារណៈតាមខេត្តគោលដៅ។

-ចុះស្ទង់មតិពីតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋនៅតាមខេត្តគោលដៅ។

-ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញ រដ្ឋសភា។

## ៣.ការងារអធិការកិច្ច

**៣.១.ការងារអធិការកិច្ចទី១** (**លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច**)

-ត្រៀមចុះធ្វើអធិការកិច្ច លើការអនុវត្តតួនាទីភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈក្នុងការិយបរិច្ឆេទ២០២០ នៅក្រសួងចំនួន២ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គភាពក្រោមឱវាទ។

-ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ ក្រសួងបរិស្ថាន សាលារាជធានីភ្នំពេញ សាលា

ខេត្តកោះកុង សាលាខេត្តកំពង់ស្ពឺ សាលាក្រុង ស្រុក ខណ្ឌ ចំណុះ និងអង្គភាពក្រោមឱវាទពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០។

-ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២០ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរ អង្គភាពក្រោមឱវាទ។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២២។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.២.ការងារតាមដានការអនុវត្តច្បាប់**

-ត្រៀមចុះតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចំនួន៦ ដែលមិនទាន់បានអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០២១ រួមមានៈច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ១៤៦អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច ប្រកាសលេខ០៨៧ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី និងតាមដានការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២២។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មាន។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២២។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ៤.ការងារសវនកម្មផ្ទៃក្នុង

បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

### ៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

៥.១.១. អភិវឌ្ឍ និងពង្រឹងសមត្ថភាពស្ថាប័ន

-ពង្រឹងសមត្ថភាពមន្ត្រីវិទ្យាស្ថានបន្ថែមលើជំនាញពាក់ព័ន្ធ ដើម្បីបំពេញការងារ ឱ្យកាន់តែមានប្រសិទ្ធភាព។

-បន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារជាប្រចាំ។

-ស្នើសុំមធ្យោបាយធ្វើដំណើររបស់វិទ្យាស្ថាន។

-ស្នើសុំក្របខណ្ឌមន្ត្រីរាជការបន្ថែមសម្រាប់វិទ្យាស្ថាន។

-ស្នើសុំមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតសម្រាប់វិទ្យាស្ថាន។

-កែលម្អរបៀបរបបបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។

-បង្កើត និងផ្តល់ការបណ្តុះបណ្តាលដល់ក្រុមគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ច។

### ៥.១.២. ពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ

-ស្នើសុំបង្កើតអង្គភាពថវិកាវិទ្យាស្ថានជាតិអធិការកិច្ចដើម្បីសម្រួល និងពន្លឿនចរន្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

-ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងបុគ្គលិក និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ។

-ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

## ៥.២. ការងារផែនការ និងស្រាវជ្រាវ

### ៥.២.១. ពង្រឹងការគ្រប់គ្រងផែនការ

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣របស់វិទ្យាស្ថាន។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំ២០២២ និងឆ្នាំ២០២៣។

-បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

### ៥.២.២. ពង្រឹងការគ្រប់គ្រងការសិក្សាស្រាវជ្រាវ

-ស្រាវជ្រាវ និងចងក្រងអនុសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រី។

-ស្រាវជ្រាវ និងប្រមូលផ្តុំឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-តាមដានអំពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារមន្ត្រីរាជការ ដែលទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

-សិក្សាស្រាវជ្រាវ និងស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ច។

## ៥.៣. ការងារបណ្តុះបណ្តាល

### ៥.៣.១. អភិវឌ្ឍធនធានមនុស្ស បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

-ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចដល់មន្ត្រីរាជការក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួង ស្ថាប័ននានា។

-រៀបចំកែលម្អកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣។

-រៀបចំការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សាបច្ចេកទេស/ឯកទេស។

### ៥.៤. ការងារទំនាក់ទំនងសាធារណៈ

#### ៥.៤.១. ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាស្ថានទូតនានា។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា។

#### ៥.៤.២. ពង្រឹងការគ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យ

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

-រៀបចំបង្កើតរោងពុម្ព និងបោះពុម្ពឯកសារ។

#### ៥.៤.៣. កិច្ចការផ្សេងៗទៀត

-បន្តចូលរួមផ្សព្វផ្សាយក្នុងផេករបស់វិទ្យាស្ថាននូវសេចក្ដីណែនាំ វិធានការ និងលិខិតបទដ្ឋាននានារបស់ក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងការការពារ និងបង្ការការចម្លងជំងឺកូវីដ-១៩ ព្រមទាំងវិធានការ ៣ការពារ ៣កុំ របស់រាជរដ្ឋាភិបាល។

-បន្តផ្ដល់ព័ត៌មាន ណែនាំ និងក្រើនរំលឹកមន្ត្រីរាជការនៃវិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីទប់ស្កាត់ និងការពារការឆ្លងជំងឺកូវីដ-១៩។

-អនុវត្តការងារផ្សេងៗ តាមការណែនាំ និងចង្អុលបង្ហាញពីថ្នាក់ដឹកនាំក្រសួង។

## ៦.ការងារផ្សេងៗ

### ៦.១.ការងារយេនឌ័រ

-បន្តផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ១១ ចំណុច របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី។

-ជំរុញការបង្កើនបរិមាណ និងសមត្ថភាពស្ត្រីក្នុងការធ្វើសេចក្ដីសម្រេច និងភាពជាអ្នកដឹកនាំ។

-រៀបចំវេទិកាសាធារណៈ ស្ដីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-អនុវត្តផែនការបញ្ជ្រាបយេនឌ័រឆ្នាំ២០២២។

-បន្តយកចិត្តទុកដាក់សួរសុខទុក្ខមន្ត្រីរាជការជាស្ត្រី និងជួយឱ្យទាន់ពេលវេលាដោយផ្ដល់ជាសម្ភារ ឬថវិកា ដោយផ្ទាល់ឬតាមប្រព័ន្ធផ្ទេរលុយរឺងក្នុងករណីមានជំងឺ ឬសម្រាលមាតុភាព។

-អនុវត្តតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

### ៦.២.ការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាព ជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្ដល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើន

ជីវភាព រស់នៅរបស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

**៦.៣.ការងារសមាគមសង្គហមិត្តភាព**

-បន្តទទួលសមាជិក សមាជិកាថ្មី ក្នុងសមាគមសង្គហមិត្តភាពក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តទទួលថវិកាពីសមាជិក សមាជិកា ដើម្បីយកមកដំណើរការសមាគមសង្គហមិត្តភាព ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**៦.៤.ការងារក្រុមការងារ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

-បន្តប្រជុំ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅគ្រប់ដំណាក់កាល។

-បន្តរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តដែលថ្នាក់ដឹកនាំប្រគល់ជូន។

-ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាអាទិភាពដែលបានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-ត្រៀមចូលរួមប្រជុំជាមួយបណ្តាក្រសួង ស្ថាប័ន តាមការចាត់តែងរបស់ថ្នាក់ដឹកនាំក្រសួង ដើម្បីការពារនូវតួនាទី ភារកិច្ចរបស់ក្រសួង។

**៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង**

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួង ក្នុងឆ្នាំ២០២២។

**៦.៦.ការងារគេហទំព័រ** MONASRI.GOV.KH **និង** MONASRI App

-បន្តតាមដានការចុះផ្សាយព័ត៌មាននៅក្នុងទំព័រហ្វេសប៊ុកសំខាន់ទាំង៣ ដើម្បីស្រង់បញ្ចូលក្នុងគេហទំព័រឱ្យបានទាន់ពេលវេលា។

-បន្តត្រួតពិនិត្យ និងរក្សាទុកទិន្នន័យដែលមាននៅក្នុងគេហទំព័រកន្លមកជាប់ជាប្រចាំ។

-ជំរុញការផ្សព្វផ្សាយព័ត៌មានពីគេហទំព័រទៅកាន់បណ្តាញសង្គមដូចជា Facebook WhatsApp និង Telegram។

-រក្សាទំនាក់ទំនងជាមួយក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ ដើម្បីសម្រួលការងារផ្នែកបច្ចេកទេស និងអភិវឌ្ឍគេហទំព័រឱ្យកាន់តែមានសុវត្ថិភាព។

-ត្រៀមរៀបចំ និងធ្វើបច្ចុប្បន្នភាពគេហទំព័រឱ្យកាន់តែមានភាពទាក់ទាញ និងងាយស្រួលប្រើប្រាស់។

**៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** FMIS

- ត្រៀមអនុវត្តផែនការរួមដំណាក់កាលទី៣ បូក២ ឆ្នាំ២០២២ ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅដែល បានដាក់ចេញ។
- ត្រៀមបញ្ចូលលាភការ និងប្រាក់បេសកកម្មទៅក្នុងគណនីឯកជននឹងត្រូវអនុវត្តនៅពេលសមស្រប។

- ត្រៀមអនុវត្តអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ នៅពេលដែលសមស្រប។
- កសាងសមត្ថភាពសម្រាប់អង្គភាពថវិកាទាំងបីដើម្បីមានសមត្ថភាពេញលេញ ក្នុងការអនុវត្តជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ។
- ត្រៀមអនុវត្តជំហានបន្ទាប់នៃការអនុវត្តយុទ្ធសាស្រ្តថវិកា (ថវិកាផ្អែកលើសមិទ្ធកម្ម)

# ផ្នែកទី៤. សេចក្តីសន្និដ្ឋាន



នៅឆ្នាំ ២០០២១ ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព និងជោគជ័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ក្តី។ សមិទ្ធផលការងារ ដូចបានរៀបរាប់ខាងដើមបានមកដោយសារមានការដឹកនាំ ប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង និងវាងវៃ របស់លោកជំទាវឧបនាយករដ្ឋមន្រ្តី និងដោយសារថ្នាក់ដឹកនាំ មន្រ្តី មានសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ និងមានការយល់ដឹងផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ជាការពិត បុគ្គល និងស្ថាប័នមួយចំនួនមានចេតនាមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសក្រុមការងារអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសារ បញ្ហាផលប្រយោជន៍។ ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួន យល់ថាក្រសួងមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នាជាមួយស្ថាប័នគេ ដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ និងអគ្គាធិការដ្ឋាននៃក្រសួងស្ថាប័នមួយចំនួនទៀត។ម្យ៉ាងទៀតការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ចមួយចំនួនតូចនៅមានការខ្វះខាតខ្លះ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយធានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាព ជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានតម្រង់ទិស និងណែនាំឱ្យក្រសួងស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួនស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានធ្វើឱ្យតួនាទីភារកិច្ចការទទួលខុសត្រូវរបស់ក្រសួងមានសារៈសំខាន់ និងរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង។

លើសពីនេះក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យអាស្រ័យដោយមានការដឹកនាំ ប្រកបដោយភាពឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែគាំទ្ររាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពារលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

យើងសង្ឃឹមថា ក្នុងឆ្នាំ២០២២ ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

# ផ្នែកទី ៥. ឧបសម្ព័ន្ធ



# ឧបសម្ព័ន្ធ ទី១. កម្មវិធីសន្និបាត

## កម្មវិធី

**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និង ទិសដៅការងារ ឆ្នាំ២០២២**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២
សណ្ឋាគារ សុខាភ្នំពេញ (វិថីកែវ ចិន្តា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ)

| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
|---|---|---|
| **ពេលព្រឹក** | | |
| ៧.០០ - ៨.០០ | សមាជិក សមាជិកា សន្និបាតមកដល់ និងចុះឈ្មោះ | |
| ៨.០០ - ៨.៣០ | គណៈអធិបតីអញ្ជើញដល់ | |
| **ពិធីបើកសន្និបាត** | | |
| ៨.៣០ - ៩.៣០ | - ប្រកាសហេតុ<br>- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកដោយឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ<br>-របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ ក្រសួងទរពអ អានដោយ ឯកឧត្តម **ប៉ែន ច័ន្ទសុខរិន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ | -ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ៩.៣០ - ៩.៤៥ | សម្រាក ពិសាភេសជ្ជៈ និងអាហារសម្រន់ | |
| **ដំណើរការសន្និបាតដឹកនាំដោយឯកឧត្តម ឆេង សារឿន រដ្ឋលេខាធិការប្រចាំការ** | | |
| ៩.៤៥ - ១១.០០ | -ចំណាប់អារម្មណ៍ របស់មន្ទីរទរពអ រាជធានី ខេត្ត<br>-ចំណាប់អារម្មណ៍ របស់នាយកដ្ឋាន វិទ្យាស្ថានជាតិ អធិកិច្ច (ថ្នាក់កណ្តាល) | -ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១១.០០- ១១.៣០ | ពិភាក្សាលើរបាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ ក្រសួងទរពអ | -ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១១.៣០- ១៣.៣០ | សម្រាកអាហារថ្ងៃត្រង់ Buffet នៅសណ្ឋាគារសុខាភ្នំពេញ | |
| | | |

| **ពេលរសៀល** | | |
|---|---|---|
| ១៤.០០- ១៤.៣០ | ពិភាក្សាលើរបាយការណ៍ (បន្ត) | -លោកជំទាវ កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៤.៣០-១៥.១៥ | - បទបង្ហាញរបស់ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមិទ្ធផល និងការរំពឹងទុករបស់ក្រសួង ទ.រ.ព.អ | -លោកជំទាវ កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៥.១៥-១៥.៤៥ | ការពិភាក្សាលើបទបង្ហាញ | |
| ១៥.៤៥ - ១៦.០០ | សម្រាកពិសាភេសជ្ជៈ និងអាហារសម្រន់ | |
| **ពិធីបិទសន្និបាត** | | |
| ១៦.០០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ១៦.០០-១៦.១៥ | - របាយការណ៍បូកសរុបលទ្ធផលសន្និបាតដោយ ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៦.១៥- ១៦.៤៥ | -សុន្ទរកថាបិទសន្និបាត ដោយលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៦.៤៥-១៧.០០ | -ពិធីបំពាក់មេដាយ-គ្រឿងឥស្សរិយយស | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ |
| ១៧.០០ | -គោរពភ្លេងជាតិបិទកម្មវិធី។ | |

***កំណត់សំគាល់៖***

១) គណៈកម្មាធិការរៀបចំសន្និបាតសូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់។

២) សម្លៀកបំពាក់៖ បុរសៈ អាវធំ ក្រវ៉ាត់ក នារីៈ ប្រពៃណី។

៣) សូមទាក់ទងទូរស័ព្ទ ឯកឧត្តម កឹម សុខជា៖ ០១៧៤៦៩៦៩៩ និង លោក ស្រ៊ុន សារ៉ន៖ ០៨៩៧២៩២៩២

## ឧបសម្ព័ន្ធ ទី២. របាយការណ៍សង្ខេប

**របាយការណ៍សង្ខេប**
**ស្ដីពី**
**ការបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

ក្នុងឆ្នាំ២០២១ នេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវសមិទ្ធផលនានា ជាច្រើនដូចខាងក្រោម៖

## ផ្នែកទី១-សមិទ្ធផលការងារ

### ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

#### ១-១-ការងាររដ្ឋបាល

-បានទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន១,០៥២ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន ៦៧៨ ច្បាប់។

-បានរៀបចំ និងបញ្ជូនសារលិខិតថ្វាយព្រះពរ-ជូនពរ ចូលរួមទទួលជួបសម្ដែងការគួរសមរវាងភ្ញៀវជាតិ-អន្តរជាតិជាមួយថ្នាក់ដឹកនាំក្រសួង បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស រយៈពេល ៩ខែ ប្រចាំឆ្នាំ រយៈពេល៥ឆ្នាំ លិខិតបង្គាប់ការចាត់មន្ត្រីរាជការចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ ធ្វើសេចក្ដីជូនដំណឹង ស្ដីពីពិធីបុណ្យសព ធ្វើសារលិខិតរំលែកទុក្ខ ធ្វើអត្តសញ្ញាណប័ណ្ណជូនមន្ត្រីរាជការ ចុះលេខលិខិតដែលមានការសម្រេចរួចរាល់ពីថ្នាក់ដឹកនាំក្រសួង និងថតចម្លងរាល់ឯកសារជូនថ្នាក់ដឹកនាំក្រសួង។

-បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-បានត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-បានចូលរួមប្រជុំនៅទីស្ដីការក្រសួង និងក្រសួងស្ថាប័នផ្សេង ពាក់ព័ន្ធនឹងការងារផ្សេងៗចំនួន ២១លើក។

#### ១.២.ការងារបុគ្គលិក និងធនធានមនុស្ស

-បានធ្វើសេចក្ដីសម្រេច សេចក្ដីជូនដំណឹង ប្រកាសស្ដីពីការតែងតាំងមន្ត្រីរាជការ ប្រកាសស្ដីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ប្រកាសស្ដីពីការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការ ប្រកាសស្ដីពីការអនុញ្ញាត

ឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ និងធ្វើលិខិតផ្សេងៗពាក់ព័ន្ធនឹងការងារបុគ្គលិក និងធនធានមនុស្ស។

*ការងារបណ្តុះបណ្តាល

-បានចាត់មន្ត្រីរាជការចំនួន៩៥រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ នៅក្នុងប្រទេស។

### ១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-បានទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជា ថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

### ១.៤.ការងារផែនការ និងស្ថិតិ

-បានរៀបចំគម្រោងវិនិយោគសាធារណៈ៣ឆ្នាំរំកិល របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) គម្រោងថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ចងក្រងជាសៀវភៅថវិកាសម្រាប់គ្រប់គ្រង ឆ្នាំ២០២២ សៀវភៅផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ចងក្រងទិន្នន័យ ស្ថិតិផ្លូវការ ដែលបានចាត់តាំងទៅតាមវិស័យ ចងក្រងទិន្នន័យស្ថិតិទូទៅ ប្រចាំឆ្នាំ២០២១ ចងក្រងសៀវភៅ ស្ថិតិផ្លូវការ ដែលបានចាត់តាំងទៅតាមវិស័យ ចងក្រងឯកសារពាក់ព័ន្ធការងារតាមដាន-វាយតម្លៃរបស់នាយកដ្ឋាន បូកសរុបរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ចូលរួមវគ្គបណ្តុះបណ្តាលគោលការណ៍ ណែនាំ ស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។

-បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការងារជំនាញ និងការងារផ្សេងៗចំនួន៦លើកក្នុងនោះតាមប្រព័ន្ធអនឡាញចំនួន៤លើក។

### ១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ

-បានសម្របសម្រួលជាមួយស្ថានទូតអូស្ត្រាលី និងបកប្រែលិខិតស្តីពីការជួបសម្តែងការគួរសមរវាងឯកឧត្តមអនុប្រធានបេសកកម្ម Zurbrugg និងឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជាមួយថ្នាក់ដឹកនាំក្រសួង។

-បានចូលរួមកិច្ចប្រជុំអន្តរក្រសួង នៃគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា-វៀតណាម (JC) លើកទី១៨ ឆ្នាំ២០២០(JC)លើកទី១៩ ឆ្នាំ២០២១ និងទទួលកំណត់ហេតុពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្តីពីកិច្ចប្រជុំអន្តរក្រសួង នៃគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា-វៀតណាម (JC) លើកទី១៨ ឆ្នាំ២០២០។

-បានចូលរួមកិច្ចប្រជុំជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ (JC) លើកទី១៩ និងសេចក្តីព្រាងសេចក្តីប្រកាសរួមក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បានចូលរួមកិច្ចប្រជុំពេញអង្គដើម្បីពិភាក្សា លើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ (JC) លើកទី ១៩ និងសេចក្តីព្រាងសេចក្តីប្រកាសរួមក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមបណ្តុះបណ្តាលស្តីពីជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ តាមប្រព័ន្ធវីដេអូConference ដែលមានរយៈពេល៣សប្តាហ៍។

-បានបកប្រែលិខិតចំនួន១១ច្បាប់។

## ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក តាមប្រព័ន្ធ Zoom។

-បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក នៅទីស្តីការក្រសួង។

-បានចូលរួមសិក្ខាសាលាពាក់ព័ន្ធនឹងការងារផ្សេងៗតាមប្រព័ន្ធអនឡាញចំនួន៤លើក។

-បានបញ្ចូលអត្ថបទច្បាប់ចំនួន៨០ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

-បានចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ចំនួន ៨ លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភាចំនួន៤លើក និងមន្ទីររាជធានី-ខេត្តចំនួន៤លើក) គឺច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាចំនួន៤លើក(ខេត្តមណ្ឌលគិរីចំនួន១លើក រតនគិរីចំនួន១លើក កំពង់ចាមចំនួន១លើក និងខេត្តពោធិ៍សាត់ចំនួន ១លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៣លើក (ខេត្តកំពតចំនួន ៣លើក) និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១លើក(ខេត្តកំពង់ធំចំនួន១លើក) ដោយមានអ្នកចូលរួមចំនួន១,៣៣២នាក់ (ស្ត្រីចំនួន៥៥៧នាក់)។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-បានចុះផ្សព្វផ្សាយច្បាប់ចំនួន៧៣លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៥លើក និងមន្ទីររាជធានី-ខេត្តចំនួន៦៨លើក) គឺច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ១៥ លើកនៅខេត្តចំនួន៧ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១២លើកនៅខេត្តចំនួន៦ ច្បាប់ភូមិបាលចំនួន ១ លើកនៅខេត្តចំនួន១ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចំនួន ១ លើកនៅខេត្តចំនួន១ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ៣ លើកនៅខេត្តចំនួន១ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺ

ឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន១២លើកនៅខេត្តចំនួន៥ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន១៤លើកនៅខេត្តចំនួន១ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំនួន១៥លើកនៅខេត្តចំនួន២ ដោយមានអ្នកចូលរួមចំនួន៦,៧៩៧នាក់(ស្ត្រីចំនួន២,៨៥៩នាក់) និងបានទទួលសំណួរចំនួន៥២៥សំណួរ។

-បានចុះចែកឯកសារច្បាប់ចំនួន១៧លើក គឺច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១៦លើក និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាចំនួន១លើក ជូនក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីផ្សព្វផ្សាយបន្ត ដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងខេត្តក្រចេះ ចំនួន២,០១៥ច្បាប់។

-បានរៀបចំកម្មវិធីថតវិឌីអូផ្សព្វផ្សាយច្បាប់ សម្រាប់ផ្សព្វផ្សាយ តាមរយៈទូរទស្សន៍ និងតាមបណ្តាញសង្គម ដោយសហការជាមួយស្ថានីយទូរទស្សន៍អប្សរាប៉ុស្តិ៍លេខ១១ ដែលក្នុងនោះរួមមាន៖ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីសញ្ជាតិ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អនុក្រឹត្យស្តីពីការគ្រប់គ្រងជីរដ្ឋ ច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ភូមិបាល(ប្រធានបទ៖សម្បទានដីសង្គមកិច្ច និងកម្មសិទ្ធិឯកជន) ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីអស្សាមិករណ៍។

-បានរៀបចំផ្សព្វផ្សាយសេចក្តីជូនដំណឹង សារាចរណែនាំ និងវិធានការ តាមរយៈវិទ្យុជាតិ ភ្នំប្រុស ភ្នំស្រី និងផេកមន្ទីរព័ត៌មានខេត្តកំពង់ចាមរួមមាន៖ អំពីការអប់រំអនុវត្តវិធានការ ៣ ការពារ ៣ កុំចំនួន ១៨០លើក អំពីការជំរុញឱ្យកុមារ និងយុវវ័យមានអាយុពី១២ឆ្នាំដល់ក្រោម១៨ឆ្នាំ ទៅទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួន១២០លើក អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន សេចក្តីជូនដំណឹងស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០២១ និងស្តីពីការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០២១ សេចក្តីជូនដំណឹងស្តីពីការចូលរួមរបស់អាជ្ញាធរក្នុងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ

ចំនួន ២៤០ លើក និងសេចក្តីជូនដំណឹងស្តីពីការពិន័យអន្តរកាលចំពោះអ្នកបើកបរយានយន្តធុនស្រាល និងធុនធ្ងន់ដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន២១០លើក។

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

-បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីលើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន២លើក សេចក្តីព្រាងច្បាប់ចំនួន១១លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៣១លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំនួន ២លើក។

### ២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភាលើសេចក្តីព្រាងច្បាប់ចំនួន១៨ លើក ព្រះរាជសារចំនួន១លើក របាយការណ៍របស់រដ្ឋសភាចំនួន១លើក ការបោះឆ្នោតជ្រើសតាំងចំនួន៥លើក ការសម្រេចអំពីសុពលភាពចំនួន២លើក និងបោះឆ្នោត ផ្តល់សេចក្តីទុកចិត្តចំនួន ២ លើក។

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញ របស់ព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ចំនួន១៨លើក របាយការណ៍របស់ព្រឹទ្ធសភាចំនួន១លើក ការប្រកាសទទួលស្គាល់ចំនួន ១លើក និងការបោះឆ្នោតជ្រើសរើសចំនួន១លើក។

### ២.៥.ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

-បានរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ ដោយអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល គឺពាក់ម៉ាស លាងដៃនឹងអាកុល និងរក្សាគម្លាតសុវត្ថិភាពក្នុងពេលបំពេញការងារចំនួន៤លើក (ខេត្តស្វាយរៀងចំនួន១លើក តាកែវចំនួន១លើក កំពតចំនួន១លើក និងខេត្តកែបចំនួន១លើក) ដោយមានអ្នកចូលរួមចំនួន៦១០នាក់(ស្ត្រីចំនួន១៩៥នាក់)។

## ៣.សកម្មភាពការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ នៅក្រសួងសាធារណការ និងដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ក្នុងការងារស្តារ សាងសង់ ជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រ និងការប្រើប្រាស់ប្រេងអន្តរាគមន៍ នៅក្រសួងធនធានទឹក និងឧតុនិយម មន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ ២០១៨។

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ក្នុងការងារស្តារ សាងសង់ ជួសជុល ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ផ្លូវលំជនបទ នៅក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

### ៣.២.ការងារអធិការកិច្ចលើវិស័យរដ្ឋបាលទូទៅ

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំ ហេដ្ឋារចនាសម្ព័ន្ធ នៅតាមបណ្តាសាលាខេត្ត សាលាក្រុង ស្រុក មន្ទីរ អង្គភាពពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅខេត្តកណ្តាល បាត់ដំបង និងខេត្តកំពង់ចាម។

-របាយការណ៍ទទួលពីបណ្តាក្រសួងចំនួន៤ គឺក្រសួងការពារជាតិចំនួន១០លើក ក្រសួងវប្បធម៌និងវិចិត្រសិល្បៈចំនួន៦លើក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១លើក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១លើក។

-របាយការណ៍ជូនជ្រាបតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន ១៧ គឺមន្ទីរទរពអខេត្តកែបចំនួន១៦លើក មន្ទីរទរពអខេត្តពោធិ៍សាត់ចំនួន១៥លើក មន្ទីរទរពអខេត្តកោះកុងចំនួន១៥លើក មន្ទីរទរពអខេត្តបាត់ដំបងចំនួន១៤លើក មន្ទីរទរពអខេត្តស្វាយរៀងចំនួន១៤លើក មន្ទីរទរពអខេត្តក្រចេះចំនួន១៣លើក មន្ទីរទរពអខេត្តកំពតចំនួន១៣លើក មន្ទីរទរពអខេត្តកំពង់ស្ពឺចំនួន ១២ លើក មន្ទីរទរពអរាជធានីភ្នំពេញចំនួន១២លើក មន្ទីរទរពអខេត្តត្បូងឃ្មុំចំនួន១១លើក មន្ទីរទរពអខេត្តកណ្តាលចំនួន១១លើក មន្ទីរទរពអខេត្តកំពង់ចាមចំនួន១០លើក មន្ទីរទរពអខេត្តរតនគិរីចំនួន១០ លើក មន្ទីរទរពអខេត្តតាកែវចំនួន៩លើក មន្ទីរទរពអខេត្តកំពង់ធំចំនួន៨លើក មន្ទីរទរពអខេត្តកំពង់ឆ្នាំងចំនួន ៤លើក និងមន្ទីរទរពអខេត្តព្រះសីហនុចំនួន៣លើក។

### ៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ នៅក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន និងមន្ទីររាជធានី-ខេត្ត ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

### ៣.៤.ការងារតាមដានការអនុវត្តច្បាប់

-បានចុះតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍៖

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ស្ពឺ។

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តក្រចេះ។

+ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ឆ្នាំង។

+អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការពិនិត្យស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការកាប់ទន្រ្ទានឈូសឆាយដីព្រៃលិចទឹក នៅតំបន់បឹងទន្លេសាប ស្ថិតក្នុងខេត្តកណ្តាល កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ និងខេត្តបន្ទាយមានជ័យ។

-បានចុះតាមដានការអនុវត្តច្បាប់(មន្ទីររាជធានី-ខេត្ត)៖

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ភូមិបាល អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដាឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅខេត្តឧត្តរមានជ័យ។

+ការគ្រប់គ្រងផ្សារ និងការប្រមូលចំណូលភាស៊ី នៅផ្សាររដ្ឋចំនួន៣ គឺផ្សារអូឡាំពិក ផ្សារទួលទំពូង និងផ្សារធំថ្មី នៅរាជធានីភ្នំពេញ។

+ការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅការិយាល័យអប់រំ យុវជន និងកីឡា និងបណ្តាវិទ្យាល័យនានា ក្នុងស្រុកអង្គរបូរី និងស្រុកកោះអណ្តែត ក្នុងខេត្តតាកែវ។

+ច្បាប់ស្តីពីវិធានសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកប ដោយគ្រោះថ្នាក់ផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅតាមអង្គភាពមានសមត្ថកិច្ចដែលឈរជើងនៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង និងការកាប់ទន្រ្ទានឈូសឆាយដីព្រៃលិចទឹកតំបន់២ និងតំបន់៣ នៃដែនបឹងទន្លេសាប នៅខេត្តបាត់ដំបង។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងចូលរួមជាមួយក្រុមការងាររបស់ក្រសួង និងរដ្ឋបាលខេត្តកំពង់ធំចុះពិនិត្យ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការកាប់ទន្រ្ទានឈូសឆាយដីព្រៃលិចទឹកនៅតំបន់៣ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ កិច្ចសន្យាភាស៊ី ចំណតរថយន្ត ចំណតទូក និងឡសត្តឃាត និងសិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី និងទឹកបរិសុទ្ធ នៅខេត្តស្វាយរៀង។

+អនុក្រឹត្យ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

+អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេរបស់រាជរដ្ឋាភិបាល នៅស្រុកដំណាក់ចង្អើរ ខេត្តកែប។

+ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ ការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិ ចូលរួមវាស់វែង និងកាត់ឆ្វៀលដីជូនប្រជាពលរដ្ឋ ចូលរួមចុះបង្ក្រាបបទល្មើសការកាប់រានដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យមើលការឈូសឆាយ និងកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស៊ីវហ្គេច អ៊ិនវេសមេន ចូលរួមចុះបង្ក្រាបបទល្មើសឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមចុះពិនិត្យទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ និងគ្រឿងចក្រ ខុសច្បាប់ ចូលរួមចុះពិនិត្យទីតាំងឈូសឆាយដីព្រៃខុសច្បាប់ ចូលរួមជាមួយក្រុមការងារថ្នាក់ខេត្តចុះវាស់វែងដីសង្គមកិច្ច និងស្រង់ស្ថិតិប្រជាពលរដ្ឋ ដែលរស់នៅអាស្រ័យផលលើដីបម្រុងខេត្ត ចូលរួមចុះពិនិត្យ និងវាស់វែងដីសំណង់ជូនក្រុមហ៊ុនហ៊ីវ៉ាយសិន អាហ្គ្រីខលឈ័រចំនួន៥,៦០២ហិកតា នៅស្រុកសេសាន-ស្រុកសៀមប៉ាង និងបានចូលរួមជាមួយក្រុមការងារចម្រុះថ្នាក់ខេត្តចុះត្រួតពិនិត្យ និងបង្ក្រាបសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ នៅខេត្តស្ទឹងត្រែង។

## ៣.៥.ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន១១៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៩បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៨៩បណ្តឹង)៖

-ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន ៧ បណ្តឹង (ឆ្នាំ២០២១ ចំនួន ៧ បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី-ខេត្តចំនួន៨០បណ្តឹង(ឆ្នាំ២០២១ ចំនួន ៨០ បណ្តឹង)។

-ពាក្យបណ្តឹង បានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន ១៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៣ បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៥បណ្តឹង ក្នុងនោះឆ្នាំ២០២១ ចំនួន១៨ បណ្តឹង)។

-ពាក្យបណ្តឹង ដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការ ចំនួន ១ បណ្តឹង (ឆ្នាំ ២០២១ ចំនួន ១ បណ្តឹង)។

-ពាក្យបណ្តឹង ដែលម្ចាស់បណ្តឹងសុំដកវិញចំនួន៣បណ្តឹង(មន្ទីររាជធានី-ខេត្តចំនួន៣បណ្តឹង គឺឆ្នាំ ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹង ដែលម្ចាស់បណ្តឹងបានបោះបង់ចោលចំនួន២បណ្តឹង (មន្ទីររាជធានី-ខេត្ត ចំនួន ២ បណ្តឹង គឺឆ្នាំ២០២១ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលបានធ្វើរបាយការណ៍ គោរពជូនឯកឧត្តម អភិបាល នៃគណៈអភិបាល ខេត្តកំពង់ស្ពឺ ពិនិត្យសម្រេចចំនួន ៤បណ្តឹង (មន្ទីររាជធានី-ខេត្តចំនួន៤បណ្តឹង គឺឆ្នាំ២០២១ ចំនួន ៤ បណ្តឹង)។

-ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួង ចំនួន ៤បណ្តឹង (ឆ្នាំ២០២០ ចំនួន៣បណ្តឹង ឆ្នាំ ២០២១ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន៤បណ្តឹង (ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន ៣ បណ្តឹង)។

-ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន ២៤ បណ្តឹង (អគ្គនាយកដ្ឋាន អធិការកិច្ចចំនួន ១២ បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១២បណ្តឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន ៨បណ្តឹង ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន ១៤ បណ្តឹង)។

-ពាក្យបណ្តឹងបានទទួលការឆ្លើយតបចំនួន ២បណ្តឹង (ឆ្នាំ២០២០ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយ ចំនួន៤បណ្តឹង (ឆ្នាំ២០១៦ ចំនួន ១បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង)។

-ពាក្យបណ្តឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន៥បណ្តឹង(ឆ្នាំ២០១៦ ចំនួន ១ បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹងបានបញ្ចប់ ការដោះស្រាយចំនួន ៦៣ បណ្តឹង (អគ្គនាយកដ្ឋាន អធិការកិច្ចចំនួន ២០បណ្តឹងនិងមន្ទីររាជធានី-ខេត្តចំនួន៤៣បណ្តឹង ក្នុងនោះឆ្នាំ២០១៤ ចំនួន២បណ្តឹង ឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៧ ចំនួន២បណ្តឹង ឆ្នាំ២០១៨ ចំនួន៣បណ្តឹង ឆ្នាំ២០១៩ ចំនួន ៨ បណ្តឹង ឆ្នាំ២០២០ ចំនួន១៦បណ្តឹង ឆ្នាំ២០២១ ចំនួន៣១បណ្តឹង)។

## ៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-ក្នុងរយៈពេល១២ខែឆ្នាំ២០២១នេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានទទួលលិខិតបញ្ជាបេសកកម្មពីសំណាក់ថ្នាក់ដឹកនាំក្រសួង ដើម្បីចុះធ្វើសវនកម្មក្នុងការិយបរិច្ឆេទ២០២០ នៅតាមទីសវនដ្ឋានចំនួន ៤ មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបង ប៉ៃលិន កំពង់ធំ និងខេត្តកែប តែដោយសារវិបត្តិនៃជំងឺកូវីដ-១៩ នាយកដ្ឋានសវនកម្មផ្ទៃ ក្នុងមិនទាន់បានចុះធ្វើសវនកម្មនៅឡើយ។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ១៦៨ អនក្រ. បក ដែលរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធZoom។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយឯកសារស្រាវជ្រាវ ទស្សនាទាន ស្តីពីនីតិវិធី សុខដុមនីយកម្មសវនកម្ម និងអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធ Zoom។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការដែលរៀបចំឡើងដោយអាជ្ញាធរសវនកម្មជាតិ តាមប្រព័ន្ធZoom។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បានពង្រឹងការគ្រប់គ្រងរដ្ឋបាល-ចរន្តការងារទូទៅ ប្រជុំតាមដានវឌ្ឍនភាពការងារប្រចាំខែមករាដល់ខែធ្នូ ឆ្នាំ២០២១ ប្រជុំបូកសរុបការងារឆ្នាំ២០២១ បង្កើតក្រុមស្រាវជ្រាវចងក្រងអនុសាសន៍របស់សម្តេចតេជោ ស្រាវជ្រាវ ចងក្រងអនុសាសន៍របស់សម្តេចតេជោសរុបចំនួន៨៧ច្បាប់ ប្រមូលផ្តុំឯកសារច្បាប់-លិខិតបទដ្ឋានគតិយុត្តនានាសរុបចំនួន១,៣៩៩ច្បាប់ ធ្វើសៀវភៅចំនួន៥៥ក្បាល។

-បានរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២២ កម្មវិធីបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ អធិការកិច្ចសម្រាប់ឆ្នាំ២០២២ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ បើកវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចជំនាន់៣ វគ្គ១ ដល់សិក្ខាកាមចំនួន៤៥នាក់ របាយការណ៍សមិទ្ធកម្មធមាសទី១-ប្រចាំឆ្នាំ ២០២១ របាយការណ៍លទ្ធផលការងារពាក់កណ្តាលអាណត្តិពីខែមករា ឆ្នាំ២០១ ដល់ខែមិថុនា ឆ្នាំ២០២១ របាយការណ៍ប្រចាំខែមករាដល់ខែធ្នូ ឆ្នាំ២០២១ និងបញ្ជូនមន្ត្រីរាជការចំនួន៣ រូបរបស់វិទ្យាស្ថានទៅសិក្សានៅសាលាភូមិន្ទរដ្ឋបាល។

-បានបញ្ចប់សេចក្តីព្រាងស្តីពីការជ្រើសរើសសាស្ត្រាចារ្យ គ្រូឧទ្ទេស មន្ត្រីរាជការ និងនិស្សិត បញ្ចប់សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន និងបញ្ចប់សេចក្តីព្រាងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់វិទ្យាស្ថាន។

-បានផ្តល់ព័ត៌មាន ណែនាំ និងក្រើនរំលឹកមន្ត្រីរាជការនៃវិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីទប់ស្កាត់និងការពារការឆ្លងជំងឺកូវីដ-១៩ និងបានសម្របសម្រួលមន្ត្រីរាជការវិទ្យាស្ថាន បានចាក់វ៉ាក់សាំងកូវីដ-១៩ លើកទី១ លើកទី២ និងដូសជំរុញទាំងអស់គ្នា។

-បានផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួង និងវិទ្យាស្ថាន នៅក្នុងផេករបស់វិទ្យាស្ថានជាប្រចាំ និងចូលរួមផ្សព្វផ្សាយបន្តក្នុងផេករបស់វិទ្យាស្ថាននូវសេចក្តីណែនាំ វិធានការ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងការការពារ និងបង្ការការចម្លងជំងឺកូវីដ-១៩ ព្រមទាំងវិធានការ ៣ការពារ និង៣កុំ របស់រាជរដ្ឋាភិបាល។

## ៦.សកម្មភាពការងារផ្សេងៗ

### ៦.១.សកម្មភាពការងារយេនឌ័រ

-ស្ថានភាពស្ត្រីក្នុងមុខតំណែង នៅក្រសួងសម្រាប់ឆ្នាំ២០២១ មានភាពប្រែប្រួលដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រីចំនួន១រូបត្រូវបានតែងតាំងជារដ្ឋលេខាធិការ ចំនួន១៨រូបជាទីប្រឹក្សា ចំនួន១រូបជាប្រធានការិយាល័យ និងចំនួន៣រូបជាអនុប្រធានការិយាល័យ។ ទន្ទឹមនេះដែរ ថ្នាក់មន្ទីររាជធានី-ខេត្ត មន្ត្រីរាជការជាស្ត្រីត្រូវបានតែងតាំងជាអនុប្រធានមន្ទីរចំនួន១រូប ប្រធានការិយាល័យចំនួន៩រូប និងអនុប្រធានការិយាល័យចំនួន១៤រូប។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រីដែលមានមុខតំណែងថ្នាក់ក្រសួងមានប្រមាណ២៩% និងថ្នាក់មន្ទីររាជធានី-ខេត្តមានប្រមាណ២៧%។

-លោកជំទាវប្រធានក្រុមការងារបានចុះសួរសុខទុក្ខ និងបានចាត់តាំងប្រតិភូចុះសួរសុខទុក្ខស្ត្រីជាមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាសម្រាលមាតុភាពចំនួន៧នាក់ និងប្រគល់ជូនថវិកាឧបត្ថម្ភរបស់លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី ក្នុងម្នាក់ ចំនួន ៥០ម៉ឺនរៀល និងថវិការបស់ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងម្នាក់២០ម៉ឺនរៀល បន្ថែមលើប្រាក់ឧបត្ថម្ភរបស់ក្រសួង។

-ដើម្បីចូលរួមចំណែកគាំទ្រដល់សកម្មភាពបង្ការ ការពារនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឯកឧត្តម លីវ សុភក្ត្រា អនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមការងារបច្ចេកទេសយេនឌ័របានឧបត្ថម្ភម៉ាស់ពេទ្យ និងជែលលាងដៃ ជូនដល់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៥ខេត្ត ដោយមន្ទីរនីមួយៗទទួលបានម៉ាស់ពេទ្យចំនួន១០,០០០ម៉ាស់ និងជែលលាងដៃចំណុះ២៥០មីលីលីត្រ សរុបចំនួន ៩៦ដប។

-ក្រុមការងារបច្ចេកទេសយេនឌ័របានផ្អាកធ្វើពិធីផ្លូវការអបអរខួប លើកទី១១០ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២១ ប្រធានបទ «ស្ត្រី និងការអភិវឌ្ឍក្នុងបរិការណ៍កូវីដ១៩»។ ទោះជាមានការផ្អាកធ្វើពិធីក៏ដោយ ក៏ថ្នាក់ដឹកនាំក្រសួង ក៏ដូចជាក្រុមការងារបច្ចេកទេសយេនឌ័របានយកចិត្តទុកដាក់ រៀបចំផ្តល់ជូនថវិកា និងវត្ថុអនុស្សាវរីយ៍ ដល់ថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដោយលោកជំទាវកិត្តិសង្គហបណ្ឌិតបានឧបត្ថម្ភថវិកា របស់ឯកឧត្តម លីវ សុភក្ត្រា បានឧបត្ថម្ភម៉ាសពេទ្យ ដែលលាងដៃ និងសប្បុរសជនបានផ្តល់ក្រណាត់ប៉ាក់ ដោយម្នាក់ៗទទួលបានថវិកា៥ម៉ឺនរៀល ម៉ាសសុវត្ថិភាព១ប្រអប់ ដែលលាងដៃ១ដប និងក្រណាត់ប៉ាក់១អាវ។ ដោយឡែកមន្ត្រីជាប់កិច្ចសន្យាជាបុរសលោកជំទាវកិត្តិសង្គហបណ្ឌិតបានឧបត្ថម្ភថវិកា ម្នាក់៥ម៉ឺនរៀល។

-បានដោះស្រាយជូនមន្ត្រីជាអ្នកជំងឺចំនួន ២រូបចូលសម្រាកព្យាលបាលនៅមន្ទីរពេទ្យ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយមន្ទីរពេទ្យព្រះកេតុមាលា។

-បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រសួងកិច្ចការនារីចំនួន២លើក និងជាមួយក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីចំនួន២លើក និងចូលរួមប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រអន្តរក្រសួងប្រចាំឆ្នាំ២០២១ ចំនួន១លើក នៅសណ្ឋាគារភ្នំពេញ។

## ៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយកងកម្លាំងជួរមុខវរសេនាតូចនគរបាល ការពារព្រំដែនទឹក លេខ ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣។ ក្នុងឱកាសនោះ ក៏មានការឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគ និង ថវិកាមួយចំនួនដែលបានមកពីសប្បុរសជនគិតជាទឹកប្រាក់សរុបចំនួន៨០,២៨០,០០០រៀល និងប្រាក់ដុល្លារសហរដ្ឋអាមេរិកចំនួន១១,០០០ដុល្លារ។

## ៦.៣. សមាគមសង្គហមិត្តភាព

-ចាប់ពីខែឧសភា ឆ្នាំ២០១៨ ដល់ខែធ្នូ ឆ្នាំ២០២១ សមាជិក សមាជិកា សមាគមសង្គហមិត្តភាពមានចំនួន៥៨៩នាក់ ថ្នាក់កណ្តាលមានចំនួន១៤នាយកដ្ឋាន វិទ្យាស្ថានជាតិអធិការកិច្ច សមាជិកផ្សេងៗ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២៥រាជធានី-ខេត្ត។

-ក្នុងឆ្នាំ២០១៨ សមាជិក សមាជិកា មានចំនួន៥៨៩នាក់ ឆ្នាំ២០១៩ សមាជិក សមាជិកា មានចំនួន ៥២៣នាក់ ឆ្នាំ២០២០ សមាជិក សមាជិកា មានចំនួន ៤៣៧នាក់ និងឆ្នាំ២០២១ សមាជិក សមាជិកា មានចំនួន ២៤៤នាក់។ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ ចំនួនសមាជិក សមាជិកា ដែលមិនទាន់បានបង់វិភាគទាន ជូនសមាគមសង្គហមិត្តភាពក្នុងនោះថ្នាក់កណ្តាល មានចំនួន ៩ នាយកដ្ឋាន និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៦មន្ទីរ។

-សមាគមសង្គហមិត្តភាពក៏បានឧបត្ថម្ភប្រាក់ជូនដល់មន្ត្រីរាជការ និងក្រុមគ្រួសារមន្ត្រីរាជការដែរទទួលមរណភាពចំនួន៧លើករួមមាន៖ ថ្នាក់កណ្តាល និងមន្ទីរទេពអខេត្តស្វាយរៀង ព្រះសីហនុ កែប កំពង់ឆ្នាំង តាកែវ។

**៦.៤.សកម្មភាពក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាន គតិយុត្ត**

-បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក។

-បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក។

**៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង**

បានស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនក្រសួងចំនួន១៥៥នាក់។

**៦.៦.សកម្មភាពការងារក្រុមការងារសង្រ្គោះព័ត៌មាន និងខ្លឹមសារ អនុសាសន៍ របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់**

-សម្តេចតេជោ នាយករដ្ឋមន្ត្រី បានដាក់ចេញនូវអនុសាសន៍ជាបន្តបន្ទាប់សរុប ចំនួន ៩៩ អនុសាសន៍ និងឥស្សរជនជាន់ខ្ពស់ បានដាក់ចេញនូវអនុសាសន៍ជាបន្តបន្ទាប់សរុបចំនួន៤ គឺខែមករាបានដាក់ចេញនូវចំនួន៧អនុសាសន៍ ខែកុម្ភៈបានដាក់ចេញនូវចំនួន៨អនុសាសន៍ ខែមីនាបានដាក់ចេញនូវ ចំនួន ១៤ អនុសាសន៍ ខែមេសាបានដាក់ចេញនូវចំនួន២៦អនុសាសន៍ ខែឧសភាបានដាក់ចេញនូវចំនួន ១ អនុសាសន៍ ខែមិថុនាបានដាក់ចេញនូវចំនួន ៨អនុសាសន៍ ខែកក្កដាបានដាក់ចេញនូវចំនួន១អនុសាសន៍ ខែសីហាបានដាក់ចេញនូវចំនួន៦អនុសាសន៍ ខែកញ្ញាបានដាក់ចេញនូវចំនួន៣ អនុសាសន៍ ខែតុលាបាន ដាក់ចេញនូវចំនួន៥អនុសាសន៍ ខែវិច្ឆិកាបានដាក់ចេញនូវចំនួន១២ អនុសាសន៍ និងខែធ្នូបានដាក់ចេញនូវចំនួន ៨ អនុសាសន៍ និងលិខិតបទដ្ឋានគតិយុត្តសរុបចំនួន៥៩ គឺខែមករាចំនួន១២លិខិត ខែកុម្ភៈចំនួន៣លិខិត ខែមីនា ចំនួន៥លិខិត ខែមេសាចំនួន៧លិខិត ខែឧសភាចំនួន៧លិខិត ខែមិថុនាចំនួន៣លិខិត ខែកក្កដា ចំនួន ៥លិខិត ខែសីហាចំនួន៨លិខិត ខែកញ្ញាចំនួន២លិខិត ខែតុលាចំនួន៥លិខិត ខែធ្នូចំនួន២លិខិត។

**៦.៧.សកម្មភាពការងារគេហទំព័រ** MONASRI.GOV.KH **និង** MONASRI App

-បានធ្វើការចុះផ្សាយព័ត៌មាន និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងស្ថាប័នក្រោមចំណុះក្រសួង ចូលក្នុងគេហទំព័រជាប់ជាប្រចាំ។

-បានធ្វើការទាញរក្សាទុកទិន្នន័យនៅក្នុងគេហទំព័រជាប្រចាំ ដើម្បីរក្សាទុកទិន្នន័យទាំងអស់ដែលមាននៅក្នុងគេហទំព័រកន្លងមក។

-បានធ្វើបច្ចុប្បន្នភាព (update) ប្រព័ន្ធការពារមេរោគរបស់គេហទំព័រ ដើម្បីធានាបាននូវសុវត្ថិភាព។

-បានធ្វើការផ្សព្វផ្សាយព័ត៌មានពីគេហទំព័រទៅកាន់បណ្តាញសង្គមដូចជា Facebook និង Telegram។

## ៦.៨. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS

ក្រសួងបានអនុវត្តតាមផែនការសកម្មភាពដំណាក់កាលទី៣បូក២ ឆ្នាំ២០២១ ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធFMIS ដោយសម្រេចបានទលទ្ធផលដូចខាងក្រោម៖

-អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបានរៀបចំរបាយការណ៍ ប្រៀបធៀបផែនការចំណាយតាមកម្មវិធីប្រចាំត្រីមាស និងការអនុវត្តជាក់ស្តែង ដោយឆ្លុះបញ្ចាំងនូវគោលដៅចំណាយក្នុងត្រីមាសនីមួយៗ។

-ក្រសួងបានផ្សព្វផ្សាយ តាមរយៈសារព័ត៌មាននូវសេចក្តីជូនដំណឹង ស្តីពីការចូលរួមដេញថ្លៃរបស់អង្គភាពលទ្ធកម្ម។

-ក្រសួងបានទូទាត់ថវិការដ្ឋទេយ្យបុរេប្រទានប្រចាំត្រីមាសនីមួយៗ (ជុំទី១,២,៣,៤) បានទាន់ពេលវេលា។

-ក្រសួងបានពិនិត្យលទ្ធភាពបញ្ចូលប្រាក់បេសកកម្ម ក្នុងប្រព័ន្ធ ATM កំរិតថ្នាក់ដឹកនាំ (រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ) តែនៅមានបញ្ហាមួយចំនួនដែលនៅសេសសល់ និងមិនទាន់បានអនុវត្ត។

-បានចូលរួមបណ្តុះបណ្តាល (Online Meeting) ទាំងមន្ត្រីចាស់ មន្ត្រីថ្មីលើការអនុវត្តប្រព័ន្ធ FMISជាមួយក្រុមការងារ FMIS នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាច្រើនលើក។

-បានចូលរួមប្រជុំជាមួយគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុ សាធារណៈ (អ.គ.ហ) ចំនួន២១លើក។

-អង្គភាពលទ្ធកម្មបានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើន ថយប្រចាំឆ្នាំ២០២០ និងបានរៀបចំរបាយការណ៍ចំនួនមន្ទីរដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ។

-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ត្រូវបានអនុវត្តតាមប្រព័ន្ធគ្រប់គ្រង ទិន្នន័យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានពិនិត្យ និងវាយតម្លៃលក្ខណៈសម្បត្តិ របស់អង្គភាពថវិកាចំនួន៣ ដែលមិនទាន់ជាអង្គភាពអណាប័កផ្ទេរសិទ្ធិ និងត្រៀមការកសាងសមត្ថភាពមន្ត្រីជំនាញដើម្បីឈានទៅអនុវត្តបន្ត។

-គម្លាតនៃផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដែលអនុម័ត ត្រូវបានកាត់បន្ថយ។

-បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធី ប្រចាំត្រីមាសទី១,២,៣ និងទី៤ ហើយបានផ្ញើ ជូនអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាន់ពេលវេលា។

-បានរៀបចំកិច្ចប្រជុំវាយតម្លៃការអនុវត្តការងារពាក់កណ្តាលឆ្នាំ តាមរយៈ Zoom Meeting។

-ផែនការយុទ្ធសាស្ត្រអធិការកិច្ច ៣ឆ្នាំរំកិល ផែនការអធិការកិច្ចប្រចាំឆ្នាំ២០២២ ត្រូវបានបញ្ចប់ និងអនុម័ត។

-ផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំរំកិល និងផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២២ ត្រូវបានបញ្ចប់ និងអនុម័ត។

-មានតារាងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) និងតារាងតម្រូវការថវិកាសម្រាប់ការអនុវត្តឆ្នាំ២០២២ និងបានផ្ញើជូនអគ្គលេខាធិការគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈ ពិនិត្យ។

-បានរៀបចំកិច្ចប្រជុំស្តីពីការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពលម្អិតដំណាក់កាលទី៣ បូក២ តាមប្រព័ន្ធZoom Meeting។

-បានរៀបចំសេចក្តីសម្រេចការកែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្ញើជូនអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិនិត្យ និងវាយតម្លៃ។

-បានអនុម័តជាប្រចាំនូវឯកសារមួយចំនួនតាមប្រព័ន្ធ FMIS ដូចជាប្រាក់បៀវត្សរ៍មន្ត្រីរាជការ ការងារលទ្ធកម្ម រដ្ឋទេយ្យ ទឹក ភ្លើង ទូរស័ព្ទ និងធានាចំណាយផ្សេងៗទៀត។

-បានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ២០២១ ផ្ញើជូនទៅអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិនិត្យ។

## ផ្នែកទី២-បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

-ពុំទាន់មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចឱ្យបានគ្រប់គ្រាន់។

-កង្វះថវិកា កង្វះមធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារៈបច្ចេកវិទ្យាសមស្របសម្រាប់ចុះបំពេញបេសកកម្ម។

-ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-កិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាននៅមានកម្រិត។

-ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បណ្តាលឱ្យការងាររបស់ អគ្គនាយកដ្ឋាន អធិការកិច្ច ស្ទើរតែទាំងស្រុងត្រូវបានផ្អាកសកម្មភាពស្ទើរពេញ១ឆ្នាំ នាំឱ្យផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានអធិការកិច្ចមិនបានអនុវត្ត ជាហេតុធ្វើឱ្យការងារអធិការកិច្ច និងការងារតាមដានការអនុវត្តច្បាប់មិនសម្រេចបានលទ្ធផល។

-កិច្ចសហការរបស់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួនលើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវបណ្តឹងនៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខាលើលទ្ធផលអធិការកិច្ច។

-ពុំទាន់មានក្របខ័ណ្ឌមន្ត្រីរាជការគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងប្រសិទ្ធភាពការងាររបស់វិទ្យាស្ថាន និងសមត្ថភាពមន្ត្រីនៅមានកម្រិត។

-ពុំទាន់មានគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់ផ្តល់ការបណ្តុះបណ្តាល។

-ថវិកានៅមានកម្រិត ដែលជាឧបសគ្គដល់ការរៀបចំការបណ្តុះបណ្តាលឱ្យមានលក្ខណៈជាប្រព័ន្ធ និងរយៈពេលវែង ក៏ដូចជាឧបសគ្គដល់ការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍវិស័យអធិការកិច្ច។

-កិច្ចសហការរវាងអង្គភាពផ្តល់ការបណ្តុះបណ្តាល (វិទ្យាស្ថានជាតិអធិការកិច្ច) និងអង្គភាពទទួលការបណ្តុះបណ្តាលនៅមានកម្រិតនៅឡើយ ជាពិសេសទាក់ទងនឹងការចាត់បញ្ជូនមន្ត្រីមកចូលរៀន។

-ការបណ្តុះបណ្តាល និងការងារទំនាក់ទំនងត្រូវបានផ្អាកជាបណ្តោះអាសន្នដោយសារការរីករាលដាល នៃជំងឺកូវីដ-១៩។

-ចរន្តការងារទំនាក់ទំនងរបស់ក្រសួង មកវិទ្យាស្ថានជាតិអធិការកិច្ច នៅមានការយឺតយ៉ាវ ។

# ផ្នែកទី៣-ទិសដៅការងារឆ្នាំ ២០២២

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទីភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់គ្រងកំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យស្របតាមតួនាទី ភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

**១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-ត្រៀមទូទាត់លើការប្រើប្រាស់អគ្គិសនី ទឹក ទូរស័ព្ទ តាមវិក័យបត្រជាក់ស្តែងជូនថ្នាក់ដឹកនាំ។

-បន្តពិនិត្យ និងចូលរួមយោបល់ទាក់ទងតម្រូវការចំណាយផ្សេងៗក្នុងក្រសួង។

-ត្រៀមរៀបចំទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែ ឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំជានាចំណាយប្រេងឥន្ធនៈប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសម្ភារថែទាំអគារ និងថែទាំសម្ភារឧបករណ៍ប្រចាំ ឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសង្ហារិម និងសម្ភារប្រើប្រាស់ ប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសម្ភារ និងឧបករណ៍ដឹកជញ្ជូន ប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ ជានាចំណាយការងារជួសជុលលាបថ្នាំបន្ទប់អគារទីស្តីការ ក្រសួង (ABC) និងជួសជុលស្លាបនាអគារឱ្យសន្តិសុខស្នាក់នៅប្រចាំឆ្នាំ២០២២។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយការងារជួសជុល និងមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២២។

-ត្រៀមបែងចែកប្រេងឥន្ធនៈ ដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-ត្រៀមរៀបចំបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ ដឹកនាំគ្រប់នាយកដ្ឋាន។

-ត្រៀមបែងចែកសម្ភារអនាម័យតាមបណ្តានាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ត្រៀមរៀបចំបែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមនាយកដ្ឋាន។

-ត្រៀមរៀបចំការងារជួសជុលសម្ភារការិយាល័យ ជួសជុលអគារការិយាល័យគ្រឿងយន្ត និងបរិក្ខាបច្ចេកទេស ក្នុងទីស្តីការក្រសួង។

**១-៤-ការងារផែនការ និងស្ថិតិ**

-បន្តរៀបចំស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តកែសម្រួលនូវទម្រង់របាយការណ៍លទ្ធផលនៃការអនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្ត របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យកាន់តែប្រសើរឡើង ដើម្បីឈានទៅអនុវត្តថវិកាសមិទ្ធកម្មនាពេលឆាប់ៗ។

-ត្រៀមសហការរាល់ការងារដែលពាក់ព័ន្ធអង្គភាព និងស្ថាប័នផ្សេងៗ។

-បន្តសិក្សាស្រាវជ្រាវអំពីទម្រង់ និងបែបបទនៃការរៀបចំថវិកាសមិទ្ធកម្ម នាឆ្នាំខាងមុខ។

### ១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យ នៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-រៀបចំកិច្ចប្រជុំបន្តពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-ចុះស្ទង់មតិប្រជាពលរដ្ឋនៅតាមខេត្តគោលដៅ។

-បន្តសិក្សាស្រាវជ្រាវអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បញ្ចូលក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចុះផ្សព្វផ្សាយច្បាប់តាមខេត្តគោលដៅ។

-ផលិតវីដេអូផ្សព្វផ្សាយច្បាប់ សម្រាប់ផ្សព្វផ្សាយតាមទូរទស្សន៍ និងបណ្តាញសង្គម។

-ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃមុន និងក្រោយការផ្សព្វផ្សាយច្បាប់។

-ចុះរៀបំវេទិកាសាធារណៈតាមខេត្តគោលដៅ។

-ចុះស្ទង់មតិពីតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋនៅតាមខេត្តគោលដៅ។

-ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញ រដ្ឋសភា។

## ៣.ការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ច (លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

-ត្រៀមចុះធ្វើអធិការកិច្ច លើការអនុវត្តតួនាទីភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈក្នុងការិយបរិច្ឆេទ២០២០ នៅក្រសួងចំនួន២ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គភាពក្រោមឱវាទ។

-ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ ក្រសួងបរិស្ថាន សាលារាជធានីភ្នំពេញ សាលា

ខេត្តកោះកុង សាលាខេត្តកំពង់ស្ពឺ សាលាក្រុង ស្រុក ខណ្ឌ ចំណុះ និងអង្គភាពក្រោមឱវាទពាក់ព័ន្ធក្នុងការិយបរិច្ឆេទ២០២០។

-ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច និងការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២០ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរ អង្គភាពក្រោមឱវាទ។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២២។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.២.ការងារតាមដានការអនុវត្តច្បាប់

-ត្រៀមចុះតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចំនួន៦ ដែលមិនទាន់បានអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០២១ រួមមានៈច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីអត្តិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ១៤៦អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច ប្រកាសលេខ០៨៧ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី និងតាមដានការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២២។

### ៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មាន។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២២។

## ៤.ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

### ៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

#### ៥.១.១. អភិវឌ្ឍ និងពង្រឹងសមត្ថភាពស្ថាប័ន

-ពង្រឹងសមត្ថភាពមន្ត្រីវិទ្យាស្ថានបន្ថែម លើជំនាញពាក់ព័ន្ធ ដើម្បីបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។

-បន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារជាប្រចាំ។

-ស្នើសុំមធ្យោបាយធ្វើដំណើររបស់វិទ្យាស្ថាន។

-ស្នើសុំក្របខណ្ឌមន្ត្រីរាជការបន្ថែមសម្រាប់វិទ្យាស្ថាន។

-ស្នើសុំមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែតសម្រាប់វិទ្យាស្ថាន។

-កែលម្អរបៀបរបបបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។

-បង្កើត និងផ្ដល់ការបណ្ដុះបណ្ដាលដល់ក្រុមគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ច។

**៥.១.២. ពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ**

-ស្នើសុំបង្កើតអង្គភាពថវិកាវិទ្យាស្ថានជាតិអធិការកិច្ចដើម្បីសម្រួល និងពន្លឿនចរន្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

-ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងបុគ្គលិក និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ។

-ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

## ៥.២. ការងារផែនការ និងស្រាវជ្រាវ

**៥.២.១. ពង្រឹងការគ្រប់គ្រងផែនការ**

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣របស់វិទ្យាស្ថាន។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំ២០២២ និងឆ្នាំ២០២៣។

-បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

**៥.២.២. ពង្រឹងការគ្រប់គ្រងការសិក្សាស្រាវជ្រាវ**

-ស្រាវជ្រាវ និងចងក្រងអនុសាសន៍សម្ដេចតេជោ នាយករដ្ឋមន្ត្រី។

-ស្រាវជ្រាវ និងប្រមូលផ្ដុំឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹង វិស័យអធិការកិច្ច។

-តាមដានអំពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារមន្ត្រីរាជការដែលទទួលបានការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

-សិក្សាស្រាវជ្រាវ និងស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ច។

## ៥.៣. ការងារបណ្ដុះបណ្ដាល

**៥.៣.១. អភិវឌ្ឍធនធានមនុស្ស បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ**

-ផ្ដល់ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ចដល់មន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួង ស្ថាប័ននានា។

-រៀបចំកែលម្អកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈអធិការកិច្ចសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣។

-រៀបចំការបណ្ដុះបណ្ដាលកម្រិតឧត្ដមសិក្សាបច្ចេកទេស/ឯកទេស។

## ៥.៤. ការងារទំនាក់ទំនងសាធារណៈ

**៥.៤.១. ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ**

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាស្ថានទូតនានា។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា។

### ៥.៤.២. ពង្រឹងការគ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យ

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

-រៀបចំបង្កើតរោងពុម្ព និងបោះពុម្ពឯកសារ។

## ៦.ការងារផ្សេងៗ

### ៦.១.ការងារយេនឌ័រ

-បន្តផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ១១ចំណុចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

-ជំរុញការបង្កើនបរិមាណ និងសមត្ថភាពស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងភាពជាអ្នកដឹកនាំ។

-រៀបចំវេទិកាសាធារណៈ ស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-អនុវត្តផែនការបញ្ជ្រាបយេនឌ័រឆ្នាំ២០២២។

-បន្តយកចិត្តទុកដាក់សួរសុខទុក្ខមន្ត្រីរាជការជាស្ត្រី និងជួយឱ្យទាន់ពេលវេលាដោយផ្តល់ជាសម្ភារ ឬថវិកា ដោយផ្ទាល់ឬតាមប្រព័ន្ធផ្ទេរលុយវីងក្នុងករណីមានជំងឺ ឬសម្រាលមាតុភាព។

-អនុវត្តតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

### ៦.២.ការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើនជីវភាពរស់នៅ របស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

### ៦.៣.ការងារសមាគមសង្គហមិត្តភាព

-បន្តសម្របសម្រួល និងទទួលសមាជិក សមាជិកាថ្មីចូលក្នុងសមាគមសង្គហមិត្តភាពក្រសួងបន្ថែមទៀត។

-បន្តប្រមូលយក និងគៀងគរថវិកាពីសមាជិក សមាជិកា ដែលមិនទាន់បានបង់ថវិកា។

### ៦.៤.ការងារក្រុមការងារ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បន្តប្រជុំ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅគ្រប់ដំណាក់កាល។

-បន្តរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តដែលថ្នាក់ដឹកនាំប្រគល់ជូន។

-ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ជាអាទិភាពដែលបានចែង ក្នុងសេចក្តីព្រាង ច្បាប់ស្តីពីអធិការកិច្ច។

-ត្រៀមចូលរួមប្រជុំជាមួយបណ្តាក្រសួង ស្ថាប័ន តាមការចាត់តែងរបស់ថ្នាក់ដឹកនាំក្រសួង ដើម្បីការពារនូវតួនាទី ភារកិច្ចរបស់ក្រសួង។

### ៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួង ក្នុងឆ្នាំ២០២២។

### ៦.៦.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App

-បន្តតាមដានការចុះផ្សាយព័ត៌មាននៅក្នុងទំព័រហ្វេសប៊ុកសំខាន់ទាំង៣ ដើម្បីស្រង់បញ្ចូលក្នុងគេហទំព័រឱ្យបានទាន់ពេលវេលា។

-បន្តត្រួតពិនិត្យ និងរក្សាទុកទិន្នន័យដែលមាននៅក្នុងគេហទំព័រកន្លមកជាប់ជាប្រចាំ។

-ជំរុញការផ្សព្វផ្សាយព័ត៌មានពីគេហទំព័រទៅកាន់បណ្តាញសង្គមដូចជា Facebook WhatsApp និង Telegram។

-រក្សាទំនាក់ទំនងជាមួយក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ ដើម្បីសម្រួលការងារផ្នែកបច្ចេកទេស និងអភិវឌ្ឍគេហទំព័រឱ្យកាន់តែមានសុវត្ថិភាព។

-ត្រៀមរៀបចំ និងធ្វើបច្ចុប្បន្នភាពគេហទំព័រឱ្យកាន់តែមានភាពទាក់ទាញ និងងាយស្រួលប្រើប្រាស់។

### ៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS

-ត្រៀមអនុវត្តផែនការរួមដំណាក់កាលទី៣ បូក២ ឆ្នាំ២០២២ ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅដែលបានដាក់ចេញ។

## ផ្នែកទី៤-សេចក្តីសន្និដ្ឋាន

ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវខ្ពស់ និងកាន់តែមានប្រសិទ្ធភាព និងជោគជ័យលើគ្រប់វិស័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ក្តី។ សមិទ្ធផលការងារ ដូចបានរៀបរាប់ខាងដើមបានមកដោយសារមានការដឹកនាំ ប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង និងវាងវៃ របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ដោយសារកិច្ចសហការចូលរួមពីថ្នាក់ដឹកនាំគ្រប់លំដាប់ និងមន្ត្រីរាជការមានការសាមគ្គីផ្ទៃក្នុងល្អ មានសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ និងមានការយល់ដឹងផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ជាការពិត បុគ្គល និងស្ថាប័នមួយចំនួនមានចេតនាមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសក្រុមការងារអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសារ បញ្ហាផលប្រយោជន៍។ ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួន យល់ថាក្រសួងមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នាជាមួយស្ថាប័នគេ ដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ និងអគ្គាធិការដ្ឋាននៃក្រសួងស្ថាប័នមួយចំនួនទៀត។ ម្យ៉ាងទៀតការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ចមួយចំនួនតូចនៅមានការខ្វះខាតខ្លះ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយធានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាព ជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានតម្រង់ទិស និងណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានធ្វើឱ្យតួនាទីភារកិច្ចការទទួលខុសត្រូវរបស់ក្រសួងមានសារៈសំខាន់ និងរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង។

លើសពីនេះក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យ អាស្រ័យដោយមានការដឹកនាំ ប្រកបដោយភាពឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែគាំទ្ររាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

យើងសង្ឃឹមថា ក្នុងឆ្នាំ២០២២ ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានា ដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

## ឧបសម្ព័ន្ធ ទី៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត

**របាយការណ៍បូកសរុបលទ្ធផលសន្និបាត ឆ្នាំ ២០២១-២០២២**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**
ដោយ **ឯកឧត្តម ចាប សុថារិទ្ធ** រដ្ឋលេខាធិការ

សូមគោរព

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់
ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
ឯកឧត្តមអគ្គនាយក
ឯកឧត្តម នាយកខុទ្ទកាល័យ
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងរយៈពេលពេញមួយថ្ងៃនេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០២១ និងលើកទិសដៅឆ្នាំ ២០២២ ដែលនឹងបញ្ចប់នៅពេលរសៀលបន្តិចទៀតនេះ។

ដោយគោរពតាមបទបញ្ជារបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ និងការឆ្លងរាលដាលនៃជម្ងឺកូវីដ ១៩ សន្និបាតក្រសួងឆ្នាំនេះ ត្រូវបានធ្វើឡើងក្នុងរូបភាព តូចជាងឆ្នាំ ២០១៩ តែធំជាងឆ្នាំ២០២០។ អង្គសន្និបាតត្រូវបានរៀបចំឡើងក្នុងរូបភាពផ្ទៃក្នុងក្រសួងតែប៉ុណ្ណោះ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចាប់ពីថ្នាក់អនុប្រធានការិយាល័យឡើង និងថ្នាក់មន្ទីររាជធានី-ខេត្ត ដោយអញ្ជើញ តែប្រធានមន្ទីរ ១នាក់ បូកអនុប្រធាន១នាក់ប៉ុណ្ណោះ។ ដូច្នេះអ្នកចូលរួមសរុបមានចំនួន ២៩០នាក់ ស្ត្រី ៥៥នាក់ បានប្រព្រឹត្តទៅយ៉ាងរលូនតាមកម្មវិធីដែលបានគ្រោងទុក។

នៅពេលបើកសន្និបាត ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ តំណាងលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថាបើកសន្និបាត ដោយបានបញ្ជាក់ពីប្រវត្តិសង្ខេបរបស់ក្រសួង និងតួនាទីភារកិច្ចស្នូលចំបងៗរបស់ក្រសួង។ ឯកឧត្តមបានសម្តែងនូវមោទនភាព កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្ដាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការទទួល អង្កេត និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ បានរំលឹកថា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានទស្សនៈវិស័យគឺ៖ ***«អភិវឌ្ឍស្ថាប័ន ឱ្យក្លាយជារដ្ឋបាលទំនើបមួយ ប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីធ្វើជាភ្នែក ជាត្រចៀករបស់រាជរដ្ឋាភិបាល បំរើ***

*ប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័ន និងប្រជាពលរដ្ឋ ពង្រឹងតម្លាភាព អភិបាលកិច្ចល្អ និងនីតិរដ្ឋ»* ។

ដើម្បីប្រែក្លាយទស្សនវិស័យខាងលើឱ្យទៅជាការពិត ក្រសួងមានបេសកកម្ម គឺ៖ *«បំពេញការងារដោយយកច្បាប់ជាគោល ក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋ ធ្វើអធិការកិច្ច តាមដានការអនុវត្តច្បាប់ និងដោះស្រាយបណ្តឹង ដើម្បីសម្រេចលទ្ធផលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងគោលដៅទប់ស្កាត់បាតុភាពអសកម្ម អំពើពុករលួយ និងការរំលោភដោយអំណាច ដើម្បីបំរើប្រជាពលរដ្ឋ និងបង្កើនជំនឿជឿជាក់មកលើរាជរដ្ឋាភិបាល»*។

ឯកឧត្តមក៏បានផ្តល់ការណែនាំ ដល់អង្គសន្និបាត បញ្ចេញយោបល់ តាមរយៈធ្វើបទអន្តរាគមន៍ ឬចោទជាសំណួរដើម្បីពិភាក្សា លើរបាយការណ៍បូកសរុបការងារ ឆ្នាំ ២០២១ និងទិសដៅ ឆ្នាំ ២០២២ របស់ក្រសួង ដែលបានចែកជូន អង្គសន្និបាត ជា soft copy ផង និង hard copy ផង។ បន្ទាប់មក ឯកឧត្តម **ម៉ែន ច័ន្ទសុខរិន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅបានអានរបាយការណ៍សង្ខេប ស្តីពីលទ្ធផលការងារ ឆ្នាំ ២០២១ និងទិសដៅឆ្នាំ ២០២២។

បន្ទាប់ពីសម្រាកស្រស់ស្រូបអាហារសម្រន់មក លោកជំទាវកិត្តិសង្គហបណ្ឌិត **មែន សំអន** បានដឹកនាំការពិភាក្សាលើរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០២១ និងទិសដៅឆ្នាំ ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ ក្នុងឱកាសនោះ **ឯកឧត្តម សុខ ម៉ុនសុខ** ប្រធាននាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ បានចូលរួមយោបល់លើ សេចក្តីព្រាងរបាយការណ៍ស្តីពីការបូកសរុប លទ្ធផល ការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២។ ដោយឡែក លោកប្រធានមន្ទីរទរពអខេត្តបាត់ដំបងបានធ្វើបទអន្តរាគមន៍ ការងាររបស់មន្ទីរ ដោយបាន លើកឡើងពីសមិទ្ធផល ការងារ បទពិសោធន៍ការងារ និងការប្រឈមមួយចំនួន រួមមាន កង្វះមធ្យោបាយដឹកជញ្ជូន កង្វះបុគ្គលិក និងកង្វះការបណ្តុះបណ្តាលបច្ចេកទេស ជាពិសេសច្បាប់ស្តីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ជាការឆ្លើយតប គណៈអធិបតី ដែលដឹកនាំដោយលោកជំទាវកិត្តិសង្គហបណ្ឌិត រួមជាមួយឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ក្រសួងបានកត់ត្រាទុកជាធាតុចូល និងបានឆ្លើយតប ពន្យល់ និងបកស្រាយជូនអង្គសន្និបាតទៅតាម វិស័យទទួលខុសត្រូវរៀងៗខ្លួនបានយ៉ាងច្បាស់លាស់ និងក្បោះក្បាយ។

អង្គសន្និបាតក៏បានលើកពីសំណូមពរមួយចំនួន ដើម្បីកែលម្អខ្លឹមសាររបាយការណ៍ឆ្នាំក្រោយៗទៀត ដោយត្រូវរំលេចសូចនាករណ៍ដែលអាចវាស់វែងបាន ដោយប្រៀបធៀបទៅនឹងសូចនាករណ៍ឆ្នាំមុន ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ពីវឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗរបស់ក្រសួង។

អង្គសន្និបាតស្នើអគ្គនាយកដ្ឋានទាំងបី ពង្រឹងការងាររបស់ខ្លួនដោយដឹកនាំនាយកដ្ឋានចំណុះឲ្យចេះរៀបចំរបាយការណ៍សមិទ្ធិកម្ម ប្រៀបធៀបនឹងផែនការក្នុងឆ្នាំដែលអនុវត្តកន្លងមក ។

នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវរៀបចំទម្រង់ផែនការរួមមួយ សម្រាប់ប្រើប្រាស់ក្នុងក្រសួង និងជូនទៅមន្ទីរទរពអ រាជធានី ខេត្ត អនុវត្ត។

អង្គសន្និបាតបានលើកឡើងនូវចំណុចខ្វះខាតខ្លះ នៃរបាយការណ៍ក្រសួង ដែលត្រូវកែសម្រួលជាអត្ថបទបោះពុម្ព ដើម្បីដាក់ជូនលោកជំទាវឧបនាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអារម្ភកថា និងផុសក្នុងវិបសាយផ្លូវការរបស់ក្រសួង។

ក្រោយពីសម្រាកពិសាបាយសាមគ្គី ថ្ងៃត្រង់រួមគ្នា នៅសណ្ឋាគារសុខា នេះប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល។ នៅពេលរសៀល ដឹកនាំដោយ លោកជំទាវកិត្តិសង្គហបណ្ឌិតផ្ទាល់ បានបន្តទៅតាមកម្មវិធីដែលបានគ្រោងទុក ដោយបន្តពិភាក្សាលើរបាយការណ៍ក្រសួង។

ក្នុងឱកាសនោះ លោកប្រធានមន្ទីរទរពអ ខេត្តកំពង់ធំបានគាំទ្រលើរបាយការណ៍ និងបានធ្វើចំណាប់អារម្មណ៍បន្ថែម លើកការងារមន្ទីរដែលបានអនុវត្តកន្លងមក ជាពិសេសពីសមិទ្ធផលការងារ ដែលទទួលបានដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរខេត្ត ជាពិសេសតាមដាន និតត្រួតពិនិត្យលើករណីរុករានទន្ទ្រានយកដីនៅតំបន់ជុំវិញបឹងទន្លេសាប។

បន្ទាប់មក លោកប្រធានមន្ទីរទរពអ ខេត្តកំពង់ឆ្នាំង ក៏បានគាំទ្រទាំងស្រុងលើរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០២១ និងទិសដៅឆ្នាំ ២០២២របស់ក្រសួង ព្រមទាំងបានធ្វើចំណាប់អារម្មណ៍ លើការងារ មន្ទីរ ដែលបានអនុវត្តកន្លងមក និងបញ្ហាប្រឈមដែលបានជួបប្រទះ។

បន្ទាប់មក ខ្ញុំ (ចាប សុថារិទ្ធ) ក្នុងនាមក្រុមការងារការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងបានធ្វើបទបង្ហាញមួយ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមិទ្ធផល និងការរំពឹងទុករបស់ក្រសួងទ.រ.ព.អ។ បទបង្ហាញមានគោលបំណងផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយអំពីកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល និងដើម្បីរាយការណ៍ពីវឌ្ឍនភាព នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងយើង ដែលទាក់ទងនឹងយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកា និងការរំពឹងទុករបស់ក្រសួង ដែលត្រូវត្រៀមអនុវត្ត នៅអនាគត។

ជារួម អង្គសន្និបាតបានរកឃើញការប្រឈមមួយចំនួន គឺសមិទ្ធផលរបស់ក្រសួងភាគច្រើន គឺមិនអាចវាស់វែងបាន (អរូបីយ) ដូចជា ការពង្រឹងអភិបាលកិច្ចល្អ ការចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ និងគោលនយោបាយនានា ។ល។ ដែលនាំឲ្យមានការលំបាកក្នុងការរៀបចំ និងការការពារថវិកាប្រចាំឆ្នាំ។ ចំណែកការប្រឈមមួយទៀតគឺក្រសួងនៅខ្វះច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យដែលក្រសួងកំពុងគ្រប់គ្រង ជាពិសេសវិស័យអធិការកិច្ច ដែលទាមទាការខិតខំទ្វេរដងដើម្បីដោះស្រាយការប្រឈមនោះ។

ជាការសន្និដ្ឋាន សមិទ្ធផលការងារក្រសួងខ្លះ ត្រូវបានប៉ះពាល់ ដោយវិបត្តិនៃជំងឺកូវីដ ១៩ ។ ទោះជាយ៉ាងនេះក្តី ក៏សន្និបាតបានវាយតម្លៃខ្ពស់ ចំពោះជោគជ័យ នៃឆ្នាំ ២០២១ ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព មនសិការទទួលខុសត្រូវខ្ពស់ និងដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នឯកជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋផងដែរ។

ជាទិសដៅ ក្នុងឆ្នាំ ២០២២ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ ប្តេជ្ញាខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់

បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។

ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

## ឧបសម្ព័ន្ធ ទី៤. សុន្ទរកថាបើកសន្និបាត

**សុន្ទរកថា**

ឯកឧត្តម **ឆេង សារឿន**

រដ្ឋលេខាធិការប្រចាំការ

តំណាងលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១

របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២

សណ្ឋាគារ សុខាភ្នំពេញ (វិថីកែវ ចិន្តា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ)

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ជាបឋម ខ្ញុំមានសេចក្តីរីករាយ និងកិត្តិយស ក្នុងនាមតំណាងរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រសួងដែលបានចូលរួមជាអធិបតីក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំរបស់ ក្រសួងនាពេលនេះ។

យើងជួបជុំគ្នាក្នុងសន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះមានគោលបំណងត្រួតពិនិត្យវាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២១កន្លងមក ដោយលើកឡើងពីសមិទ្ធផលគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរនៅរាជធានី ខេត្ត និងការប្រឈម និងវិធានការណ៍ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២២ ដើម្បីសម្រេចបានលទ្ធផលទៅតាម ផែនការ និងយុទ្ធសាស្ត្រដូចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។

សន្និបាតយើងធ្វើឡើងចំពេលដែលប្រទេសយើង ក៏ដូចជាប្រទេសនានាក្នុងតំបន់ និងពិភពលោក កំពុងជួបប្រទះនូវគ្រោះមហន្តរាយនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាត និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការព្រមទាំងលំហូរ នៃការធ្វើដំណើរ សេវាកម្ម ទេសចរណ៍ ពាណិជ្ជកម្ម និងការវិនិយោគ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែក វិបត្តិកូវីដ១៩ក៏បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ប្រតិបត្តិការការងាររបស់ក្រសួងយើងផងដែរជាពិសេស ប្រេងឥន្ធនៈ ប្រាក់បេសកកម្ម ទាំងក្នុង និងក្រៅប្រទេស លទ្ធកម្ម និងការបណ្តុះបណ្តាល ដោយសាររាជរដ្ឋាភិបាលបានកាត់បន្ថយការចំណាយលើមុខសញ្ញាជាច្រើន ចាប់ពីដើមឆ្នាំ២០២០មក ក្នុងគោលបំណងត្រៀមទប់ទល់ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។

ដោយសារបញ្ហារក្សាសុវត្ថិភាពក្នុងដំណាក់កាលគ្រោះនៃជំងឺកូវីដ-១៩ ទើបសន្និបាតឆ្នាំនេះត្រូវបានរៀបចំឡើង ដោយកំណត់ការចូលរួមបានត្រឹមតែពីមន្ត្រីរាជការ ថ្នាក់ដឹកនាំការក្រសួង ចាប់ពីអនុ

ប្រធានការិយាល័យ នៅថ្នាក់កណ្តាល និងថ្នាក់ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ចរាជធានី ខេត្តម្នាក់ រួមនឹងអនុប្រធាន១នាក់តែប៉ុណ្ណោះ។ យើងមិនបានអញ្ជើញតំណាងក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្សេងទៀតចូលរួមដូចសន្និបាតនៅឆ្នាំមុនៗនោះទេ។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានបានចំណាយពេលដ៏មានតម្លៃមកចូលរួមក្នុងពិធីនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គឺជាស្ថាប័នរដ្ឋដែលជាសេនាធិការផ្ទាល់របស់រដ្ឋាភិបាលមានប្រវត្តិយូរយាមកហើយ និងបានវិវត្ត ផ្លាស់ប្តូរជាហូរហែរ ទៅតាមស្ថានការណ៍នយោបាយនៅកម្ពុជា។

ក្រសួងយើងមានភារកិច្ច ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះភារកិច្ចសំខាន់របស់ក្រសួង គឺការចុះធ្វើអធិការកិច្ច ការត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ ដើម្បីរួមចំណែកទប់ស្កាត់អំពើពុករលួយ ភាពអយុត្តិធម៌ក្នុងសង្គម និងការរំលោភបំពានដោយអំណាច ដើម្បីបំរើប្រយោជន៍បុគ្គល និងក្រុមគ្រួសារ និងការពារសិទ្ធរបស់ពលរដ្ឋ និងសុវត្ថិភាពសាធារណៈ ពោលគឺពង្រឹងអភិបាលកិច្ចល្អ ដែលជាស្នូល នៃយុទ្ធសាស្រ្តចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានទស្សនៈវិស័យគឺ៖ ***«អភិវឌ្ឍស្ថាប័ន ឱ្យក្លាយជារដ្ឋបាលទំនើបមួយ ប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីធ្វើជាភ្នែក ជាត្រចៀករបស់រាជរដ្ឋាភិបាល បំរើប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័ន និងប្រជាពលរដ្ឋ ពង្រឹងតម្លាភាព អភិបាលកិច្ចល្អ និងនីតិរដ្ឋ»*** ។

ដើម្បីប្រែក្លាយទស្សនវិស័យខាងលើឱ្យទៅជាការពិត ក្រសួងមានបេសកកម្ម គឺ៖ ***«បំពេញការងារដោយយកច្បាប់ជាគោល ក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋ ធ្វើអធិការកិច្ច តាមដានការអនុវត្តច្បាប់ និងដោះស្រាយបណ្តឹង ដើម្បីសម្រេចលទ្ធផលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តរបស់ក្រសួង ក្នុងគោលដៅទប់ស្កាត់បាតុភាពអសកម្ម អំពើពុករលួយ និងការរំលោភដោយអំណាច ដើម្បីបំរើប្រជាពលរដ្ឋ និងបង្កើនជំនឿជឿជាក់មកលើរាជរដ្ឋាភិបាល»***។

ក្នុងន័យនេះ យុទ្ធសាស្រ្ត និងផែនការសកម្មភាពត្រូវបង្កើតឡើងដើម្បីធ្វើឱ្យបេសកកម្មនេះទទួលបានជោគជ័យ ។

*អង្គសន្និបាតទាំងមូលជាទីមេត្រី*

ការធ្វើអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ និងបង្កើនប្រសិទ្ធភាពការងារពោលគឺសំដៅទៅលើការកាត់បន្ថយ និងទប់ស្កាត់អំពើពុករលួយ ព្រោះអំពើពុករលួយធ្វើឱ្យប៉ះពាល់ជាអវិជ្ជមាន យ៉ាងធ្ងន់ធ្ងរណាស់ដល់ប្រទេសជាតិ ដូចជាបង្កការខាតបង់ថវិការដ្ឋ ទ្រព្យសម្បត្តិសាធារណៈ រាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច បង្កឧបសគ្គដល់ធុរកិច្ច និងការបាត់បង់ដល់ការប្រកួតប្រជែង ដោយសេរី និង

យុត្តិធម៌ និងរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿមកលើរាជរដ្ឋាភិបាល។

អភិបាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជម្រុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍនមួយប្រកបដោយនិរន្តរភាព។ អភិបាលកិច្ចដែលប្រកបដោយសុភវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល។ ដោយយល់ឃើញពីសារៈសំខាន់ នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា "អភិបាលកិច្ចល្អគឺជាបុរេល័ក្ខ័ណ្ឌសំខាន់បំផុត ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម"។

ការទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ និងការជម្រុញអភិបាលកិច្ចល្អទាមទាឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងវិស័យរដ្ឋ និងឯកជន។ ដោយសារការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវផ្តោតទៅលើអភិក្រមជាសារវន្ត័ចំនួន ៣ គឺៈ ការអប់រំបង្ការទប់ស្កាត់ជាមុន ការអនុវត្តច្បាប់ និងការចូលរួមគាំទ្រពីមហាជន។ ដូច្នេះការងារអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ មិនអាចផ្តាច់ចេញពីការអប់រំផ្សព្វផ្សាយច្បាប់ជូនដល់មហាជន និងការចូលរួមរបស់ប្រជាជនបានឡើយ។ ដូច្នេះ ការងារស្នូលដ៏សំខាន់របស់ក្រសួង គឺជានាការដឹកនាំគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

ចាប់តាំងពីការបង្កើតស្ថាប័ននេះមក ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូលដូចជា អធិការកិច្ច ការទទួល និងដោះស្រាយពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការចុះស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការសម្របសម្រួលបញ្ចប់ទំនាស់រ៉ាំរ៉ៃ បានជាច្រើនករណី ការតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏មានភារកិច្ចធ្វើការអប់រំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អរ ជម្រុញលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលមានបួនដំណាក់កាល។ ដោយឡែក រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានប្រកាសដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសម្រាប់ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំជាបន្តទៀត។ យុទ្ធសាស្ត្រថ្មីនេះបានពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាពរូបនីយកម្មមុំនីមួយៗ នៃចតុកោណយុទ្ធសាស្ត្រទាំង៤ ព្រមទាំងកែលម្អរបៀបវារៈ គោលនយោបាយ និងយន្តការអនុវត្តមួយ ចំនួនឲ្យកាន់តែល្អប្រសើរឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយ ក្នុងចក្ខុវិស័យ ***"ប្រែក្លាយឋានៈរបស់ប្រទេសកម្ពុជា ពីប្រទេសមាន***

*ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើង ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ"។*

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរួមចំណែកក្នុងការអនុវត្ត យុទ្ធសាស្ត្រចតុកោណ សំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយដែលពិតជាស្របតាមគោលដៅយុទ្ធសាស្ត្រទី ៤ នៃ"**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" គឺ "បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាព នៃសេវាសាធារណៈ សំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងស្ថានភាពអំណោយផលសម្រាប់វិនិយោគ។

ជារួម នៅឆ្នាំ ២០២១ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដូចដែលបានលើកឡើងក្នុងរបាយការណ៍ដែលបានចែកជូនអង្គសន្និបាត ដើម្បីពិភាក្សា និងអនុម័ត។ យើងពិតជាមានមោទនភាព និងអំណរសាទរចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្តេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំដ៏ត្រឹមត្រូវ ដោយមានផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ រួមនឹងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាព នានា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !***

ដើម្បីសម្រេចបានជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដូចបានលើកឡើងខាងលើនេះ ទាមទារឱ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងសមត្ថភាព និងបទពិសោធន៍ និងគោរពច្បាប់ និងក្រមសីលធម៌មន្ត្រីរាជការ និងខិតខំបំពេញការងារទៅតាមការចាត់តាំង និងតួនាទីរបស់ខ្លួនគ្រប់ៗគ្នា។

ទន្ទឹមនេះ មន្ត្រីរាជការក៏ត្រូវមានលក្ខណៈសម្បត្តិថ្លៃថ្នូ ស័ក្តិសមជាអ្នកបម្រើដ៏ល្អ របស់ប្រជាជនដោយផ្លាស់ប្តូរឥរិយាបទ ប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូរអភិវឌ្ឍន៍ដែលអាចទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនប្រសិទ្ធផលសេវាកម្មសាធារណៈ។ ជាមួយគ្នានេះ មន្ត្រីរាជការក្រសួងទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់សម្តេចតេជោនាយករដ្ឋមន្ត្រីគឺៈ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងបារនា២ គឺ "**កែទម្រង់ខាងក្នុង និងបង្កើតមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**" ដែលយើងត្រូវចងចាំកុំឲ្យភ្លេចខ្លួន។

ក្នុងឱកាសសន្និបាតរយៈពេលពេញមួយថ្ងៃនេះ ខ្ញុំសូមអំពាវនាវសូមឯកឧត្តម លោកជំទាវ លោក លោកស្រីដែលចូលរួមទាំងអស់ត្រូវបង្កើនស្មារតី យកចិត្តទុកដាក់ ប្រើប្រាស់ពេលវេលាដ៏មានប្រយោជន៍នេះដើម្បីពិភាក្សាលើរបាយការណ៍ក្រសួង ផ្លាស់ប្តូរបទពិសោធន៍ និងលើកឡើងពីចំណុចល្អៗ និងចំណុចមិនទាន់បានកែលម្អ ឬបញ្ហាប្រឈមទាំងឡាយ ព្រមទាំងលើកនូវដំណោះស្រាយដ៏សមស្រប និងប្រកបដោយប្រសិទ្ធភាព ដើម្បីដាក់ផែនការ និងសកម្មភាព សម្រាប់អនុវត្តបន្ត។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី និងសមាជិក សមាជិកា នៃអង្គសន្និបាត ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធី នាពេលនេះសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លៀងឡើយ។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យអង្គសន្និបាតសម្រេចបានជោគជ័យ និង**សូមប្រកាសបើក**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២២ របស់**ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាប់ពីពេលនេះតទៅ។**

# ឧបសម្ព័ន្ធ ទី៥. សុន្ទរកថាបិទសន្និបាត

## សុន្ទរកថា

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២២
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២
សណ្ឋាគារ សុខាភ្នំពេញ (វិថីកែវ ចិន្តា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ)

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានបូកសរុបលទ្ធផលការងារក្រសួងបានសម្រេចក្នុងឆ្នាំ ២០២១កន្លងមក និងដាក់ចេញនូវទិសដៅសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២២។ សន្និបាតដែលមានរយៈពេលពេញមួយថ្ងៃនេះសម្រេចបានលទ្ធផលគួរជាទីមោទនៈ ដូចដែលបានគ្រោងទុក។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ រួមមានថ្នាក់ដឹកនាំ មន្ត្រីរាជការ ទាំងនៅថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត ដែលបានចូលរួមក្នុងសន្និបាតនេះ។

ក្រោយពីដំណើរការពេញមួយថ្ងៃមក សន្និបាតយើងបានដំណើរការយ៉ាងរលូន និងទទួលបានការចូលរួមយ៉ាងសកម្ម រួមមានការចូលរួមជាមតិ ចោទជាសំណួរ និងមានការពន្យល់បកស្រាយរួមជាមួយការធ្វើបទបង្ហាញពីការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង និងលើកឡើងនូវបទពិសោធន៍ល្អៗ ការប្រឈមនានា និងដំណោះស្រាយ ប្រកបដោយភាពជាក់ស្តែង និងទទួលបានលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ។ នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ ពីស្មារតីទទួលខុសត្រូវ និងការខិតខំបំពេញការងាររបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជា ថ្នាក់ ដឹកនាំ និងមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត ដែលបានខិតខំ ប្រឹងប្រែងបំពេញការងារស្នូលតាមតួនាទីរៀងៗខ្លួន។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្រឹងប្រែងបំពេញភារកិច្ច ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងដោយមានកិច្ចសហការ ការគាំទ្រ និងទទួលស្គាល់ពីស្ថាប័នពាក់ព័ន្ធ ដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ នេះជាមោទនភាព និង

កិត្តិយសដ៏ធំធេង ដោយក្រសួងយើងទទួលបានជោគជ័យលើការងារជាច្រើនក្នុងបេសកកម្មដ៏ឧត្តុង្គ ឧត្តមរបស់ខ្លួន។

ខ្ញុំក៏សូមថ្លែងនូវអំណរគុណ និងការកោតសរសើរដោយស្មោះ ចំពោះគណៈកម្មាការរៀបចំសន្និបាត ដែលដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** រួមជាមួយលោកជំទាវ **សុភ័ក្ត្រ ថាវី** ឯកឧត្តម **ហួត ហាក់** និងឯកឧត្តម **ចាប សុថារិទ្ធ** និងសមាជិកទាំងអស់ដែលបានបំពេញការងារយ៉ាងសកម្ម ធ្វើឲ្យសន្និបាតឆ្នាំនេះប្រព្រឹត្តទៅបានល្អប្រសើរ។

ខ្ញុំសូមអបអរសាទរ និងគាំទ្រទាំងស្រុងនូវរបាយកាណ៍បូកសរុបការងារ ឆ្នាំ២០២០១ និងទិសដៅ សម្រាប់ឆ្នាំ២០២២ ដែលអង្គសន្និបាតបានពិភាក្សា និងសម្រេច។

*អង្គពិធីទាំងមូលជាទីមេត្រី*

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណ ដែលមានបួនដំណាក់កាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ ដោយកំណត់អាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងដាក់ចេញនូវយន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើកលទ្ធផលការងារ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩- ២០២៣ ជាការឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់ របស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យកម្មវិធីនយោបាយអភិវឌ្ឍជាតិ ប្រកបដោយចីរភាព ឆ្លើយតបទៅនឹងបរិការណ៍អភិវឌ្ឍសេដ្ឋកិច្ច-សង្គម បញ្ហាប្រឈម និងកាលានុវត្តភាពទាំងឡាយ ដែលជាបញ្ហារួមរបស់សង្គមជាតិយើង ដើម្បីឈានទៅសម្រេចបាននូវគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា។

ចាប់ពីឆ្នាំ២០២០មក កម្ពុជាក៏ដូចជាប្រទេសនានាក្នុងតំបន់ និងពិភពលោកបាន និងកំពុងជួបប្រទះនូវគ្រោះមហន្តរាយនៃការរាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងបម្លែងខ្លួនជាបន្តបន្ទាប់ និងបានឆ្លងរាលដាល និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផលិតកម្ម ការផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរនៃការធ្វើដំណើរ ទេសចរណ៍ សេវាកម្ម ពាណិជ្ជកម្ម និងការវិនិយោគ ជាហេតុរំខានទៅលើគ្រប់វិស័យ នៃសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែក នៅកម្ពុជា វិបត្តិកូវីដ១៩ក៏បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់សេដ្ឋកិច្ច និងសង្គមកិច្ចផងដែរ។ ដោយហេតុនេះ រាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយខ្ទង់ចំណាយថវិកាជាតិមួយចំនួន ក្នុងគោលបំណងត្រៀមទប់ទល់ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ដែលនាំឲ្យមានការប៉ះពាល់ដល់ប្រតិបត្តិការការងាររបស់ក្រសួងយើង ជាពិសេស ប្រេងឥន្ធនៈ បេសកកម្ម ទាំងក្នុង និងក្រៅប្រទេស លទ្ធកម្ម និងការបណ្តុះបណ្តាលចាប់ពីដើមឆ្នាំ២០២០មក។ ជាលទ្ធផល ដោយមានការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ** នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការណ៍ជាច្រើន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងកាត់បន្ថយផលប៉ះពាល់ផ្ទាល់ដល់ជីវភាពប្រជាពលរដ្ឋដែលរងហានិភ័យខ្ពស់ រួមមានការឧបត្ថម្ភសាច់ប្រាក់ ការបង្កើតមជ្ឈមណ្ឌលចត្តាឡីស័ក និងព្យាបាលជំងឺកូវីដ១៩ និងការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋដោយសេរី និងទូទៅ។ យើង

ពិតជាមានមោទនភាព ដោយកម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់ជាងគេ និងមានអត្រាមរណៈភាពដោយជំងឺកូវីដ១៩ ទាប។ លើសពីនេះ នៅពេលដែលប្រទេសជាច្រើននៅប្រើវិធានការរឹតត្បិតនៅឡើយ កម្ពុជាបានបើកសេដ្ឋកិច្ចលើគ្រប់វិស័យជាថ្មី ចាប់ពីខែធ្នូ ឆ្នាំ២០២១មក។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាយើងបានវិវត្តបណ្ដើរៗ និងប្រែប្រួលមុខមាត់កាន់តែប្រសើរ ពីមួយឆ្នាំទៅមួយឆ្នាំ។ ក្រសួងយើងធ្លាប់មានទីតាំងតូចចង្អៀត និងអគារចាស់ទ្រុឌទ្រោម ដែលឥឡូវយើងមានទីតាំងល្អបំផុតមួយនៅកណ្ដាលរាជធានីភ្នំពេញ មានអគារធ្វើការសមរម្យ ដែលក្នុងនោះអគារ ឌី (D) មានកំពស់៧ជាន់ ទំហំ ១៨ម៉ែត្រ គុណនឹង ៤៨ម៉ែត្រត្រូវបានរាជរដ្ឋាភិបាលប្រគល់ជូនកាលពីចុងឆ្នាំ ២០១៩។ ដោយឡែក ថវិកាក្រសួងក៏ត្រូវបានកើនជាលំដាប់ ដោយសារយើងខិតខំបំពេញការងារ ដោយទទួលបានជោគជ័ន និងសមិទ្ធផលកាន់តែច្រើន។ ជាក់ស្ដែង ក្រសួងបានបង្កើតវិទ្យាស្ថានជាតិអធិការកិច្ច ដែលកំពុងកសាងសមត្ថភាពឈានទៅមុខជាជំហានៗ ពីបណ្ដុះបណ្ដាលមន្ត្រីរាជការក្រសួងយើង និងឈានទៅបណ្ដុះបណ្ដាលមន្ត្រីរាជការ ដែលពាក់ព័ន្ធនឹងការងារអធិការកិច្ចមកពីក្រសួង ស្ថាប័ន ដទៃថែមទៀត។

ទោះជាយើងទទួលបានជោគជ័យ ជាច្រើនក្នុងការងារក្ដី ក៏ក្រសួងនៅមានការប្រឈមជាច្រើនដូចជា៖ ទី១) នៅតាមស្ថាប័នរដ្ឋមួយចំនួនមិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ ដោយសារគេយល់ថា ក្រុមបេសកកម្មយើង ទៅរកចាប់កំហុសគេ និងរំខានការងារគេទី២) ក្រសួងស្ថាប័នរដ្ឋមួយចំនួនមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នា ដែលធ្វើឱ្យមានក្រុមបេសកកម្មច្រើនត្រួតគ្នា ដែលធ្វើឱ្យគេពិបាកទទួល និងខាតពេលវេលា ទី៣)ធនធានមនុស្សដែលមានជំនាញ និងសមត្ថភាព នៅមានកំរិត និងក្រសួងនៅខ្វះមធ្យោបាយធ្វើដំណើរ ដើម្បីចុះទៅបំពេញបេសកកម្ម ទី៤) សមាជិកក្រុមការងារចុះធ្វើបេសកកម្មខ្លះមិនបានអនុវត្ត តាមក្រមសីលធម៌វិជ្ជាជីវៈពេញលេញនៅឡើយ ទី៥) ការងារអធិការកិច្ចជាពិសេសការទទួល ស្រាវជ្រាវ និងដោះស្រាយពាក្យបណ្ដឹង នៅមានការប្រឈមខ្លះ ព្រោះវាជាការងារដែលលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ច្រើន ដែលទាមទារការតស៊ូ សមត្ថភាព និងជំនាញច្បាស់លាស់ ពីបច្ចេកទេសអធិការកិច្ច និងសមត្ថភាពផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។ លើសពីនេះក្រសួងនៅមានការប្រឈមផ្សេងទៀតដូចដែលបានចែងក្នុងរបាយការណ៍សន្និបាត។

ទោះជាមានការប្រឈមខ្លះយ៉ាងណាក្ដី ក្រសួងបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ដោយទទួលខុសត្រូវក្នុងនាមរាជរដ្ឋាភិបាល ដែលបានប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងរាល់កិច្ចការសម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើការងារអធិការកិច្ច លើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបានចុះធ្វើអធិការកិច្ច ដើម្បីត្រួតពិនិត្យលើការគ្រប់គ្រង ការងារតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល សំដៅជួយកាត់បន្ថយបាតុភាពអសកម្មនានា និងការងារទទួលពាក្យបណ្ដឹង ការងារអង្កេតស្រាវជ្រាវ ដើម្បីទប់ស្កាត់ការរំលោភដោយអំណាច និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ក្រសួងសម្រេចបានលទ្ធផលជាច្រើន ក្នុងការងារអធិការកិច្ច ដូចជាៈ ការងារទទួលពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការងារស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការងារសម្រប សម្រួលបញ្ចប់ទំនាស់រ៉ាំរ៉ៃ បានជាច្រើនករណី ការងារតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាត របស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏បានអប់រំ ណែនាំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីកែលម្អរ និងលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្រ្តចតុកោណទាំង៤ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។

អ្វីដែលជាមោទនភាពដែលលេចធ្លោនៅឆ្នាំនេះ គឺការចូលរួមយ៉ាងសកម្មរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប ដោយបានចូលរួមជាមួយស្ថាប័នពាក់ព័ន្ធចុះទៅត្រួតពិនិត្យ និងទប់ស្កាត់កាប់ព្រៃ និងទន្ទ្រានដីព្រៃលិចទឹកក្នុងតំបន់មាត់បឹងទន្លេសាប។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ដើម្បីសម្រេចបាននូវគោលដៅអនាគត ឆ្នាំ២០២២ ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ លោក លោកស្រី មន្រ្តីរាជការគ្រប់លំដាប់ថ្នាក់ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោមនេះ៖

១. ត្រូវអនុវត្តអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលតម្រូវឲ្យក្រសួងយើងផ្អែកលើអភិក្រម ដូចខាងក្រោម៖

- តាមបណ្តឹងតវ៉ា និងបណ្តឹងបរិហារ ពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន
- តាមបណ្តឹងរបស់ស្ថាប័នរងអធិការកិច្ច លើលទ្ធផល អធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- ផ្អែកលើហានិភ័យ បណ្តឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធ
- តាមសំណើរបស់ក្រសួងស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- មានភាពមិនប្រក្រតីលើរបាយការណ៍លទ្ធផលអធិការកិច្ច
- តាមដាននូវរាល់វិធានការដែលអធិការកិច្ចបានដាក់ចេញ ដល់ស្ថាប័នរងអធិការកិច្ច និង
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

២. ក្នុងពេលបំពេញបេសកកម្មចុះធ្វើអធិការកិច្ច មន្រ្តី ឬភ្នាក់ងារអធិការកិច្ចត្រូវគោរពឲ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ ទៅតាមក្រមសីលធម៌មន្រ្តីរាជការអធិការកិច្ច ដែលបានដាក់ចេញរួចហើយតាមប្រកាសលេខ ០៧៨ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៨ ដែលក្នុងនោះតម្រូវឲ្យមន្រ្តីអធិការកិច្ចត្រូវឈរលើគោលការណ៍គ្រឹះ សុចរិតភាព ភាពមិនលំអៀង សមត្ថភាពវិជ្ជាជីវៈ ឯករាជ្យភាព ត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយយកច្បាប់ជាធំ និងត្រូវមានឯកសណ្ឋាន ដូចដែលក្រសួងបានណែនាំរួចហើយ។ ត្រូវពង្រឹងប្រសិទ្ធភាព ក្នុងបេសកកម្មចុះធ្វើអធិការកិច្ច ការអង្កេត ស្រាវជ្រាវពាក្យបណ្តឹង និងការតាមដាន

ការអនុវត្តច្បាប់ តាមរយៈការរកព័ត៌មានឲ្យមានតុល្យភាពច្បាស់លាស់ មានភស្តុតាង និងឯកសារសំអាង គ្រប់គ្រាន់ទាំងអង្គហេតុ និងអង្គច្បាប់។

៣. ពង្រឹងវិន័យការងារ ដោយត្រូវវត្តមានឱ្យបានជាប់ជាប្រចាំ និងបន្តបំពេញការងារជាធម្មតា ដោយត្រូវតាមដានព័ត៌មាន និងស្រាវជ្រាវឯកសារ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងការងារក្រសួង ដើម្បីពង្រឹងសមត្ថភាព រួមទាំងការគ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ សវនកម្ម និងបុគ្គលិកដើម្បីបង្កើនសមត្ថភាពជំនាញទៅតាមតួនាទីរៀងៗខ្លួន។ ត្រូវអនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ៖ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និងបាវនា ២ គឺ **"កែទម្រង់ខាងក្នុង និងបង្កើតមិត្តខាងក្រៅ ក្នុងស្មារតីឯកភាពជ្យ"**។

៤. ដោយសារការផ្សព្វផ្សាយច្បាប់ ជាតម្រូវការចាំបាច់ ក្រុមការងារក្រសួងត្រូវបន្តការអប់រំ និងផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយ គ្រប់២៥ រាជធានី-ខេត្ត ជាពិសេសទៅតាមទីប្រជុំជន និងជនបទដាច់ស្រយ៉ាល។

៥. ត្រូវបន្តជម្រុញការឆ្លងសេចក្តីព្រាងច្បាប់អធិការកិច្ច ដែលក្រសួងបានតាក់តែងរួច ដោយបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យច្បាប់នេះត្រូវបានអនុម័ត។ លើសពីនេះក្រុមការងារតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងសេចក្តីប្រកាសរបស់ក្រសួង ដើម្បីតម្រង់ទិសការងារដោយមិនបាច់រង់ចាំច្បាប់អធិការកិច្ចដូចជា៖ ស្តង់ដារអធិការកិច្ច នីតិវិធីអធិការកិច្ច ក្រមសីលធម៌មន្ត្រីអធិការកិច្ច (ដោយធ្វើបច្ចុប្បន្នភាព ប្រកាសលេខ០៧៨ ឆ្នាំ២០០៨ និងបទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូចុះបំពេញបេសកកម្មអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ លេខ៥៩៦ ឆ្នាំ២០១៤) នីតិវិធីនៃការតាមដានការអនុវត្តច្បាប់ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង និងនីតិវិធី នៃការផ្សព្វផ្សាយច្បាប់ ។ល។

៦. ត្រូវអនុវត្តបន្តនូវកម្មវិធី ទទួលពាក្យបណ្តឹងអនឡាញ និងជម្រុញបណ្ណាល័យ អេឡិចត្រូនិក (e-Library) ដែលតាមរយៈកម្មវិធីទាំងនោះ ប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងអាចមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ការអនុវត្តកម្មវិធីទាំងនេះ គឺជាការរួមចំណែកសម្រួលការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៧. វិទ្យាស្ថានជាតិអធិការកិច្ច ត្រូវពង្រឹងគុណភាពបណ្តុះបណ្តាល ជាពិសេសពង្រឹងសមត្ថភាពគ្រូ។ ដោយសារក្រសួងយើងជាស្ថាប័នស្នូលលើវិស័យអធិការកិច្ច ដូច្នេះយើងត្រូវតែយល់ច្បាស់ និងមានសមត្ថភាពខ្ពស់ជាងគេលើវិស័យនេះ។ យើងត្រូវបង្កើតជាមេរៀនដែលជារបស់យើងក្នុងបរិបទកម្ពុជា ដោយមិនចម្លងទាំងស្រុងពីប្រទេសណាមួយនោះឡើយ។ វិទ្យាស្ថានជាតិអធិការកិច្ចត្រូវចំខ្លឹមសារ កម្មវិធីបណ្តុះបណ្តាលថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្តម លើជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធ។ វិទ្យាស្ថាន ក៏ត្រូវបណ្តុះបណ្តាលមុខជំនាញផ្សេងបន្ថែម ក្រៅពីអធិការកិច្ច ដូចជា ជំនាញអប់រំផ្សព្វផ្សាយច្បាប់ ជំនាញការសិក្សាស្រាវជ្រាវ ជំនាញវាយតម្លៃ ជំនាញផ្នែកស្ទាបស្ទង់មតិ និងជំនាញផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់របស់ក្រសួង។

៨. ត្រូវបន្តធ្វើការកែទម្រង់ផ្ទៃក្នុងក្រសួងជាបណ្តើរៗ ជាពិសេសពង្រឹងសមត្ថភាពអង្គភាពថវិកាដើម្បីត្រៀមអនុវត្តថវិកាកម្មវិធីពេញលេញ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៩. ទោះជាមានស្ថាប័នច្រើន មានភារកិច្ចស្រដៀងគ្នា ឬត្រួតគ្នាក៏ដោយ យើងត្រូវតែពន្យល់ពីសារៈសំខាន់ នៃការងារអធិការកិច្ច ដែលជាស្ថាប័នត្រួតពិនិត្យ ជម្រុញអភិបាលកិច្ចនិងប្រសិទ្ធភាពការងារដល់ស្ថាប័នផ្សេងៗទៀតឱ្យយល់ និងត្រូវកែទស្សនៈដែលខុសឆ្គងពី **"ការងារត្រួតគ្នា"** ទៅជា **"ការងារបំពេញបន្ថែមគ្នាទៅវិញទៅមក"** ដើម្បីបុព្វហេតុអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរបស់រាជរដ្ឋាភិបាលតែមួយ។

១០. មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅរាជធានី-ខេត្ត ពង្រឹងកិច្ចសហការ និងទំនាក់ទំនងឱ្យបានល្អជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីរួមគ្នាបំពេញការងារជាក្រុម ជាពិសេសការដោះស្រាយពាក្យបណ្ដឹង និងការចូលរួមជាមួយស្ថាប័នពាក់ព័ន្ធចុះត្រួតពិនិត្យ និងទប់ស្កាត់ការកាប់ព្រៃ និងទន្ទ្រានយកដីរដ្ឋ ជាពិសេសនៅតំបន់មាត់បឹងទន្លេសាប។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការ ក្រុមការងារនៃគណៈកម្មការរៀបចំសន្និបាត ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឱ្យសន្និបាតក្រសួងឆ្នាំនេះបានទទួលជោគជ័យគួរជាទីពេញចិត្ត។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្ដាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបម្រើប្រជាជន លើវិស័យទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្ដឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

មុននឹងបញ្ចប់ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផល ដែលអង្គសន្និបាតសម្រេចបានក្នុងរយៈពេលពេញមួយថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នឹងបន្តអនុវត្តភារកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់ ដើម្បីបង្កើតសមិទ្ធផលថ្មីៗថែមទៀត ជូនរាជរដ្ឋាភិបាល ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍របស់ជាតិ។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបិទ **សន្និបាត ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០២១-២០២២។**

# ឧបសម្ព័ន្ធ ទី៦. កម្រងរូបថតអនុស្សាវរីយ៍















សន្និបាត
បូកសរុបលទ្ធផលការងារ ឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០២២



































សន្និបាត




បូកសរុបលទ្ធផលការងារ ឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥






























